# ច្បាប់ផ្សេងៗ


ច្បាប់ផ្សេងៗ
បោះពុម្ពផ្សាយជាធម្មទាន
ដោយ
អង្គការសន្តិស័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា (អេស វី អេ)
ភ្នំពេញ
ព.ស. ២៥៤៩ - គ.ស. ២០០៥

# ច្បាប់ផ្សេងៗ

## ចម្លងពីសាស្ត្រាស្លឹករឹត

ការផ្សាយរបស់

**សមាគម សម្តេច ជួន ណាត**

ព.ស ២៥១៨ គ.ស ១៩៧៤

# សេចក្ដីផ្ដើម

គ្រឹះស្ថានបោះពុទ្ធនិងចែកផ្សាយ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជននិងកីឡា អោយបោះពុម្ពសៀវភៅ "**ច្បាប់ផ្សេងៗ**" ឡើងវិញ ដើម្បីរក្សាការពារកេរដំណែលវប្បធម៌ អក្សរសាស្រ្តជាតិ និងបំពេញសេចក្ដីត្រូវការរបស់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ។ ក្នុងការបោះពុម្ពផ្សាយឡើងវិញនេះ យើងខ្ញុំបានរក្សាអត្ថន័យអត្ថរស ខ្លឹមសារ និងឃ្លោវឃ្លា នៅដដែលទាំងស្រុង។

យើងខ្ញុំ រីករាយនឹងរង់ចាំទទួលនូវការរិះគន់កែលំអរ ក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ដើម្បីធ្វើអោយការបោះពុទ្ទផ្សាយលើកក្រោយៗកាន់តែសុក្រិតថែមទៀត។

បោះពុម្ពផ្សាយឡើងវិញតាមច្បាំដើម

ដោយគ្រឹះស្ថានបោះពុទ្ធ និង ចែកផ្សាយ

នៃក្រសួងអប់រំ យុវជន និង កីឡា

ចំនួន ៥ ០០០ច្បាប់

**រោងពុម្ព អប់រំ**

គ.ស ២០០៣ ព.ស ២៥៤៧

# អារម្ភកថា

គោលបំណង ដែលចែងយ៉ាងច្បាស់ ក្នុងលក្ខន្តិកៈរបស់ខ្លួន ត្រង់មាត្រា២ វគ្គទី១ សមាគម សម្ដេច ជួន ណាត មានមុខងារខាងផ្សាយស្នាដៃរបស់ខ្មែរពិតប្រាកដ មានស្នាដៃខាងសិល្បៈនិងអក្សរសិល្ប៍ជាដើម ដើម្បីតម្រូវតាមនាមរបស់សមាគម គឺ សម្ដេច ជួន ណាត ដែលជាអ្នកប្រាជ្ញធំរបស់ខ្មែរសុទ្ធសាធ។

កាលពីឆ្នាំមុនៗ យើងមានបោះពុម្ពសៀវភៅខ្លះៗហើយដែរ តែច្រើនជាវប្បធម៌ទូទៅ ទើបតែមកដល់ពេលប្រជុំ នាថ្ងៃពុធទី ១៧ កក្កដា ១៩៧៤ កន្លងទៅនេះគណៈកម្មាធិការនាយក ក៏បានសម្រេចមូលមតិគ្នាថា : ត្រូវចាត់ការបោះពុម្ពផ្សាយស្នាដៃអក្សរសិល្ប៍បុរាណខ្មែរយើង ឱយបានច្រើនបំផុត តាមមធ្យោបាយដែលអាចធ្វើបាន ដើម្បីក្នុងគោលបំណងជួយផ្សព្វផ្សាយស្នាដៃអ្នកប្រាជ្ញខ្មែរ និងជួយប្រមូលឯកសារជូនអ្នកសិក្សាទូទៅ ឱយបានសាយភាយពេញផ្ទៃប្រទេស និងឆ្លងទៅកាន់ប្រទេសក្រៅទៀតផង។ ដោយសារសេចក្ដីសម្រេចនេះហើយ ដែលកើតបានជារូបរាងសៀវភៅនេះឡើង សម្រាប់ជាគូដៃដល់អ្នកសិក្សា និងជាជំនួយខាងអង្គការបោះផ្សាយឯទៀតៗក្នុងប្រទេសយើង។

បន្ទាប់ៗទៅទៀត សមាគម សម្ដេច ជួន ណាត ខំប្រឹងស្រាវជ្រាវរកស្នាដៃបុរាណដ៏ល្អៗមកបោះផ្សាយបន្តទៅទៀត ទាំងផ្នែកអក្សរសីល្ប៍ទាំងផ្នែកវប្បធម៌ទូទៅឱយតែសម្គាល់ថា ជាការមានប្រយោជន៍សម្រាប់វប្បធម៌ជាតិ និងជាកេរ្តិ៍អក្សរសិល្ប៍ខ្មែរសុទ្ធសាធ។

សមាគម សូមថ្លែងអំណរគុណយ៉ាងស្មោះទុកជាមុន ចំពោះអស់លោក អ្នកដែលជួយឧបត្ថម្ភដល់ការផ្សាយ របស់សមគម សម្ដេច ជួន ណាត ឱយកាន់តែបានរីកចំរើនឡើង។

*ភ្នំពេញ ខែសីហា ១៩៧៤*

❁ ❁ ❁

# សមាគម សម្ដេច ជួន ណាត

# សេចក្ដីសង្កេតចំពោះច្បាប់ផ្សេងៗ

ច្បាប់ដំបូន្មាន ដែលអ្នកប្រាជ្ញបុរាណ ចងក្រងទុកមក សម្រាប់ប្រៀនប្រដៅ ពត់ហាត់កាយ វាចា ចិត្ត របស់បុលបុត្ត-កុលធីតា មានច្រើនច្បាប់ណាស់ ដែលគេប្រមូលផ្ដុំគ្នាមក ឱយឈ្មោះសរុបមួយថា "ច្បាប់ផ្សេងៗ"។ ដើម្បីយល់ពីផលប្រយោជន៍ និងទ្រង់ទ្រាយច្បាប់ទាំងនេះឱយច្បាស់លាស់ គប្បីធ្វើការសង្កេត ដូចតទៅនេះ ៖

១. ប្រភពដើម :

អត្ថបទច្បាប់ទាំងនេះ សុទ្ធតែគ្មានចុះកាលបរិច្ឆេទ ឱយយើងដឹងច្បាស់ថា កើតនៅក្នុងឆ្នាំណាប្រាកដប្រជាទេ តែអ្នកសិក្សាអាចសម្គាល់បានថា ជាអត្ថបទកើតនៅក្នុងសម័យឧត្តុង្គ គឺរវាងសតវត្សទី ១៧-១៩ និង ១៩ ប៉ុណ្ណោះ ដោយសារគេប្រមាណតាមគោលគំនិត ពាក្យសម្ដីនិង ទំនៀមទម្លាប់ ដែលមានចែងក្នុងអត្ថបទទាំងនោះ។

ក្នុងច្បាប់ផ្សេងៗ គេរកឃើញកំនើតដើមនៃគំនិត តែងតែដកស្រង់បានពីប្រភព៣គឺ ៖

ក. មួយភាគធំ អ្នកនិពន្ធដកស្រង់គំនិតអំពីដំបូន្មានរបស់ព្រះពុទ្ធ (ពុទ្ធឱវាទ) ព្រោះអ្នកនិពន្ធច្រើនជាអ្នកបានរៀនសូត្រជ្រៅជ្រះខាងពុទ្ធសាសនា ដ៏ជាវិជ្ជាជាន់ខ្ពស់ ក្នុងកិច្ចសិក្សារបស់ខ្មែរយើងសម័យនោះ។

ខ. អ្នកនិពន្ធស្រង់គំនិតនិងពាក្យសម្ដី ដែលជាទំនៀមទម្លាប់បុរាណ ហើយដែលអ្នកស្រុកចាំមាត់តៗគ្នាមកអធិប្បាយ។

គ. អ្នកនិពន្ធដកស្រង់ ការពិសោធន៍ផ្ទាល់ ដែលគេបានជួបប្រទះក្នុងជីវភាពរាល់ថ្ងៃ តែងមានដំណើរត្រូវខ្លះ ខុសខ្លះ ដែលអ្នកនិពន្ធនិយមធ្វើការសង្កេតហើយចងចាំទុកយកមកប្រៀនប្រដៅកូនចៅតៗមកទៀត។

ច្បាប់ត្រីនេតិ ច្បាប់កូនចៅ និងច្បាប់វិធូរបណ្ឌិត ពិតជាកើតពីអ្នកប្រាជ្ញាធំជុំណាស់ ព្រោះមានខ្លឹមសារពិសេស ប្រកបដោយអត្ថន័យជ្រាលជ្រៅទូលំ

ទូលាយ។ ច្បាប់អរិយសត្ថា ច្បាប់ក្រម កើតពីព្រះសង្ឃឧបជ្ឈាយាចារ្យ ដែលប្រៀនប្រដៅសិស្សច្បាប់ពាក្យចាស់ ច្បាប់ហែមហាជន កើតពីចាស់ៗព្រឹទ្ធព្រេង ប្រដៅក្មេងៗតាមតម្រាយបុរាណ ច្បាប់កេរកាល កើតពីអ្នកមានម្នាក់ប្រដៅកូន។ ឯច្បាប់ព្រះរាជសម្ភារ គឺព្រះរាជសម្ភារខ្លួនឯង ជាអ្នកតែង ហើយទោះជាលោកដាក់ឈ្មោះច្បាប់នេះថា "**រាជនេតិ**" តែអ្នកស្រុក នៅតែហៅច្បាប់ព្រះរាជសម្ភារ ដដែល។ សរុបសេចក្តីទៅគឺថា វិធីអប់រំរបស់ចាស់បុរាណលោកតែងប្រើតាមមធ្យោបាយអក្សរសិល្ប៍ គឺសរសេរជាពាក្យកាព្យឱយទន្ទេញចាំមាត់ រួចហើយស្រង់យកន័យដែលចាំមាត់នោះរំលឹកទូន្មានខ្លួនឯងតែម្តងទៅ។ អ្នកសិក្សាសព្វថ្ងៃ នៅតែដកស្រង់យកន័យល្អៗពីក្នុងនេះ មកប្រតិបត្តិអាចត្រូវបានជាដរាបដែរ បានជាគេចាត់ទុក **ច្បាប់ផ្សេងៗ** ជាអក្សរសិល្ប៍សាមញ្ញមួយ ផ្នែកខាងការអប់រំមនុស្ស។

# ច្បាប់ដែលមានក្នុងសៀវភៅនេះ

| | |
|---|---|
| -ច្បាប់ក្រម | -ច្បាប់ពាក្យចាស់ |
| -ច្បាប់កេរ្តិ៍កាល | -ច្បាប់ហែមហាជន |
| -ច្បាប់អរិយសត្ថា | -ច្បាប់បណ្តាំបិតា |
| -ច្បាប់ស្រី | -ច្បាប់កូនចៅល្បើក |
| -ច្បាប់ប្រុស | -ច្បាប់វិធូរបណ្ឌិត |
| -ច្បាប់ទូន្មានខ្លួន | -ច្បាប់ត្រីនេតិ |
| -ច្បាប់កូនចៅ | -ច្បាប់ព្រះរាជសម្ភារ។ |

អាស្រ័យដោយប្រភពទាំងពីនេះ ទើបន័យក្នុងច្បាប់ផ្សេងៗមានលាយការហួសសម័យនិយមខ្លះ ខាងផ្នែកទំនៀមរស់នៅ ប៉ុន្តែត្រូវជានិច្ច ខាងគោលការណ៍អប់រំ ឬគោលសីលធម៌។

**២. ន័យខ្លឹមសារ:**

ច្បាប់ផ្សេងៗ ពត់ហាត់មនុស្សឱយមានចរិយល្អដើម្បីរស់នៅសុខសាន្ត ក្នុងសង្គមដែលច្បាប់ទាំងនេះមាន អប់រំតាមន័យផ្សេងៗគ្នាដូចជា ៖

-អប់រំឱយមានសណ្តាប់ធ្នាប់ត្រឹមត្រូវ តាមគន្លងប្រពីណីជាតិ ដែលជាកេរអរិយធម៌យូរអង្វែងហើយ។

-ដឹកនាំឱយមានប្រាជ្ញាវាងវៃ កាលបើឮ ឬបើឃើញបញ្ហាអ្វីមួយកើតឡើងភ្លាមក៏អាចយកប្រាជ្ញានោះទៅដោះស្រាយបានភ្លាមៗ គ្រប់ពេលដែលគេជួបប្រទះក្នុងមុខរបរ ឬក្នុងការងារប្រចាំថ្ងៃ ។

-បង្កើនសណ្តាប់ល្អ ក្នុងរបបរស់នៅ តាមគន្លងច្បាប់គ្រប់គ្រងប្រទេស ព្រមទាំងជាគតិដាស់តឿនក្រើនរំលឹកដល់អ្នកក្រោយៗទៀតផង។

រួមសេចក្តីទៅ **ច្បាប់ផ្សេងៗ** ជាកម្រងចំណេះប្រាជ្ញាមនុស្សក្នុងសម័យនីមួយៗដែលជាមធ្យោបាយ ជួយដោះស្រាយបញ្ហារាយរងសង្គម និងរៀបចំគ្រួសារ ឬសង្គមជាតិ ឱយសុខសាន្តល្អ ។

**៣. កាលបរិច្ឆេទ និង អ្នកនិពន្ធ :**

ច្បាប់ផ្សេងៗទាំងអស់ មិនសូវមានចុះកាលបរិច្ឆេទ ឱយយើងដឹងច្បាស់ទេ ឯអ្នកនិពន្ធ ក៏មិនសូវបានស្គាល់នាមដែរ ខ្លះគ្រាន់តែដាក់ប្រាប់ងារ ឬប្រាប់មុខរបរ ដូចជាថា "អរិយសត្ថា" ឬថា "សេដ្ឋី" ជាអ្នកផ្តើមសរសេរឡើង។ មានតែច្បាប់ប្រុសច្បាប់ស្រីទេ ដែលអ្នកនិពន្ធប្រាប់នាមថា "ម៉ឺនមៃ" ជាអ្នកតែង តែគ្មានបញ្ជាក់ថាលោកជាមន្ត្រីអ្វី? នៅស្រុកណា? តែងពីឆ្នាំណាឡើយ។

❁ ❁ ❁

# ច្បាប់ក្រម

១. នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍។

នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធវគ្ក
ចូរធ្វើឱយត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកនូវនិព្វាន។

នរអ្នកផង ទោះដឹងយល់ហោង ចិត្តនោះឱយហ៊ាន
បំពេញព្រះផ្នួស ដោយព្រះទូន្មាន កុំធ្វើលឹកលាន
ដោយចិត្តអន្ធពាល។

ម្តាយឪពុកសោតណា ស្រឡាញ់ស្ងួនភ្ងា ហៅកូនសង្ក្សារ
អាចមកបំបួស ហេតុចង់សម្ភារ ប្រើបង់អន្ធពាល
រៀនដោយក្រមច្បាប់។

៥. សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាគាប់
សង្វាតសូត្ររៀន ដោយគ្រូប្រញ៉ប់ប្តី កុំធ្វើលេលាប់
ដោយចិត្តមាក់ងាយ។

ហែអស់សាមណេរ ម្តាយមកបង្វើរ អ្នកជាបាធ្យាយ
សង្វាតសូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាយងាយ
ដូចនៅគ្រហស្ថ។

កុំធ្វើរាយមាយ នឹងគ្រូបាធ្យាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឱយណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឡាយ។

អាសូរមេបា ចិញ្ចឹមរក្សា កុំឱយអន្តរាយ
អាចយកមកផ្ញើ នឹងគ្រូបាធ្យាយ ហេតុចង់ពណ្ណរាយ
ប្រយោជន៍ទាំងបី។

មួយចង់ក្តីច្បាប់ ឱយបានខ្លួនគាប់ នៅនាលោកិយ
មួយចង់ប្រាជ្ញា មិនឱយអប្រិយ មួយចង់បារមី
នាំញាតិទាំងឡាយ។

១០. ហែអស់សាមណេរ កុំធ្វើដែលដែរ ត្រង់ក្តីពាយងាយ

លំអុតបម្រើ អ្នកជាបាធ្យាយ ជូនបុណ្យទៅម្ដាយ
ឪពុកទីទៃ។
សង្វាតសូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ
លំអុតបម្រើ ផ្ដាប់ដោយហឫទ័យ បារម្ភមៃៗ
ក្ដីច្បាប់កុំបីបង់។
ច្បាប់នេះសោតណា ទូន្មានអាត្មា ដោយនូវក្រឹត្យសង្ឃ
ត្រង់ណាហៅច្បាប់ ឱយមានបារម្ភ ទើបខ្លួនជាធំ
ទៅដល់មហាក្សត្រិយ៍។
ច្បាប់នេះសោតណា ទូន្មានអាត្មា ចេរនៅពុំបាត់
ទោះខ្លួនឥតបុណ្យ បម្រើមហាក្សត្រិយ៍ គោរពប្រតិបត្តិ
យសនោះពុំលែង។
១៥. ហេតុបានដឹងច្បាប់ បានដូចបង្គាប់ ចិត្តគ្រូយល់ស្ដែង
ទោះទៅបម្រើ ស្ដេចជាគម្ដែង យសនោះពុំលែង
ប្រាកដពណ្ណរាយ។
ក្ដីនេះជាច្បាប់ ឱយសាមណេរគ្រាប់ សព្វសរិលទាំងឡាយ
កុំសើចតិះដៀល អ្នកជាបាធ្យាយ អ្នកហោងស្មើម្ដាយ
បង្កើតក្ដីច្បាប់។
សាមណេរណាៗ ទោះមានប្រាជ្ញា នឹងចង់រៀនគ្រាប់
ឱយយកត្រចៀក នោះឱនចូលស្ដាប់ ធ្វើដោយក្រមច្បាប់
នៃគ្រូបាធ្យាយ។
សមណេរណាសោត ចិត្តនោះក្រេវក្រោធ ឱយចៀសចេញឆ្ងាយ
ច្បាប់នេះមិនខំ សាមណេរទាំងឡាយ តាមចិត្តសប្បាយ
អាត្មាទីទៃ។
នរូអ្នកណា នឹងស្វែងប្រាជ្ញា ឱយបានខ្លួនថ្លៃ
ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្ដាប់ដោយហឫទ័យ
អ្នកជាបាធ្យាយ។
២០. ទោះនឹងស្វែងធម៌ ឱយមានសម្គាល់ កុំធ្វើរាយមាយ
ទោះនឹងស្វែងច្បាប់ កាន់ខ្ជាប់កុំបីណាយ កុំឱយអន្តរាយ
នូវច្បាប់ក្រមផង។
រីគ្រូបាធ្យាយ ប្រដូចនូវម្ដាយ ឪពុកយើងផង
ហ្វឹកហ្វឺនប្រដៅ មិនឱយមានឆ្គង តាមដោយគន្លង

ព្រេងព្រឹទ្ធបុរាណ។
នរអ្នកណា នឹងស្វែងប្រាជ្ញា ជារស្មីប្រាណ
ឱយគិតសញ្ជឹង រំពឹងលែងបាន កុំធ្វើបំពាន
ប្រទូស្តរឹងស្មង។
នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង
ទោះនឹងឆ្ពោះទៅ ស្រុកតូចធំផង សឹងដូចបំណង
នៃចិត្តចិន្តា។
វីនឹងចេះឯង ដូចអ្នកវង្វេង កណ្តាលអធ្វា
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា
ឥតអ្នកដឹកដៃ។
២៥. សូម្បីរកផ្លូវ ពុំដែលនឹងត្រូវ សឹងពានឯព្រៃ
ហេតុត្បិតចេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ
ដូចដល់ពុំដល់។
នេះដូចអ្នកផង ពុំដោយគន្លង នៃលោកណាយល់
សឹងធ្វើមោហោ ទោសោកំហល់ ពុំអាចទប់ទល់
នាធ្ងន់នាស្រាល។
ប្រដៅក្តីច្បាប់ សឹងថាពុំគាប់ ហេតុចិត្តអន្ធពាល
ក្តីច្បាប់ទម្ងន់ សឹងថាជាស្រាល ហេតុចិត្តអន្ធពាល
ចង់តែសប្បាយ។
ពុំដឹងដើមគ្រូ បង្កើតអភិរូប៍ ប្រដូចនូវម្តាយ
ភ្លឺពីមនុស្សលោក រួចដល់សួគ៌នាយ ចៀសចតុរាបាយ
នរកទាំងបួន។
នាបីហៅគ្រូ កុំធ្វើមូទូ ចិត្តនោះឱយស្លូន
កុំធ្វើតម្កើង ចង់ធំតែខ្លួន ក្រែងបាបមកចួន
នៅនាលោកិយ។
៣០. វីគ្រូបាធ្យាយ អាចឱយពណ្ណរាយ មានរូបរស្មី
ហើយឱយរុងរឿង អស់បញ្ចិន្ទ្រិយ ស្មើព្រះជននី
ជនកសោតហោង។
ព្រះជនកសោតណា បង្កើតអាត្មា ឱយមានសរិលផង
រក្សាពីតូច មិនឱយមានហ្មង អស់សុខទុក្ខផង
ពុំដែលនឹងឆ្អន់។

ព្រះជនកព្រះជននី បើនឹងស្រដី ប្រសើរពេកពន់
ថាភ្នំព្រះសុម៉េរុ នោះហោងមហាធ្ងន់ ថាបើនឹងគណន៍
ពុំអាចកន្លង។

វីគ្រូបាធ្យាយ ប្រដូចនូវម្ដាយ ឪពុកឯងហោង
អាចឱយក្ដីច្បាប់ ប្រដៅធម៌ផង ដោយនូវគន្លង
ព្រះពុទ្ធទាំងឡាយ។

នរូអ្នកណា ទោះមានប្រាជ្ញា ឱយគិតវែងឆ្ងាយ
គុណនោះទាំងបី ហៅមហាទូលាយ កុំឱយអន្តរាយ
ក្ដីពីព្យាយាម។

៣៥. វិបុណ្យនិងបាប អំពើសភាព នោះវាតែតាម
ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលចៀសបាន
ត្រង់ក្ដីសល់វ៉ល់។

ឱយគិតជញ្ជឹង ហើយឱយរំពឹង ប្រាជ្ញាឱយយល់
ឱយមានវិរិយំ សច្ចំកុសល កុំធ្វើសល់វ៉ល់
នឹងក្ដីទុក្ខសោក។

នរូអ្នកណា នឹងនាំអាត្មា ឧស្សាហ៍អធ្យោគ
ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាបថមោក្ខ
គឺនិព្វានហោង។

# ច្បាប់កេរ្តិ៍កាល

## បទព្រហ្មគីតិ

១.   កេរ្តិ៍កាលពីព្រេងព្រឹទ្ធ      សាងសុចរិចទៀងទុកនៅ
សេដ្ឋីផ្ដាំប្រដៅ      បុត្រសង្សារទុកក្រោយហោង។
កូនអើយកេរ្តិ៍មេបា      ចូររក្សាគន់គិតគ្រង
ថៃទាំចាំរួសរង      ប្រុងប្រយ័ត្នប្រយោជន៍យូរ។
ធម្មតាអ្នកជាជាតិ      កាលគេអាទ៏ឱយគិតគូរ
កុំខ្ជិលដេកទទូរ      ដល់ថ្ងៃរះពេញពន្លឺ។
តាក់តែងខ្ញុំកំដរ      ចេញទៅរកធ្វើស្រែភ្លឺ
ចិញ្ចឹមគោក្របី      រកខ្សែវល្លិបោះក្រោលឃ្នង។
២.   ធ្វើស្រែទិសប្រាំបី      ខ្ញុំប្រុសស្រីចេញជួយផង
មើលផ្ទះស្រះរបង      វាំងចំណារគួររក្សា។
ឱយមានក្ដីបារម្ភ      ធ្វើស្រែកុំចោលចំការ
ដឹងដែកកាំបិតព្រា      ទុកឱយជាកុំឱយបាត់។
ដេកយប់ឱយវាំងទ្វារ      ទ្រព្យសម្រាលរៀបប្រយ័ត្ន
ចងទូកកុំឱយសាត់      ផ្ទះបាក់ចែកឆាប់ទល់ទ្រ។
សារពើទ្រព្យអ្វីៗ      ប្រុងស្មារតីទុកអោយល្អ
ឧសទឹកស្រូវអង្ករ      យកចេញចាយមានកំណត់។
កុំអាងមានទ្រព្យច្រើន      ពុំក្រវើនរកផ្គង់ផ្គត់
យកចាយៗដោយបទ      ទោះនឹងទុកៗដោយខ្នាត។
១០.   រទេះសេះដំរី      រាប់បញ្ជីកុំឱយឃ្លាត
ខ្ញុំណាមានមារយាទ      ទុកដាក់ដៃឱយរក្សា។
សប្បុរសយល់ដោយមុខ      ស៊ុកគ្រលុកពេកពុំជា
កំណាញ់ក្រៅតម្រា      សោតសឹងអាប់ប្រយោជន៍យស។
រក្សាខ្លួនឱយរុង      រឿងឧត្ដុង្គឧត្ដមខ្ពស់
ប្រដាប់ដោយស័ក្ដិយស      ខ្លួនជាធំឱយថៃថ្នូន។
ឱយទានតាំងចិត្តស្មោះ      កុំអាឡោះអាល័យស្ងួន
ទ្រព្យនេះនឹងនាំខ្លួន      ទៅបរលោកពុំសោះសូន្យ។
ទ្រព្យធនទោះថោកថ្លៃ      កុំដាក់ដៃឱយតែកូន

នូវអស់ទាំងបងប្អូន　　អ្នកដទៃរក្សាតាង។
១៥. ទុកចិត្តខ្ញុំមើលដាក់　　ស្មើភ្នែកខ្វាក់ទាំងសងខាង
ឱយកូនគន់មើលតាង　　ស្មើភ្នែកម្ខាងពុំពេញពីរ។
ធ្វើអ្វីធ្វើឱយហើយ　　កុំទុកឡើយបង្កើតកិរ
សំអាតអស់សរិល　　កុំឱយមានក្តីនិន្ទា។
ដំណេកដេកជាខ្នាត　　ឱយសំអាតសំអាងជា
ទើបទេវតារក្សា　　ចម្រើនសុខស្រីសួស្តិ៍។
គ្រឹះហាឱយផ្ចិតផ្ចង់　　កុំឱយផងផុយធូលី
ជម្រះបារបោសដី　　ឱយហ្មត់ហ្មងកើតសុខា។
អញ្ចាលទុកឱយគង់　　ប្រាក់ក្នុងថង់ទុកឱយជា
ប្រើខ្ញុំមើលមុខវា　　ទោះកាចជាមើលឱយស្តែង។
២០. សារពើរួសរៀនរិះ　　ឱយចាំចេះៗចាំចែង
ចង់គាប់ប្រើស្វះស្វែង　　រករៀនរិះសារពើក្តី។
សប្បុរសពេកចាញ់ធន　　នាទុជិនចាញ់ឥន្រ្ទីយ
ប្រពន្ធល្អច្រើនចាញ់ប្តី　　ពាក្យច្រើនភូតចាញ់អាត្មា។
ឈើផ្លែច្រើនចាញ់ស្លឹក　　ត្រីច្រើនទឹកល្អក់ពុំជា
ទ្រព្យច្រើនព្រួយរក្សា　　ទ្រព្យតិចណាព្រួយរិះគិត។
ដេកយប់កុំដំអក់　　ឱយលង់លក់ក្រៅសុចរិត
ខ្ញុំណាមានគំនិត　　គួរឱយគិតប្រណីវា។
ចងទូកបោះបង្គោល　　រិះរកថ្មោលពួរយុត្តា
ការខ្យល់កាចពុំជា　　ក្រែងពានពារបោកបែកបាត់។
២៥. រៀនរិះសារពើក្តី　　ទោះស្រដីនាន់ពាក្យស័ត្យ
ចាំក្បួនចាំឱយស្ទាត់　　កុំអៀនព្រៀនសមពាក្យពោល។
ការក្រកុំគិតងាយ　　ការសម្ងាយជាកម្រោល
សន្សឹមកុំបំបោល　　ក្រែងពុំដល់ដូចប្រាថ្នា។
រៀនរិះរួសរវាំង　　ធ្វើស្រែប្រាំងស្រែវស្សា
ធ្វើស្រែមានចំណារ　　ធ្វើចំការចាររបង។
ផ្លូវវៀចកុំបោះបង់　　ផ្លូវណាត្រង់កុំដើរហោង
ដើរដោយផ្លូវគន្លង　　តម្រាយអ្នកចាស់បុរាណ។
ឆ្កែជាឱយបាយឆី　　ដេកនៅដីចាំធនធាន
គ្រឿងសឹកទុកទាហាន　　គេរ្គ័គម្ពីរទុកប្រាជ្ញប្រាយ។

៣០. យល់តូចកុំអាលខំ ទោះយល់ធំកុំអាលស្រាយ
គិតក្តីកុំគិតងាយ មើលពិនិត្យពិនិស្ស័យ។
កូនអើយកេរ្តិ៍មេបា ចូររក្សាចាំសព្វថ្ងៃ
ទ្រព្យធនទោះថោកថ្លៃ គួររក្សាកុំបីឆ្ងាយ។
ពាក្យនេះជាត្រកាល ជាខ្លឹមសារទៀងទុកឱយ
កូនចៅនៅឯក្រោយ តែងទូន្មានអង្គអាត្មា។
ថៃទាំទើបគង់ទ្រព្យ រៀបរណ្តាប់ទុកទើបជា
ចាយវាយក្រៅតម្រា សឹងវិនាសធនធានផង។
បានមកទុកឱយគង់ កុំឱយបង់បាត់បំណង
រៀនរិះរក្សាគ្រង យកចេញចាយដោយរដូវ។
៣៥. ដឹងហាបឱយដឹងតុល ចែកឱយយល់ទៀងត្រាជូ
គិតគ្រប់សព្វដោយផ្លូវ ក្តីចន្លោះកុំបីមាន។
ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាថ៌ឱវាទទាន ជាសូរេចបណ្តាំហោង។

❧ ❦ ❧

# ច្បាប់អរិយសត្ថា

១. អរិយសត្ថា[១] គន់គិតថែងចារ ចងទុកជាច្បាប់
ឱយអស់សិស្សផង ត្រងត្រាប់សណ្តាប់ យកជាតម្រាប់
តម្រង់អាត្មា។

ឱយមានប្រយោជន៍ ប្រយ័ត្នអសោធិ៍ រាល់រូបអ្នកណា
អម្បាលមករៀន របៀនសាស្ត្រា ប្រយ័ត្នអាត្មា
ការកេរ្តិ៍លោកិយ។

ទោះនឹងចេញទៅ ប្រយោជន៍នានៅ ផ្តាប់ផ្គុនមន្ត្រី
ឱយត្រូវនឹងច្បាប់ សណ្តាប់សួស្តី ដូចលោកស្រដី
ប្រដៅទុកមក។

បើមិនចង់ទេ ចង់នៅទំនេរ ជួញប្រែរិះរក
ចិញ្ចឹមជីវិត គួរគិតរៀនយក របៀននោះមក
ទើបរកទ្រព្យបាន។

៥. វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច ឱយបានដឹងដាន
ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ
កត់ត្រាបញ្ជី។

ឱយបានប្រយោជន៍ ប្រយ័ត្នអសោធិ៍ ជាអ្នករកស៊ី
សម្រាប់លោកិយ ប្រក្រតីជាទី សម្គាល់បញ្ជី
ស្មៀនត្រាសៀវភៅ។

គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឱយស្ទាត់ដោយនូវ
វាយលេខទាត់ក្បាច់ ឱយស្រេចឃើញនូវ សឹមថយចេញទៅ
តាមផ្លូវលោកិយ។

ល្មមដឹងតិចច្រើន ល្មមដឹងក្រវើន ទ្រព្យធនអ្វីៗ
លេខនិងអក្សរ កំដរស្មារតី សម្រាប់លោកិយ
នោះឯងទើបត្រូវ។

*(១) អរិយសត្ថា ជាសមណសក្តិ ទីមេគណ ឬចៅអធិការដែលជាអ្នកតែច្បាប់នេះ បានគេជាឱយឈ្មោះថា "ច្បាប់អរិយសត្ថា" ដូច្នេះ ។*

បើតែវិលវេះ ខ្ជិលដេកស្រមេះ ស្រមូញស្មូញស្មូវ
ស្រទាងលើខ្នើយ ន្តើយលក់ទៅ នរណានឹងនៅ
ដាស់តឿនឱយទៀត។

១០. មិនដឹងឫអ្វី ក្នុងរាជ្យលោកិយ រាជការចង្អៀត
នរណាទុកឯង លេងវាយដៃព្រាត ឃើញហើយគេបៀត
តម្រៀតរាជការ។

ហេតុនោះគួរគិត គួរកាន់គំនិត គួរគិតឧស្សាហ៍
សង្វាតរករៀន របៀនសាស្ត្រា តម្រិះប្រាជ្ញា
បង្ការទុកទៅ។

បើដោះខ្លួនរួច រាប់ជាអ្នកស្រួច ដឹងគិតរាក់ជ្រៅ
ក្នុងរាជ្យលោកិយ សេចក្ដីឥឡូវ គិតឱយឃើញផ្លូវ
នឹងទៅមុខទៀត។

វីត្រង់ឯខ្លៅ គេថយចេញទៅ រកស៊ីចង្អៀត
គិតគួរម្ដេចម្ដា ប្រវាំបែរបៀត ពឹងអ្នកកន្ទៀត
ដូចខ្លួនកាលណា។

ហេតុតែខ្លួនឯង ចេះគិតតាក់តែង ឱយគ្រប់ប្រការ
ទាំងលេខទាំងក្បាច់ ស្រេចនូវអាត្មា ឯងឱយអស់ការ
គិតគួរសព្វសាយ។

១៥. ទើបបានគេកោត គេមានចំណោទ គេកោតប្រាជ្ញប្រាយ
គេយល់ឯងចេះ ចំណេះលៃបខាយ ពុំមានក្លែងក្លាយ
បំបាត់បានឡើយ។

វីត្រង់អ្នកខ្លៅ ផ្ដេកផ្ដិតចិត្តទៅ យកគេជាត្រើយ
កាលម្ដងគេត្រង់ គង់ចិត្តនៅឡើយ ដល់ពីរដងហើយ
គេប្រែប្រាជ្ញា។

គេគិតទាយទាត់ វាយលេខបំភ្លាត់ បំផ្លាញអាត្មា
ចំណេញទៅរក ទទេអសារ ខ្លួនឯងឥតការ
ខាតទុកក្រខ្លួន។

នេះឯងក្មេងអើយ កុំប្រហែសឡើយ រៀនទុកជាក្បួន
ទាំងលេខទាំងក្បាច់ អាស្រ័យនៅខ្លួន អក្សរឱយសួន
ទាន់ខ្លួននៅក្មេង។

តែចាស់បន្តិច វិញ្ញាណភ្លាំងភ្លេច គំនិតប្រែផ្សេង
គិតការច្រើនមុខ កើតទុក្ខកន្លង ប្រាប់អស់ក្មេងៗ
ឱយដឹងឱយហើយ។

២០. កុំអាងម៉ែឪ សម្បត្តិដែលនៅ មានច្រើននោះឡើយ
ក្រែងឥតនឹងម៉ែ នឹងឪទៅហើយ ខ្លួនខ្លៅឆោតឆើយ
ងងឹតល្ងង់មោហា។

ក្រែងអស់ទាំងទ្រព្យ នោះវាមិនខ្ជាប់ នៅនឹងអាត្មា
ខ្លួនឯងឆោតឆៅ កំឡៅមោហា មិនចេះរក្សា
មិនបានគង់ទេ។

ខូចខាតមិនខាន គំនិតមិនបាន ប្រហែសខ្ញុំគេ
គេវាយគេជាក់ គេប្រើគេជេរ មិនឱយទំនេរ
ខ្មាសគេតិចអ្វី។

ដូច្នេះគួរគិត គួរឃើញគំនិត គួរគិតសេចក្ដី
ជាមនុស្សដូចគេ គួរតែឃ្នាតខ្មី រំឭកស្មារតី
ស្រឡាញ់រៀន។

កុំគិតខ្ជិលពេក កុំគិតពួនដេក កុំគិតវេះវៀន
កុំគិតមានពុត រមត់កិចកៀន កុំគិតអៀនប្រៀន
វេះវៀនចិត្តកាច។

២៥. ឱយរៀនចិត្តល្អ ដឹងធម៌អក្សរ គួរគិតកោតខ្លាច
ការកេរ្តិ៍ប្រយ័ត្ន គួរកាត់ចោលកាច គួរឱយខ្លួនខ្លាច
កុំឱយគ្រូទាយ។

ពាក្យគ្រូធ្ងន់ណាស់ ដំនៀលដល់ចាស់ ពីព្រេងមុននាយ
ឯត្រង់ពាក្យម្ដាយ ទំនាយគ្រូទាយ នេះឯងមិនងាយ
អាក្រក់ណាស់ណា។

ឱយប្រុងប្រយ័ត្ន បម្រើប្រណិប័តន៍ កាន់ចិត្តស្នេហា
កុំឱយអន់អាក់ ថ្នាំងថ្នាក់ចិន្តា គ្រូទាយហើយណា
ឆុតឆាប់ណាស់ហោង[១]។

---

*(១) ឃ្លាតពីនេះ ប្រហែលជាបាត់មួយគាថា បានជាបាត់ជួន។*

ឱយដឹងបាបបុណ្យ ស្គាល់ទោសនិងគុណ ជាទុនទៅមុខ
គុណគ្រូបាធ្យាយ គុណម្ដាយឪពុក រៀមច្បងទំនុក
ឱយសុខអនុកូល។

គ្រូមួយផងគ្នា រួមរ័ក្សចិត្តជា ស្នេហាមិត្រមូល
កុំនាំអុជហេតុ បំបែកចេញចូល កាច់កិនត្រកូល
បង្កើតមាត់ក។

៣០. កុំធ្វើមាក់ងាយ នឹងគ្រូបាធ្យាយ រៀនចិត្តឱយល្អ
ទោះអ្នកឯណា ណែផ្លូវអក្សរ អ្នកនោះឯងអរ
ឱយចិត្តមេត្រី។

កុំឱយសៅហ្មង លើលោកកន្លង ពោលពាក្យស្រដី
រឹងរូសទ្រគោះ ឈ្លាសឈ្លោះសេចក្ដី កើតទោសអប្រិយ
ជេរពោលប្រមាថ។

អ្នកនោះស្មើគ្រូ បង្កើតអភិរូប៍ គុណគេឱវាទ
គេជួយប្រដៅ គេហៅឱហាត ដាស់តឿនសង្វាត
ឱយឯងចេះឆាប់។

បើឯងចេះហើយ កុំភ្លេចគុណឡើយ ឱយដឹងដោយច្បាប់
គួរគិតកោតខ្លាច ដើរតាមសណ្ដាប់ គន្លងធម៌ច្បាប់
កុំឱយមាក់ងាយ។

នេះឯងគន្លង ត្រឹមត្រូវទំនង អំពីព្រេងនាយ
ឯរាជ្យឥឡូវ ច្រើនតែមាក់ងាយ ចេះហើយជេរម្ដាយ
ប្រមាថគ្រូវិញ។

៣៥. ហេតុដូច្នេះឯង លោកិយយល់ស្តែង តែងឃើញម្ដេចមិញ
ហីនហោចសូន្យសុង លិចលង់ទៅវិញ ទោសនោះឯងវិញ
កើតពីឯណា។

កើតពីចិត្តឯង បងកើតស្វះស្វែង បំផ្លាញអាត្មា
រោលរាលក្នុងពោះ ឆេះក្នុងឱរា បង្កើតទោសា
ឱយទុក្ខរូបឯង។

ចេះតែបន្តិច លើកខ្លួនកំប៉ិច កំប៉ោងឥតក្រែង
តែងឃើញរឿងមក យ៉ាងដូច្នេះឯង ម៉្លោះហើយវាតែង
ខុសនឹងទេព្តា។

រីអ្នកចិត្តល្អ ដឹងធម៌អក្សរ ចេះពិចារណា
ស្គាល់គុណនិងទោស សន្តោសអាត្មា អត់ឱនចិន្តា
ពុំដែលសៅហ្មង។

អ្នកនោះឯងនៃ សោតសឹងប្រពៃ សួស្តីកន្លង
បរលោកលោកិយ ឥតបីសៅហ្មង ទាំងទេព្តាផង
ចម្រើនឱយសុខ។

៤០. ដរាបរៀងទៅ សុខពីឥឡូវ រៀងទៅឯមុន
ចៀសចាកប្រាសប្រាណ ពិស្ថាននរក រៀងរួចបានសុខ
ដល់សួគ៌ាល័យ។

អរិយសត្ថា គន់គិតចែងចារ ចែងចង់សេចក្តី
តម្រង់តម្រាប់ ជាច្បាប់យ៉ាងថ្មី ដាស់តឿនស្រដី
សិស្សសព្វប្រការ។

៤២. គួរគិតរករៀន កិច្ចការរបៀន របបសាស្ត្រា
តាមច្បាប់និទាន ទូន្មានអាត្មា រៀងរាល់រូបា
សូរេចប់ហោង។

# ច្បាប់ស្រី

## ម៉ឺន-ម៉ៃ រៀបរៀង

## បទភុជង្គលីលា

នេះបទកំណត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី។
កាលនាងឥរន្ទវតី ចរចាកតាមប្តី គឺបុណ្ណកយក្សា[១]។
នាងវិមលាជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី។
នាងនឹងត្រាច់ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ។
ទៅឋានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បម្រើស្វាមី។
ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឱយស្វាមី អាក់អន់ចិន្តា។
នាងអើយគម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ។
ហៃកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី។
ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱយញាតិចូលចិត្ត។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងផីស្លា។
ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់។
កុំជូចិត្តស្នូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី។
ទោះនឹងនិយាយស្រដី ការកេរជាស្រី កុំស្តីឡេះឡោះ។
ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកំឡោះ សសៀរចូលជិត។
សើចព្រៀងបញ្ឆៀងមិនគិត ប្រុសព្រើសបានចិត្ត ទាហានដោយសារ។
ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន។
សើរើពុំធ្វើនឹងនួន ស្រដីមិនមួន មិនមានអៀនអន់។
ឃើញគេបៀតបែរគយគន់ សើចសួរចំអន់ ចំអកឱយប្រុស។
ហៅស្រីអប្រិយទុរយស មិនខ្លាចខ្លួនខុស មារយាទក្រិត្យក្រម។
ធ្វើការអង្គុយច្រឡំ នឹងសមពុំសម ថាឯងជាស្រី។
មិនកោតមិខ្លាចចិត្តប្តី ឱយប្រុសដទៃ មាក់ងាយប្តីណា។
ហៅស្រីឥតលក្ខណា ឥតមានកិរិយា មារយាទពុំសម។
ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឱយហើយ។

កុំទុកទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា។
ទោះធ្វើហូលគោមព្រៃផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។
ធ្វើឱយកើតកេរ្តិ៍ប្រសើរ ហើយកុំឱយដើរ លេងផ្ទះគេណា។
ឱស្ងួនខ្លឹមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ។
មានប្ដីបានអ្វីជាខំ រវល់កូនយំ កម្រចេះឆ្លៀត។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទាវតែធី។
រឹងព្រួយទាំងមួយទាំងពីរ រកបានឱយធី ទើបបានបាត់មាត់។
ទោះកាន់ការធ្វើឱយស្ទាត់ ហូលគោមគាត់កាត់ អន្ទងត្បាញទៅ។
កុំទុកក្នុងស្មុគស្មុញនៅ ក្រែងដល់យូរទៅ ខាតខូចអសារ។
ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។
ចូររករៀនយកច្បាប់ស្រី ឱយកោតខ្លាចប្ដី គម្លែងក្រឡា។
ធ្វើវត្តប្រតិបត្តិសោតណា ឱយនាងរក្សា ភ្លក់ភ្លើងទាំងបី។
ឱយកាត់ឱយគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្លុំឱយឆេះ។
ក្រែងរាលដូចដាលព្រាយប្រេះ កើតក្ដៅរលេះ រលាយអស់អង្គរ។
ភ្លើងក្រៅកុំនាំទៅក្នុង ឱយឆេះបំផ្លុង រឹងផ្លុំបង្កាត់។
ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱយឆេះឯក្រៅ។
អុជអាលបណ្ដាលឱយក្ដៅ ដាលដល់កូនចៅ អសោចិ៍អប្រិយ។
ឱយនាងខំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឱយគង់។
ភ្លើងនោះឱយគុណពុំលង់ នឹងឱយឧត្តុង្គ ឧត្ដមកន្លង។
កើតយសរបស់ទ្រព្យផង បរិបូណ៌ឥតហ្មង ប្រសើរក្លាត់ណា។
ភ្លើងមួយនោះឱយរក្សា គឺគុណមាតា បិតាស្ងួនគ្រង។
ឱយនាងធ្វើដោយគន្លង ប្រណិប័តន៍កុំឆ្គង នឹងម្ដាយឪពុក។
ឱយខំថៃទាំងញឹកញ៉ុក ចំណីចំណុក ចំណង់អាត្មា។
កុំឃ្លានទុកធីឡើយណេ ឆ្ងាញ់ឈ្ងុយពិសា ជូនជាប្រក្រតី។
ពាក្យពេចន៏ការកិច្ចអ្វីៗ អត់ឱនកុំបី ឱយអាក់ចិន្ដា។
ភ្លើងមួយគម្លែងក្រឡា គឺប្ដីអាត្មា បិតថេររួមរ័ក្ស។
ឱយនាងប្រណិប័តន៍ជៀកជាក់ កុំធ្វើឱយអាក់ ឱយអន់ចិត្តប្ដី។
អត់ឱនខ្លាចខ្លួនជាស្រី កុំឱយស្រដី ទុកគេជាស្មើ។
ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្ដាប់។
ទោះប្ដីស្រដីពុំគាប់ ពុំគួរឱយប្រាប់ បានដឹងដល់ម្ដាយ។

កើតខឹងរែងរឹងខ្វរខ្វាយ ឮពាក្យពីម្ដាយ ខ្សឹបខ្សៀវប្រាប់ប្ដី។
មិនក្សាន្តបែកបានពីរបី កើតជាសម្ដី សួរចុះសួរឡើង។
ពុំស្ងាត់ស្ងៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់។
តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀតឱយបាត់ ឱយបានទីសុខ។
ជជែកស្ទើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ឡើយនៃ។
នេះហៅភ្នក់ភ្លើងទាំងបី ម្ដាយផ្ដាំកូនស្រី ឱយខំរក្សា។
នាងអើយគម្ពែងក្រឡា ខុសឆ្គងម្ដេចម្ដា ម្ដាយផ្ដាំកូនស្រី។
ឱយអត់សង្កត់ហឫទ័យ កូនកុំស្រដី ដើមប្ដីកំបាំង។
កុំជេរកុំចេញជាខ្លាំង ខ្សត់ខ្សោយខ្ចៅខ្លាំង នាងកុំមើលងាយ។
ល្ងង់ខ្សោយប្រើឱយនិយាយ ណែនាំលេងលាយ ឱយស្រួលវាចា។
ទោះប្ដីស្រដីម្ដេចម្ដា ខេខឹងជេរថា បោះពាក្យទម្ងន់។
ក្រោធក្រេវឆុលឆេវមិនអន់ ជេរថាជន្លេញ ត្បិតទាស់នឹងចិត្ត។
ឱយកូនស្រីស្ងួនខំអត់ ឱយបានរលត់ រលាយកំហឹង។
កុំកូនកាន់ខ្លួនប្រែប្រឹង តតបទៅនឹង អ្នកជាស្វាមី។
ខេខឹងត្រញឹងសម្ដី មិនគិតខ្លួនស្រី ស្រដីទ្រគោះ។
ប្រកែកស្ដីពាក្យគំរោះ គំរាមបញ្ឆោះ បញ្ឆោរឱយខឹង។
រឹងរូសមើលមុខសំឡឹង សំឡក់ទៅរឹង ចចើងចង់ឈ្លោះ។
រឹងឆ្លងឆ្លើយពាក្យបញ្ឆោះ បំបែកជាឈ្លោះ បំបែរពុំទៀង។
ជេរថាឆ្កែឆ្មាបំព្រៀង ដៀលត្មះបញ្ឆៀង បញ្ឈឺចិត្តប្ដី។
បោះបោកប្រទះអ្វីៗ ចាប់ចោលទៅដី បែកបាក់ពុំគិត។
មិនស្រួលទទួលបាត់មាត់ ម្នះម្នេញក្នុងចិត្ត ឱយបានប្ដីចាញ់។
ទើបបានសុខចិត្តជាវិញ ហៅស្រីម្នះម្នេញ អាប់កេរ្តិ៍សធ្លាយ។
ហៃកូនស្រីស្ងួនមាសម្ដាយ ខុសណាស់នាងអាយ កុំធ្វើដូចគេ។
ទោះបីបើប្ដីនាងជេរ នាងចូលទៅឯ ដំណេកគិតសិន។
ចេញមកនាងយកពាក្យទន់ ស្រដីឱយអន់ ស្រាយទោសនោះទៅ។
ទោះបីបើប្ដីប្រដៅ ចូរនាងចាំនៅ ទុកក្នុងអាត្មា។
ពាក្យពេចន៍កុំភ្លេចឡើយណា ក្រែងឆ្គងម្ដេចម្ដា ត្បិតបានផ្ដាំស្រាប់។
ព្រោះឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បង្កើតតែឈ្លោះ។
ឥតសុខអាក្រក់តែឈ្មោះ ឮគេប្រឈ្លោះ មិនចេះហៅល្ហែ។
នេះពុំរាប់ជាស្រីទេ ជាអ្នកប៉ៅឡៃ ចិត្តចោរដកទង។
ឱយមាត់បង្គ្របប្ដីផង ឱយគេស្ដាប់ហោង ថាឯងគ្រាន់បើ។

គឺមោះនាងនោះមិនប្រើ មិនបើកឱយដើរ បញ្ចើឱយទេ។
ទោះបីប្ដីប្រើមាសមេ កុំកូនចំអែរ ចំអៀកមិនទៅ។
ឆ្ងាយជិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឱយប្ដីជេរ។
កុំទៅនៅយូរផ្ទះគេ រវល់ទំនេរ រវៀសមកណា៎។
ហៃកូនខ្លឹមខ្លួមមាតា ជាស្រីនេះណា៎ កម្រណាស់នាង។
មិនថាត្បិតល្អរូបរាង មិនរស់ត្បិតជាង ចេះការទាំងគ្រប់។
មិនបានស្គាល់ទីគោរព ស្គាល់តែឧបទ្រព ទាំងដប់ប្រការ។
ហៅតែនឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង។
មួយល្អរូបសសន្លាង ឥតគេផ្ទឹមខាង ច្បាប់ផងមិនចេះ។
ល្អពិតគំនិតមិនផេះ ទោះខ្លៅក្រងេះ ការសោតសមគួរ។
គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី។
ហៃកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឧបទ្រពចង្រៃ។
កាន់ក្បាលប្ដីហើយរកចៃ មិនបានលើកដៃ បិទទួលសំពះ។
លោកទុកស្មើកុកទំផ្ទះ រង្គំរង្គះ នឹងបង់អស់ទ្រព្យ។
កន្លងជើងប្ដីពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងជើងប្ដី។
ស្មើសត្វលលកខ្មោចខ្មី ហើយប្រាលអប្រិយ កើតព្យាធិ៍រោគា។
ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។
ធ្វេសប្រាណខុសខានមិនរាំង មិនរុញបំបាំង មើលយល់សាយសុស។
ទុកស្មើគេអុជចន្លុះ ឱយចោរចូលចុះ យកទ្រព្យទាំងឡាយ។
ស្រីមួយសើចលេងក្អាកក្អាយ ឮលេចចម្ងាយ រំលងផ្ទះបី។
ស្មើសត្វចចាតបក្សី ចូលភូមិផងក្ដី ចង្រៃក្ដាត់ណា៎។
ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឱយខ្នងទៅប្ដី។
ទុកស្មើពស់ក្រាយអប្រិយ ឡើងផ្ទះឥតបី ឥតបើកគណនា។
ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាសគ្នា ពុំបានវែងឆ្ងាយ។
ស្រីមួយសក់វែងអន្លាយ រំសុសរំសាយ សក់សោតរោ។
នៅមាត់អណ្ដូងមាត់ទ្វារ បីដូចមជ្ឈរា ឆ្មាលាក់ក្រចក។
ចង្រៃឥតបីបើរក រោសំកក មិនចុកសក់ងាយ។
ស្រីមួយដើរទៅទាត់ជាយ ឮលាន់ស្មើរឆ្ងាយ ប្រចពីសន្ទឹក។
សំពត់ដាច់ដាចមិននឹក ដើរឮគគឹក ស្មើសូររន្ទះ។
ញ៉ាំញ៉ើដំណើររលះ ដាក់ជើងលើផ្ទះ គគ្រាំគគ្រេង។

កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញទៅ។
ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក។
ពុំចេរចំណេរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង។
ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឱយអន្តរាយ។
ទោះឆីចំណីនូវបាយ លបលូកកកាយ ពមពុំសណ្ដាប់។
កូនអើយនេះហើយចូរស្ដាប់ ហៅក្តីឧបទ្រព ទាំងដប់ប្រការ។
ឱយចៀសអស់ទាំងនេះណា ឱយរៀនលក្ខណា ទាំងប្រាំពីរផង។
គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា។
មួយមាតុមួយមិត្តភរិយា កាតុភរិយាជា ទាសភរិយាផង។
ទាំងបួនប្រសើរឥតហ្មង គួរឱយចាំចង ទុកក្នុងអង្គា។
រីឯហៅមាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្ដាយ។
ចរិតបីប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឱយប្តី។
បានថ្កើងរុងរឿងព្វល្បី មិនឱយអាប់ប្តី ឱយបានសក្តិយស។
មួយបើប្តីស្លៀកពាក់ចាស់ យកថ្មីឱយផ្លាស់ ចាស់ស្លៀកខ្លួនឯង។
ចេះរៀបរណ្ដាប់តាក់តែង ចំណីផងស្វែង រកមកឱយប្តី។
មួយបើប្តីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្តី រកថ្នាំសង្កូវ។
រកពេទ្យមេមត់នូវគ្រូ គ្រោះយាមគន់គូរ មើលប្តីឱយជា។
រីឯហៅកាតុភរិយា ប្រសើរសោភា ប្រពន្ធស្មើបង។
នោះមានចរិតពីរផង ដូចប្អូននិងបង ចិត្តមូលមួយប្រាណ។
មួយធ្វើឱយប្តីក្សេមក្សាន្ត របស់ប្តីបាន ចេះទុករក្សា។
មួយទោះឮពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្តី។
ពុំត្រូវអាស្រូវអប្រិយ ចេះការគេរប្តី បែរបានជាសុខ។
ទោះបីបើប្តីមានទុក្ខ គិតឱយបានសុខ យកខ្លួនជានា។
មួយសោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ។
បីដូចកលមិត្តសំឡាញ់ មានចិត្តអស់អញ មិនឱយមានហ្មង។
បីដូចកលប្អូននិងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា។
មានចិត្តប្រតិព័ទ្ធមហិមា ត្បិតបានជួយគ្នា មិនឱយមានហ្មង។
មួយមានមារយាទកន្លង ទោះឃើញប្រុសផង មិនល្មៀងចិត្តទៅ។
រីទាសភរិយានោះកូវ ក្នុងមាត្រាត្រូវ ក្រែងប្តីវាយជេរ។
ចរិតប្រាបីប្រការខ្មី មួយចិត្តខ្លាចប្តី ក្រែងប្តីវាយជេរ។
ប្រុងចិត្តការគិតខ្មាសគេ មិនឱយប្តីជេរ បន្ទោសខ្លួនបាន។

ទោះប្ដីខឹងក្រៃប៉ុន្មាន មិនចេះហៅហាន ឆ្លើយឈ្លោះតមាត់។
មួយទោះប្ដីនោះកាចក្ដាត់ ខឹងដល់វាយវាត់ ជេរចោរដកទង។
មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង ក្រែងពួកេរឆ្ងាយ។
មួយចេះប្រដាប់រៀបបាយ ប្ដីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ។
អត់ចាំទំរាំប្ដីមក ជួបជុំទើបយក បរិភោគផងគ្នា។
នេះឯងហៅទាសភរិយា សម្ដេចភគវា ទេសនាប្រោសប្រាប់។
បើអស់ស្រីណាបានស្ដាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ។
លុះអស់អាយុក្សិណក្ស័យ បានទៅកើតឰ តុសិតសួគ៌នាយ។
នឹងបានក្បេមក្សាន្តពណ្ណរាយ សេពសុខសប្បាយ និរទុក្ខកយា។
រីឯប្រពន្ធពុំជា ពេជ្ឍឃាតភរិយា ចរិតមានបួន។
កុំឱយយកទុកក្នុងខ្លួន ឱយចៀសចេញជួន កើតកម្មវេរា។
មួយចិត្តគំនិតចងជា ឆ្លាស់ឆ្លើយបំពារ បំពានឱយប្ដី។
ប្រទូលរឹងរូសខ្វូវខ្វី មិនចេះចាញ់ប្ដី ថាឯងគ្រាន់បើ។
ឆ្លើយឆ្លងសូរសងបណ្ដើរ ចង់ឈ្លោះឱយស្មើ ឱយល់សប្ដីវិញ។
មួយមិនចង់ធ្វើបំពេញ បង្គាប់ប្ដីវិញ ឱយថ្កើងខ្លួនឯង។
អាងចេះដៀលតិះពុំក្រែង ឱយប្ដីស្ដាប់ឯង ដោយចិត្តអន្ធពាល។
មួយមានចិត្តនោះស្រើបស្រាយ ចង់ត្រេកត្រអាល ចោរពេញមុខប្ដី។
មួយចិត្តទ្រឹស្ដទ្រុស្តអប្រិយ ចង់សម្លាប់ប្ដី ស្រឡាញ់ប្រុសទៀត។
គិតកាប់សម្លាប់បង់ម្សៀត នឹងយកប្រុសទៀត ធ្វើប្ដីមរណា។
រីឯសត្រូវភរិយា ចរិតពុំជា ប្រាំពីរប្រការ។
មួយមិនខ្លាចប្ដីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត។
មួយទ្រឹងទ្រមឹងស្ងៀមស្ងាត់ ប្ដីសួរបីម៉ាត់ ពុំស្រដីផង។
មួយប្ដីស្រដីគន្លង ប្រដៅច្បាប់ផង ពុំចូលចិត្តស្ដាប់។
មួយមិនចង់ឱយប្ដីគាប់ មិនចង់ប្រដាប់ ឱយប្ដីថ្កុំថ្កើង។
មួយទោះនឹងស្រដីឡើង ពាក្យធំចចើង ចចេសនឹងប្ដី។
មួយទោះប្ដីលោះខ្ញុំស្រី វាបម្រើប្ដី មិនឱយអាក់អាន់។
ឃើញគាប់រីងស្អប់ខ្នាញ់គ្នាន់ ក្នុងចិត្តប្រចណ្ឌ ជេរថានាយអាយ។
មួយត្បិតប្ដីមានសហាយ ហួរហែកសុសសាយ ឱយប្ដីអាស្រូវ។
រីចោរភរិយានោះកូវ ចរិតពុំត្រូវ មានបីប្រការ។
មួយចង់ចាយទ្រព្យប្ដីណា ឱយខូចអសារ មិនគង់ជាល្អ។
មួយប្ដីឃ្មាតខ្មីខំរក៍ របស់បានមក៍ មិនថែទាំទុក។

លួចឱយទៅម្ដាយឪពុក ប្ដីសួររកមុខ មិនប្រាប់ឡើយណា។
មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់។
ដេកលេងចំខែងអស់កល លុះប្ដីគេយល់ ពុតធ្វើជាឈឺ។
ទទូរដេកថ្ងូរហ៊ឺៗ ប្ដីហៅមិនឮ ពុតចង់តែស្លាប់។
នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ។
លុះអស់អាយុក្ស័បក្លាយ ធ្លាក់ទៅអបាយ ទាំងបួនចំពូក។
តែងនឹងរងទុក្ខរងសោក រំដោះរួចមក កើតជាមនុស្សខ្វើយ។
ហេតុអកុសលនេះហើយ ត្បិតខ្លួនឥតត្រើយ ធ្វើខុសគន្លង។
ខុសវត្តប្រតិបត្តិឆ្គាំឆ្គង មិនរៀងមិនរង ខុសនឹងច្បាប់ស្រី។
មាក់ងាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌លោកថា។
មាក់ងាយមួយនោះឯងណា ត្បិតប្ដីពិការ មិនបានមួនមាំ។
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះមេមត់។
មើលប្ដីឱយជាឆាប់ឆុត ខឹងវិញមិនអត់ បន់ឱយប្ដីស្លាប់។
មាក់ងាយមួយប្ដីខ្សត់ទ្រព្យ គ្មានកេរ្ដិ៍កោះគាប់ ស្មើនឹងអាត្មា។
ដៀលត្មះថាច្រាសដោយសារ ព្រោះខ្ជិលធ្វើការ ទើបគ្មានរបស់។
មាក់ងាយត្បិតប្ដីអ័ប្បយស ឯងត្រកូលខ្ពស់ ពូជពង្សពុំស្មើ។
ឆ្មើងខ្លួនឱយប្ដីបម្រើ ឈ្លោះឡើងហើយដើរ ដៀលត្មះពូជពង្ស។
មាក់ងាយមួយត្បិតប្ដីល្ងង់ ខ្លៅខ្លួនទ្រមង់ ទ្រមក់យឺតយូរ។
ដៀលត្មះពុំចេះអាសូរ សម្ដីខ្មោះខ្មូរ មិនក្រែងប៉ុនសក់។
មាក់ងាយមួយប្ដីអាក្រក់ សាច់ខ្មៅប៉ប៉ក់ មុខអុតស៊ីសុស។
កន្ទ្រលរោងរលក្រអុះ សក់ស្កាញស្កូវសុស ពោះធំប៉ុនពាង។
ខ្លួនឯងចិញ្ចៀងរូបរាង ខ្លួនសល្អជាង ថាប្ដីមិនសម។
មាក់ងាយមួយប្ដីមិនខំ ធ្វើការលេលំ ឡែឡដើរលេង។
ឆ្លៀតឆ្លើយបោះពាក្យគគ្រេង ឈ្លោះជេរមិនឈ្វេង គិតខុសមាត្រា។
មាក់ងាយមួយប្ដីផឹកស្រា ស្រវឹងចោលការ ដើរលេងតែតោ។
ពាក្យក្អេងរាំច្រៀងឡោៗ ឱយឆ្កែព្រុសឆោ ផ្អើលភ្ញាក់កូនចៅ។
ឮមាត់ប្ដីហើយខឹងក្ដៅ ប្រទេចជេរទៅ តាមដោយចិត្តខ្នាញ់។
មាក់ងាយមួយទៀតនោះមិញ ត្បិតប្ដីស្រឡាញ់ លលូកប្រឡែង។
មួលបិចចាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តជេរវិញ។
ត្បិតតែយល់គេស្រឡាញ់ ស្រដីផងមិញ គំរោះគំរើយ។
ធ្វើខ្នាញ់បែរចេញព្រងើយ គេនឹងកន្តើយ ក្និចក្នក់មាយា។

ពុំបានក្បែមក្សាន្តនឹងគ្នា	មាក់ងាយនេះជា	គម្រប់ប្រាំបី។
កូនអើយនេះហើយច្បាប់ស្រី	ឱយកូនពិសី	រករៀនរក្សា។
យកទុកក្នុងអង្គអាត្មា	ប្រសើរក្តាត់ណា	កើតសុខសួស្តី។
ប្រសើរទាំងនាលោកិយ	ទោះបរលោកក្តី	សឹងលុះប្រាថ្នា។
២១៥. ទោះចិត្តគន់គិតសទ្ធា	ជាពុទ្ធមាតា	សឹងបានបរិបូណ៌។
ដូចចិត្តឆាប់ឆុតពុំយូរ	កបកើតសម្បូរ	សម្បត្តិទ្រព្យផង។
កើតយសខ្ពង់ខ្ពស់កន្លង	យើនយូរឥតហ្មង	ដូចក្តីប្រាថ្នា។
ច្បាប់នេះឧត្តមថ្លៃថ្លា	ទោះស្រីឯណា	ឮហើយមានភ័ព្វ។
ជាល្អកម្របានស្តាប់	ស្តាប់ហើយចូរចាប់	ចូរចាំគ្រប់គ្នា។
២២០. បានដល់មគ្គផលសួគ៌ា	ប្រសើរសោភា	ចូលចាំកុំភ្លេច។
ចរចាអស់អាថ៌ពាក្យពេចន៍	ពាក្យពិតកាព្យកិច្ច	បរិបូណ៌ប្រពៃ។
ប្រាជ្ញប្រើរឹងនាមនៃ	ខ្ញុំឈ្មោះ **ម៉ឺន-ម៉ៃ**	មែនមានសទ្ធា។
មានចិត្តក្ខួចគិតកាព្យា	កបកើតជ្រះថ្លា	ត្រេកត្រង់កុសល។
សទ្ធាប្រាថ្នាមគ្គផល	ផុលផុសយោបល់	លេចលើកទុកនៅ។
២២៥. ទោះបីសេចក្តីខុសត្រូវ	សូមទានតម្រូវ	តម្រង់ឱយផង។
កុំត្មះតិះដៀលឡើយហោង	សូមសាងផលផង	ទុកតសាសនា។
សម្រាប់ជាច្បាប់មាត្រា	សូរេចបការា	បរិបូណ៌ចែងចប់។

❀ ❀ ❀

# ច្បាប់ប្រុស

## បណ្ឌិត **ម៉ែ** រៀបរៀង

### បទព្រហ្មគីតិ

១. នេះបទព្រហ្មគីតិ ពីព្រេព្រឹទ្ធទុកទូន្មាន
ថែងចងជានិទាន ទុកគ្រាន់មើលជាច្បាបថ្មី។
ឱយអស់កូនចៅក្រោយ ស្តាប់កុំឱយភ្លេចស្មារតី
ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់អាត្មា។
ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសក្រណាស់ណា
ក្រគិតក្នុងចិន្តា ឱយបានដឹងសមនិងគួរ។
នឹងអស់ញាតិសន្តាន សោះគេមានពាក្យថាជួ
កុំឆ្មើងកុំតែងតួ ធ្វើកំប៉ោងកុំពាក្យធំ។
៥. នឹងដើរដូចភុជង្គ ឱយឱនអង្គអាចបារម្ភ
ឱយត្រូវនឹងច្បាប់ក្រម គួរប្រតិបត្តិកុំឱយឆ្គង។
រៀបបទរៀនបាទចាស កុំប្រទ្បាសលើរៀមច្បង
ស្រដីនឹងអ្នកផង ពាក្យឱយគួរកុំងងរឹ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱយអប្រិយ ស្រដីថាកូនអត់ពូជ។
ចាស់ទុំមិនប្រដៅ ដេរកូនចៅទើបវាខូច
គេថាកូនឥតពូជ មិនដឹងច្បាប់និងចាស់ទុំ។
គេដៀលដល់ម៉ែឪ គេរ្អីអាស្រូវស្អុយហ៊ុំ
គេស្តីដើមដៀវជុំ ជំនៀលនោះដល់មកចាស់។
១០. កុំកាចកុំស្លូតពេក កុំចំអៀករៀនរហ័ស
កុំខ្លាចកុំហ៊ានណាស់ ឱយរំពឹងរំពៃគ្រប់។
ទោះដេកឱយរហ័ស ភ្លាក់មុនចាស់ដោះឡើងលុប

មុខមាត់មើលឱយគ្រប់ ទ្រព្យរបស់សឹមដេកវិញ។
ស្លាម្លូស៊ីឱយច្រៀក កុំបីបៀកទាំងមូលមិញ
តូចធំឱយច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ។
ដេកយប់កុំដេកយូរ ហើយទទូរដូចគេងាប់
សម្លត់ស្លៀកឱយខ្ជាប់ កុំឱយអាក្រាតក្រៅខ្លួន។
នឹងដេកកុំទ្រមក់ ឱយលង់លក់ក្រៅពីក្បួន
បើភ្ញាក់ឱយដឹងខ្លួន ទ្បើងអង្គុយកុំមាត់ខ្លាំង។
១៥. ប្រែប្រាណប្រុងវិញ្ញាណ ខ្លាចក្រែងមានចោរចិត្តខ្លាំង
ប្រួញប្រាណប្របជញ្ជាំង ជញ្ជូនទ្រព្យលួចយកចេញ។
បើឥតមោះមន្ទិល កុំឱយខ្ជិលដេកទៅវិញ
ភ្ញាក់ហើយឱយក្រោកចេញ រកជក់ថ្នាំស៊ីម្លូស្លា។
ទោះពេលពន់ព្រលប់ គន់ឱយគ្រប់ទ្រព្យនានា
កាំបិតខាងអាត្មា ឱយសិតទឹកដាក់ចុងជើង។
ប្រអប់ដាក់ទឹមស្មា ថ្វាយទេព្តារក្សាយើង
ហើយឱយបំពក់ភ្លើង នៅក្រានក្រៅកុំឱយដាច់។
កុំឱយអស់រលីង រលត់ធេងហើយថាភ្លេច
សព្វថ្ងៃមើលកុំដាច់ កុំដើរយកពីផ្ទះគេ។
២០. ថែទាំមើលជើងក្រាន ឱយឧសមានកុំទំនេរ
បង្កាត់បង្កើនកេរ្តិ៍ កុំប្រហែសឱយសូន្យសុង។
ប្រយ័ត្នក្រែងក្រងាយ ពុំសប្បាយឈឺពោះពុង
បង្កាត់កំដៅអង្គ អុជបំភ្លឺមើលនេះនោះ។
មានកាលយប់ងងឹត ភ្លេចមិនគិតជូនកូនជុះ
គ្មានភ្លើងអុជចន្លុះ ក្រានរលុះរលត់ធេង។
រត់រកភ្លើងសស្រាក់ ព្រួយលំបាកតែខ្លួនឯង
ហេតុខ្ជិលពុំគិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ។
ហើយឱយថែទាំងទឹក ទោះយប់ព្រឹកកុំគិតងាយ

ដងដាក់ក្អមរាត់រាយ សព្វពួចពាងអាងអុងធំ។
២៥. កុំអោយស្ងួតក្អមផេង អស់រលីងពីពាងធំ
គ្មានសោះនោះមិនសម ជួនក្រែងក្រងាយយប់ថ្ងៃ។
ទោះដោះរទៅឆ្ងាយជិត កាន់កាំបិតកំដរដៃ
ក្រែងមានមែកឈើព្រៃ កាប់កាន់មកធ្វើជាឱស។
ជួនកាលក្រែងបន្លា មុតអាត្មាគ្រាន់ចាក់ជួស
ជាគ្រឿងគ្រប់មិនខុស ការសត្រូវទោះឆ្មាឆ្កែ។
ដើរព្រៃឱយមើលលើ ឃើញស្លឹកឈើជាបន្លែ
កាប់កាន់កុំដៃទេ អង្គុយគន់មើលឆ្វេងស្តាំ។
ក្រែងមានឈើព្រៃងាប់ គួរកាច់កាប់យកជាថ្នាំ
ផ្ញើក្រានគ្រាន់ដណ្តាំ បាយបានឆ្អិនឆាប់ដូចចិត្ត។
៣០. សោះស្រីស្រដីបាន បើឧសមានមិនព្រួយគិត
សព្វថ្ងៃប្រុងគំនិត ថែទាំទើបគង់របស់។
មាសប្រាក់ស្រូវអង្ករ ទុកឱយល្អកុំសប្បុរស
សំចៃកុំឱយអស់ មើលថែជូនខ្លួនឯងណា។
សូវស្ដួចកុំឱយដាច់ បើវាតិចឱយឧស្សាហ៍
រិះរកផ្សំទៀតណា ឱយបានច្រើនក្រវើនទុក។
នឹងចាយឱយគិតក្រោយ ទើនឹងឱយៗមើលមុខ
កុំឱយស៊ុកគ្រលុក ទោះនឹងទុកឱយចំណាំ។
រដូវធ្វើចំការ ឱយឧស្សាហ៍គ្រឿងគ្រាប់ដាំ
ស្លឹកគ្រៃខ្ទីត្រប់ត្រុំ ត្រាវត្រសក់សព្វបន្លែ។
៣៥. កុំខ្ជិលកុំច្រអូស ទៅងងូលរត់សុំគេ
គេមិនឱយឯងទេ តែគឺមោះព្រោះខ្ជិលដាំ។
ទោះធ្វើស្រែចំការ ឱយឧស្សាហ៍មើលថែទាំង
កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅវល្លិផង។
កុំឱយបង់កម្លាំង ទោះខែប្រាំងប្រឱយដង
ទឹកទៅស្រោចស្រង់ផង ឱយលូតលាស់មានផ្កាផ្លែ។

ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំគ្នួញគ្នែរ
ខ្លាំងខ្សោយកុំឱយល្វែ ខ្លាចតែនឿយហើយមិនធ្វើ។
ជាងយប់បិតឫស្សី ត្បាញជាល្មីតៅកញ្ចើ
កុំឱយស្រីស្តីលើ ឥតអំពើធ្វើលេងទៅ។
៤០. កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ
ខាងផ្ទះខាងលំនៅ ឱយវាលកាលកើតសុខា។
ឱយមានក្តីបារម្ភ ធ្វើស្រែកុំចោលចំការ
ដឹងដៃកកាំបិតព្រា ទុកឱយកុំឱយបាត់។
ដេកយប់ឱយរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន
ត្រចៀកចាំកុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន។
ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថៃថ្នូន
ទោះទ្រព្យរបស់ខ្លួន ឱយសួរកូនសួរប្រពន្ធ។
កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា។
៤៥. ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ
ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត។
ឱយប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា។
បើទៅជាមានភ័ព្វ ប្រសើរគាប់នោះឥតថា
ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុកឥតគេសម។
ទោះដើរមានដំណឹង ឱយរំពឹងគិតបារម្ភ
នឹងដើរៗឱយសម យប់ព្រលប់ឱយមាត់ក។
កុំសៀមកុំស្វាត់ពួន លបលាក់ខ្លួនខ្លាចមិនល្អ
ឱយមើលឱយមាត់ក ដើរឱយស្មោះសោះគេថា។
៥០. ទោះខ្លួនជាប៉ុន្នាន ពាក្យសន្តានវែងមុសា
គេម៉ែមកអាគ្នា តាមដំណឹងដំណើរខុស។
កូនអើយបាកុំធ្លោយ កុំធ្លាប់ឱយអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស ឱយរករៀនច្បាប់មាត្រា។
លោកថាហៅឆ្គួតបី មួយឆ្គួតស្រីមួយឆ្គួតស្រា
មួយឆ្គួតល្បែងពាលា លេងបៀរប៉ោធ្មកំតាត់។

ទាក់មាន់ទាក់ទទា ជល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត។
ធម្មតាប៉ោនិងបៀរ មិនដែលខ្មែរណានឹងកើត
មិនព្ទមានកំណើត មានតែលិចលង់ខ្លួនទេ។
៥៥. ជួនកាលគេចាញ់ឯង រៀងរាល់ល្បែងតែងនឹងវេ
មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន។
ពីព្រឹកស្លៀកហូលជរ ល្ងាចស្លៀកសខ្វះចងក្បិន
ពីព្រឹកត្បុកក្បាលចិន ល្ងាចមិនទាន់ចិនដាក់ខ្នោះ។
ជួនកាលវាចងជើង ព្យួរខ្ពស់ឡើងក្បាលដាំចុះ
ភ្នែកស្លឹងតឹងក្រញ៉ុះ វាទារក្រាក់ឱយបានឆាប់។
មើលមុខល្អតិចអ្វី មិនខ្មាសស្រីផ្សារឈរស្តាប់
មុខមិញដូចគេស្លាប់ មាត់ស្ងួញស្វាញពេបដូចក្មេង។
ស្រែកថ្ងូរអេះអួយអើយ អាចិកអើយអាណិតលែង
អញរកប្រាក់ឱយឯង ឱយអាចិកស្អែកនេះបាន។
៦០. ចិនព្ទព្រមស្រាយមក បណ្តើររកប្រាក់សន្តាន
តឹងទារទាល់តែបាន ទ្រព្យឱយទៅទើបវាលែង។
អ្នកអាយអ្នកអើយកុំ គួរបារម្ភរាល់តែល្បែង
កុំលកុំលូកលេង គួរឱយវាងឱយវៀរសោះ។
កុំឈរកុំឈប់ជិត ក្រែងមិនអត់បងកេរ្តិ៍កោះ
កុំល្បងល្បែងនោះសោះ គួរឱយដោះឱយដើរចេញ។
ច្បាប់នេះចាំរាល់ខ្លួន ទោះបងប្អូនមិនសំឡាញ់
ពឹងខ្លួនឯងឱយចេញ ធានាទ្រព្យគេយកទៅ។
ឯទ្រព្យបានទៅវា ឯងធានាស្រាប់តែនៅ
វាបានទ្រព្យយកទៅ ខ្លួនឯងនៅធានាស្រាប់។
៦៥. ដល់គេមកតឹងទារ អ្នកធានាក៏បានឆាប់
មិនបានគេប្រចាប់ ទៅជាខ្ញុំព្រោះធានា។
ទោះបងប្អូនធុរៈ ក្រជំពាក់គេតឹងទារ
បើមានទ្រព្យជួយជា កុំធានាណ៎ាអ្នកអាយ។
កូនអើយចូរបាចាំ ឪពុកផ្តាំកុំបីណាយ
ប្រយ័ត្នរាល់រូបកាយ កុំឱយភ្លេចពាក្យនេះណ៎ា។

មួយទៀតហៅឆ្កួតស្រី　គួរកុំបីសេពកាមា
វាតែងទាញអាត្មា　នាំវង្វេងភ្លេចបាបបុណ្យ។
ភ្លេចសីលទានសូន្យសោះ　ភ្លេចឃ្មាងខ្មោះដល់ជីពជន្ម
ភ្លេចទោសភ្លេចទាំងគុណ　ភ្លេចទាំងការកាន់រសាយ។
៧០. បង្កើតតែទោសទុក្ខ　បើបានសុខសឹងប្រែក្លាយ
បង្កើតក្តៅក្រហាយ　ឱយទាស់ទែងខឹងនឹងគ្នា។
ចងទោសគុំគង្គួន　មិនគិតខ្លួនខ្លាចមរណា
មានកាលក្មួយនិងមា　គុំធ្វើគ្នាឱយសោះសូន្យ។
បង្កើតតែចិត្តធំ　ចៅគំនុំនឹងជីដូន
ឯបងខឹងនឹងប្អូន　ម្តាយនិងកូនគុំធ្វើគ្នា។
រីខ្ញុំគុំកាប់ម្ចាស់　ឱយក្តៅណាស់ក្នុងអង្គា
កើតទោសខឹងនឹងគ្នា　ជាគំនុំពុំត្រាស្បើយ។
មានកាលគេដាក់ឃ្នាង　វាមិនរាងចាលចិត្តឡើយ
លក់ព្នៃខ្ញុំគេហើយ　មិនខ្លាចស្លាប់ដល់អាត្មា។
៧៥. គេកាប់ដោតទាំងក្បាល　មិនចេះចោលចិត្តឡើយណា
ភ្លេចខ្លួនសូន្យសោះសា　នឹកតែត្រង់សេពសប្បាយ។
រីឯកាមកិលេស　កុំប្រហែសគួរឱយណាយ
ស្អិតណាស់ណាអ្នកអាយ　អ្នកអើយកុំគិតសង្ស័យ។
នេះឯងហៅឆ្កួតស្រី　គួរកុំបីឱយអាល័យ
ចូរចងចាំសព្វថ្ងៃ　ទុកទូន្មានអង្គអាល័យ
អ្នកប្រាជ្ញលោកនិទាន　ទុកទូន្មានរាល់រូបា
មួយហៅឆ្កួតសុរា　នោះកុំផឹកវាស្រវឹង។
វានាំភ្លេចវិញ្ញាណ　ភ្លេចសីលទានសោះសូន្យឈឹង
ផឹកហើយមិនដែលនឹង　នាំចិត្តនោះឱយធំក្រៃ។
៨០. ឯខ្លួនឯងតូចទេ　មើលទៅគេប៉ុនមេដៃ
កម្លាំងឯងស្មើចៃ　មិនកោតគេតិចឡើយណា។
ក្អេងក្អាងពាក្យកក្អែ　អួតពូកែបទបានស្រា
មិនមានខ្លាចនរណា　ស្រដីកោងរកកលឈ្លោះ។
បញ្ជោរបញ្ចៀសផ្កាស　ជេរវាងវាសមិនចំឈ្មោះ
នាំហេតុតែខាងឈ្លោះ　ឆ្លើយឆ្លងពាក្យឱយបានទាក់។
ប្រពន្ធឃើញឃាត់ទៅ　ប្តីមិនត្រូវថាកុំអ្នក

ឯងនឹងលោភវាយធាក់ ដោយចិត្តធំបទបានស្រា។
មានកាលជួនស្រវឹង ពុំមានដឹងខ្លួនឡើយណ៎ា
ដើរដួលដេកផ្កាប់ផ្ងារ ស្រាតសំពត់អស់ពុំដឹង។
៨៥. គេឃើញអស់ខ្មាសខ្ញុំ ក្មេងជៀវជុំសើចទ្រហឹង
ដេកដូចគេស្លាប់ឈឹង ក្អែរក្អួតពាសពេញទាំងខ្លួន។
កំណើតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន
ដឹងហើយស្រវឹងប្អូន ខ្លួនខ្សត់ទេអួតថាមាន។
អ្នកស្លូតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន
ខុសត្រូវទៅបំពាន បំពុលខ្លួនឱយបានបាន។
នេះឯងហៅវត្តស្រា ក្នុងធម៌ថាពៀវដរាប
អ្នកណាផឹកហើយបាប បង់កិត្តិយសពុំសួស្តី។
គួរកុំសេពសុរា នាំអាត្មាឱយអប្រិយ
នឹងធ្លាក់ទៅអវិចី នរករងទុក្ខវេទនា។
៩០. ហែអស់ជនទាំងឡាយ កុំវាយមាយក្នុងអង្គា
ចូរស្ដាប់ច្បាប់នេះណា ទុកទូន្មានខ្លួនសព្វថ្ងៃ។
នេះឯងហៅវត្តបី លោកស្រដីក្នុងធម៌ថ្លៃ
បើអ្នកណាមួយនៃ នឹងប្រាថ្នាដោយចំណង់។
លោកចងជាឧបមា ឱយអ្នកណាមួយផ្ចិតផ្ចង់
យកដែកដុលបោះបង់ ក្នុងភ្លើងក្រានឆេះច្រាលឆ្អៅ។
បើកាន់ដែកដែលដុត នោះមិនមុតមិនមានក្ដៅ
កាន់បាននោះទើបហៅ ចិត្តមុតមែនពិតគិតប្រាណ។
នោះទើបលោកឱយធ្វើ នូវអំពើទាំងបីបាន
ដោយធម៌ពីបុរាណ លោកឧបមាដូច្នេះណា។
៩៥. ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា
ប្រដៅខ្ញុំនេះណ៎ា សព្វសេចក្ដីដូច្នេះនៃ។
កិច្ចកាព្យរាយរៀបរោះ ខ្ញុំនាមឈ្មោះបណ្ឌិតមៃ
គិតចងជាសេចក្ដី ប្រដៅជនចប់ម្ល៉េះហោង។

# ច្បាប់ទូន្មានខ្លួន

## បទព្រហ្មគីតិ

១. មនុស្សកាចកុំប្រសព្វ    កុំទៅភប់នឹងចោរក្បួយ
គេចាប់ចងទៅក្រោយ    វាយបណ្ដើរយល់អប្រិយ។
កុំគប់នឹងខ្ញុំគេ    កុំប៉ោឡៃខ្វល់នឹងស្រី
កុំជួញនឹងមន្ត្រី    នឹងខាតទុកធនឯងហោង។
កូនអើយឪពុកបា    នឹងឧបមាមួយទៀតផ្គង
បានស្ដាប់ត្រាប់ត្រងរង    ទុកទូន្មានអង្គឥន្ទ្រិយ។
គេដើរកុំអាលបាញ់    បើស្រឡាញ់កុំឱយខ្ចី
សូវឱយស្មោះទៅនៃ    នៅគង់ជាភ្ញាយីនយូរ។
៥. សូវចូលកុំឱយចេញ    សូវឱយទិញកុំឱយដូរ
សាច់ញាតិឱយប្រមូល    កុំស្រដីពាក្យសល់វ៉ល់។
មនុស្សកាច់កុំបីប្រើ    ការក្រធ្វើកុំឱយសល់
ចែកទានកុំឱយយល់    ពាក្យបញ្ឆោះកុំឱយមាន។
ពាក្យខុសកុំឱយស្ដាប់    សេចក្ដីគាប់ឱយគិតធ្យាន
អំពើបាបកុំឱយមាន    សីលនិងទានឱយរិះគិត។
សីលសោតគួររក្សា    ខំប្រាថ្នាឱយបានជិត
ពិបាកឱយគន់គិត    រកគំនិតគិតឱយដល់។
ស្អប់គេកុំអាលថា    មានប្រាជ្ញាឱយចេះយល់
ពាក្យភូតស្ដាប់គួរឆ្ងល់    មានកង្វល់កុំអាលចែង។
១០. ពាក្យក្រកុំអាលប្រាប់    ពាក្យឥតសព្ទកុំអាលថ្លែង
ពាក្យពិតកុំឱយចែង    ពាក្យពិតស្លែងពុំគួរលាក់។
គេប្រាប់កុំអាលក្រោធ    គេបញ្ឆោតកុំអាលភ្ញាក់
សឹកដេញកុំអាលបាក់    គ្នាជំពាក់ប្រើដោះសា។
គេរត់កុំអាលដេញ    គេលើកចេញកុំអាលថា
សឹកដល់កុំអាលឆ្លា    ឰវាចាកុំអាលយក។
គេប្រើកុំអាលទៅ    គេឱយហៅកុំអាលមក
គេឱយកុំអាលយក    គេសង្ស័យកុំអាលថយ។
ខ្លួនតូចកុំខំពារ    ខ្លួនអ្នកជាកុំគិតឆ្ងាយ

ឱយគិតក្រែងក្រក្រោយ ខ្លួនខ្សត់ខ្សោយឱយបារម្ភ។
១៥. ទំនៀមទំនឹកព្រេង ច្បាប់ថ្លាថ្លែងដោយត្រឹត្យក្រម
ពាក្យនេះជាឧត្តម ចូរបាខំៗត្រង់ត្រាប់។
សង្ខាតរកស៊ីចុក ជួញលលក់ទិញតាមច្បាប់
ខ្សត់គ្មានឃ្លានស៊ូស្លាប់ កុំខុសច្បាប់ព្រះធម្មា។
មានទ្រព្យត្បិតសំណាង ជាតិមុនសាងទានសីលា
ទើបកើតជាតិនេះណា មានទ្រព្យធនត្បិតទានគេ។
បើខ្លួនមានស័ក្ដិបុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍
ធ្វើចិត្តឱយត្រង់ត្រែ ជាតិទៅមុខនឹងបានទៀត។
ស៊ីបានៗនឹងខំ លោកវាយដំគេបៀនបៀត
បំបាត់ទ្រព្យគេឆ្លៀត ខុសច្បាប់ផងមិនទេឡើយ។
២០. ល្អតែនៅលោកិយ លុះដល់ក្ស័យជីវិតហើយ
ទល់ទុក្ខពុំដែលស្បើយ រូបវេទរងកម្មវេទាន។
ព្រះទ្រង់ទេសនាមក គួរតែយកទុកសិរសា
មនុស្សសត្វផងក្ដីណា ពុំដែលវៀរពីក្ដីស្លាប់។
គួរតែសាងសីលទាន នោះនឹងបានបុណ្យលាងបាប
រក្សាសីលដរាប នោះប្រសើរពេកកូនអើយ។
អស់ទ្រព្យសម្បត្តិនៅ មិនបានទៅតាមខ្លួនឡើយ
មានតែសីលទានហើយ ទៅកំដរបរលោកនាយ។
អស់ទាំងគ្រឿងរបស់ ខ្ញុំស្រីប្រុសផងទាំងឡាយ
សឹងខានចោលនៅអាយ ជារបស់គេរស់នៅ។
២៥. គួរដឹងរិះគិតឲ្យាន គួរឱយទានធ្វើបុណ្យទៅ
ទាន់ខ្លួនជីវិតនៅ នោះប្រសើរក្រៃពេកពន់។
បើបាធ្វើតែបាប មិនសុភាពចិត្តកាចលន់
ធ្វើបាបមិនធ្វើបុណ្យ បានសងគុណម្ដាយឪពុក
ឱយទានចាំសីលសុខ នោះនឹងបានឋានសួគ៌។
ខ្លួនធំខំរកស៊ី ចាស់ព្រឹទ្ធីគួរអនិច្ចា
កើតជាមនុស្សនេះណា មានវេរាពុំដែលរួច។
មួយសោតកុំស្នេហ៍ស្និទ្ធ កុំមានចិត្តគិតគិតកាន់កួច
ភរិយាគេកុំលួច នៅលោកិយក្ដីនិន្ទា។
៣០. ដល់ខ្លួនលែងជាតិនោះ នឹងចូលចុះនរកណា

នឹងឡើងដើមរកា- ដែកនោះធំៗខ្ពស់ក្រៃ។
យមបាលរត់ទៅជ្រោម កាន់គ្រឿងចោមចាក់ទីទៃ
ក្អែកត្មាតទង់ជើងដៃ ចចឹកស៊ីជាអាហារ។
មានខ្លួននោះដាចដាច់ អស់ទាំងសាច់ឈឺខ្លោចផ្សារ
វាត្រូវនឹងបន្លា សឹងដែកជាមុតធ្លាយធ្លុះ។
ហើយធ្លាក់ពីបន្លា ដើមរកាដែកធំនោះ
ធ្លាក់ចុះក្នុងទឹកខ្ទុះ ប្រៃផ្សាក្តៅឥតសម្រាន្ត។
ហើយហែលក្នុងទឹកនោះ ស្លាប់ហើយរស់លំបាកប្រាណ
ពីរពាន់ឆ្នាំទើបបាន រួចមកកើតជាមនុស្សា។
៣៥. រួចនោះបានមកកើត យកកំណើតមនុស្សនេះណា
ហេតុកម្មពៀរវេរា កើតជាស្រីប្រាំរយជាតិ។
រួចនោះជាខ្វែខ្វើយ កូនចៅអើយកុំប្រមាទ
ភរិយាគេមិនឃ្លាត ពីនរកនោះឡើយណា។
មួយសោតឪពុកផ្តាំ ចូរបាចាំកុំផឹកស្រា
វានាំចិត្តពាលា ពាលោលន់ពន់ពេកក្រៃ។
ផឹកស្រាជាអ្នកកាច ពុំក្រែងខ្លាចអ្នកដទៃ
វានាំបាត់ស្មារតី នឹងរកស៊ីបាត់ប្រាជ្ញា។
នៅនាលោកិយហោង អស់អ្នកផងគេនិន្ទា
លុះខ្លួនជួនមរណា ទៅនរករងទុក្ខនៅ។
៤០. នៅតែរងវិបាក ខ្លួនរលាកនឹងដែកក្តៅ
អស់ថ្លើមប្រមាត់នៅ ក្នុងពុងពោះឈឺពន្លឹក។
ដែកក្តៅឆេះជាភ្លើង ផ្សែងផ្សព្វឡើងឮគគឹក
យមបាលសោតបំផឹក ទឹកទង់ដែកឆេះព្រោងព្រាយ។
ទាក់ទាញផ្តេកផ្តួល នឹងបង្គោលដែកទាំងឡាយ
មាត់នោះឆេះព្រោងព្រាយ ហេតុបាបបានផឹកសុរា។
ពាក្យនេះមិនថាឯង មានពីព្រេងព្រះទេសនា
អ្នកណាបរទារការ សេពសុរាដូច្នេះនៃ។
គិតគួរគួរឱយចាំ សីលនានាំឱយល្អក្រៃ
រៀនធម៌គម្ពីរថ្លៃ បានរៀបរាបផងនានា។
៤៥. ហៃអស់កូនចៅអើយ ចាំឱយហើយធម៌ទេសនា
អ្នកមិនផឹកសុរា អ្នកនោះបានឋានសួគ៌ហោង។

រកស៊ីគិតពីរក្តី(១) គិតលោកិយបរលោកផង
ក្រែងខ្លួនជួនមកយោង ផលជួយជូនបានសុខា។
ច្បាប់នេះព្រះបន្ទូល គួរតែចូលចិត្តគ្រប់គ្នា
ទូលទុកលើសិរសា កុំបីភ្លេចដល់មួយថ្ងៃ។
ថ្ងៃសីលរកផ្កាភ្ញី ទៀនធូបក្តីផ្សំម្រាមដៃ
ថ្វាត់ថ្វាយព្រះរ័ត្នត្រ័យ កុំបីដាច់ថ្ងៃមួយឡើយ។
អ្នកណាអាចបានស្តាប់ ត្រេកត្រងត្រាប់ធម៌ជាត្រើយ
លុះលែងជាតិទៅហើយ នោះនឹងបានឋានសួគ៌ា។
៥០. ទោះបីបានកើតមក យកកំណើតជាតិនេះណា
ប្រកបដោយប្រាជ្ញា អង្គកាយាល្អប្រិមប្រិយ។
កើតកបទ្រព្យរបស់ ខ្ញុំស្រីប្រុសគោក្របី
មាសប្រាក់ឥតខ្វះអ្វី មានទូកក្តារច្រវាំហោង។
មានកេរ្តិ៍កោះស្រែស្រូវ ចេកអំពៅដូងស្លាផង
នោះច្រើនៗពេកហោង សឹងលើសលន់ពន់ប្រមាណ។
ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាថ៌ឱវាទទាន ជាសូវេចបណ្តាំហោង។
៥៥. ចូររិះចូររៀនយក ជាបន្ទូកចិត្តចាំចង
ស្មើស្ពានចាំចម្លង ទៅដាក់ដល់ថ្នល់និព្វាន។

❁ ✿ ❁

# ច្បាប់កូនចៅ

១. កូនចៅអើយស្តាប់ ឪពុកនឹងប្រាប់ ប្រដៅគ្រប់គ្នា
ចូរចាំចូរចាប់ ជាច្បាប់អាត្មា រួសរងរក្សា
ទីទៃគ្រប់ប្រាណ។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មានផៅសន្តាន
ពុំចេះអាងអួត ប្រកួតរានកាន បំពាក់បំពាន
បំពៅតអួតអង្គ។

ទោះនឹងយាត្រា ទៅទីស្ថានណា ដើរដូចភុជង្គ
សិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំអុតឱនអង្គ
ការកេរអ្នកជា។

រីអ្នកសាមាន្យ ខ្សត់ខ្សោយសន្តាន អាប់ឥតប្រាជ្ញា
ដំណើតអែងអោង កែងកោងហត្ថា ដូចខ្ទួយសោះសា
មែនមានពិសទិច។

៥. បំពោងបំពើត ចំកោងស្ទួយស្នើត ពឹងពិសទ្រនិច
ខ្លួនតូចត្រឡាំង កំឡាំងសោតតិច ពឹងពិសទ្រនិច
ទិចតើប៉ុន្មាន។

ធម្មតាអ្នកជួ ពុំដែលផ្ទឹមតួ នឹងអ្នកជាបាន
ហេតុលោកការកេរ ឥតពីរផ្ទឹមប្រាណ លោកការសន្តាន
សន្តាប់ផៅផង។

កូនចៅអើយចាំ ឪពុកនឹងផ្តាំ ដោយនូវគន្លង
គាថាបាលី គិតពីព្រេងហោង ចូរចេះចាំចង
ទីទៃកុំឆ្ងាយ។

ពាក្យនេះជាច្បាប់ ទុន្នានឱយគាប់ កូនចៅឯក្រោយ
ឪពុកឥតទ្រព្យ អ្វីគាប់ទុកឱយ តែពាក្យនេះដោយ
ព្រះបាលីថា។

លោកថាភ្លើងភ្លឺ មែនពិតមោះឬ ពុំស្មើសុរិយា
លោកថាសូរ្យសែង ភ្លឺចែងវេហាស៍ មោះពុំស្មើនា
ព្រះធម៌ព្រះពុទ្ធ។

១០. ភ្លើងភ្លឺអស់ចិត្ត អស់កាលហើយបាត់ រលាយរលត់
ព្រះសូរ្យភ្លឺឡើង ចុំថ្ងៃងប្រាកដ អាប់អស្តង្គត
ពុំយល់រស្មី។

រីព្រះធម៌ថ្លៃ ភ្លឺហើយភ្លឺក្រៃ នៅនាលោកិយ
ដល់បរលោកនាយ ភ្លឺឆ្ងាយបារមី រុងរឿងរង្សី
ពុំរលត់ឡើយ។

កូនចៅអើយណា ពាក្យមួយលោកថា ស្តរឃ្មុំឯងហើយ
ផ្អែមក្រៃលែងផ្អែម ល្ហឹមល្ហែមជាត្រើយ មោះផ្អែមនោះសើ្បយ
ពុំចាប់ចាំនៅ។

តែពាក្យលោកថា លោកមានមេត្តា ទូន្មានប្រដៅ
នោះផ្អែមក្រៃលែង ស្តរឃ្មុំអំពៅ ចាំចងទុកនៅ
អស់កាលដ៏លង់។

លោកថាល្វាផង សម្បកក្រៅហោង ភ្លឺផ្លេកយល់យង់
រីឯក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង
នោះហោងលោកថា។

១៥. អ្នកមួយចៃចូវ រអែររអូវ វៀចវេបុស្សា
បញ្ចើចបញ្ចើ ពាក្យពើមាយា ដូចកលផ្លែល្វា
ល្អល្អះតែក្រៅ។

មួយដូចខ្នុរណាំង សម្បកស្តោកស្តាំង បន្លាច្រូងនៅ
ឯក្នុងសឹងក្លែប ក្រអែបផ្អែមទៅ ទាល់ក្នុងឥតសៅ
រសសឹងពិសា។

រីកអ្នកមានធម៌ សប្បុរសមានអាថ៌ លោកផ្ទឹមឧបមា
ដូចខ្នុរក្លិនក្លែប ក្រអែបពិសា ក្រៅក្រាស់បន្លា
មោះក្នុងផ្អែមក្រៃ។

មួយសោតលោកថា កន្លង់និងផ្កា ស្ពានឆ្ងាយទីទៃ
ហេតុចិត្តចង់ក្រេប ជញ្ជាបក្លិននៃ ហើរហួសច្រៀវច្រៃ
រសរកបុប្ផា។

ដូចអ្នកមួយមាន ចិត្តនោះចង់បាន ច្បាប់ក្បួនសាស្ត្រា
ស្វះស្វែងរកអ្នក មួយមានប្រាជ្ញា រួសរងឧស្សាហ៍
សង្វាតអាលជ្ជី។

២០. មួយនឹងរុយ រករោមសំអុយ អសោចិ៍អប្រិយ
ដូចមនុស្សអបលក្ខណ៍ ស្វែងស្វះរកក្តី ពុំគិតក្រក្រី
ក្រែងក្រោយឡើយនៃ។

មួយនីក្រមច្បាប់ លោកពុំឱយគ្រាប់ អំពើពុតជ្រៃ
កាលណាដូចដុះ អាប់ចុះអាស្រ័យ ត្រង់ស្ថានណានៃ
អ្នកដើមអន្តរាយ។

មួយនីលោកថា អំពើពុតខ្លាច យល់សាច់ទាំងឡាយ
ចង់ប៉ុន្តែស៊ី ឥតបីរសាយ អស់មនុស្សទាំងឡាយ
កុំគ្រាប់ពុតខ្លា។

កើតជាមនុស្សនេះ ដូចកង់រទេះ វិលត្រូវគ្រប់គ្នា
មានកាលត្រូវគេ ល្បែងអាត្មា ហេតុនេះលោកថា
ប្រើគ្រាប់ពុតកង់។

រីឈើវិស័យ ដុះនៅនាព្រៃ ខ្លះវៀចខ្លះត្រង់
ឯអ្នកនគរ ក្បត្រក្បាន្តទ្រទ្រង់ ខ្លះចិត្តទៀងត្រង់
ខ្លះខ្លៅសាមាន្យ។

២៥. ពពួកសត្វផង សាហាវយល់ឃ្នង គេអាចញាំងបាន
ត្រង់មនុស្សសាហាវ ពាលោឈ្លានពាន លោកឱយប្រែប្រាណ
ចៀសចេញឱយឆ្ងាយ។

កូនចៅអើយស្តាប់ ពាក្យនេះជាច្បាប់ ប្រដៅបរិយាយ
ពាក្យនេះជាថ្នល់ តម្កល់ទុកឆ្ងាយ កូនចៅទាំងឡាយ
នាំគ្នាស្តាប់រ៉ា។

ហែអស់កូនចៅ តំណក្រោយទៅ ត្រកូលវង្សា
ចូរចេះរាប់រក ស្រែករត្មីគ្នា ខុសគាប់កាចជា
អត់ឱនត្រងរង។

ឱកូនចៅអើយ អាពុកចាស់ហើយ ពុំបាននៅផង
នរណានឹងនៅ ប្រដៅបាហោង នរណានឹងស្នង
អាពុកនេះបាន។

តែខ្លួនទៅបាត់ ទុកពាក្យមួយម៉ាត់ ប្រដៅទូន្មាន
ពាក្យនេះអាពុក សង់ទុកជាស្ពាន ឱយកូនចៅបាន
ឆ្លងទៅត្រើយនាយ។

៣០. ពាក្យមួយនេះមិញ ហេតុមិនស្រឡាញ់ មានពាក្យថាឆ្ងាយ
ទោះទូកបែកចាក់ សំពៅធ្លុះធ្លាយ ទាល់លង្កានាយ
សឹងមករកបាន។
កូនចៅអើយគិត ផ្ចិតផ្ចង់គំនិត រក្សាខ្លួនប្រាណ
កុំអាងសក្តិបុណ្យ លោភលន់ចង់បាន បំពារបំពាន
ពុំធ្វើដោយធម៌។
ធម្មតាជាមនុស្ស ឱយដឹងគាប់ខុស បុណ្យបាបឱយស្គាល់
ថ្វីមិនចង់បាន ចង់គ្មានអង្គាល់ ឱយបានដោយធម៌
នោះទើបយឺនយូរ។
បើបានឹងខំ លោកោវាយដំ សន្ទំចាក់ចូល
ចំណេះទ្រព្យនោះ នៅពុំបរិបូណ៌ ស្មើរកប្រមូល
ទុកឱយគេទេ។
កូនចៅអើយអត់ គិតក្តីកំសត់ កុំធ្វើប៉ោឡៃ
កុំអាងមានទ្រព្យ កុំត្រាប់ពុតគេ ចូរចេះរិះរេ
សាយសព្វសារពើ។
៣៥. ធម្មតាស្រី កុំចង់មេត្រី សាយសព្វអន្លើ
យកម្តេចខ័ណ្ឌស្ករ មកគរទុកលើ ស្រមោចហើយតើ
អត់ម្តេចមិនស៊ី។
មួយដូចប្រុសខ្លោះ[១] ពាលពេញកម្លោះ ចិត្តចោរចង់ស្រី
កលមួយដូចក្អែក ចេញលួចរកឆី មិនដឹងឬអ្វី
យកពង់មាន់ធ្វើ។
កលមួយសោតណា នេះនឹងឧបមា អណ្តើកឯងតើ
ពងលាក់ជាហើយ ម្តេចឡើយទៅធ្វើ អស់ពាក្យពេចន៍លើ
អាអួតមហាចោរ។
ប្រើប្រុងប្រយ័ត្ន ពាក្យពេចន៍សួរសត្យ សារស័ព្ទពំនោល
ពីរោះមធូរ បរិបូណ៌ពាក្យពោល កុំអាលខឹងឃោរ
ចាចែងភាសា។
កុំអាលកន្ទ្រើង កុំស្លិតខិតឡើង លើលោកព្រឹទ្ធា
គិតការដំណៀល លោកដៀលនិន្ទា អង្គឱយកើតជា

(១) ខ្លោះ : ពាក្យបុរាណ ខ្លោះ គឺ កំឡោះ

និន្នាអាស្រវ។

៤០. ទោះប្រុសទោះស្រី កើតនាលោកិយ លោកឱយគាប់គ្រូ
ក្រែមានឆ្អែះឆ្អាប ស្រឡាបត្រង់ត្រូវ ក្រែងជូពុំជូ-
កាលកម្មវេរា។

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួនមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រែកន្លង។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង
លោកពុំឱយសេព ឱយវាងជាម្តង វាតែឱយហ្មង
ភ្លេចភ្លាំងស្មារតី។

ឱយភ្លេចក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្រ្តសួស្តី
ភ្លេចសីលភ្លេចទាន ភ្លេចញាណវុឌ្ឍី ភ្លេចច្បាប់ប្រក្រតី
ឆ្កួតបីប្រការ។

កុំអាងចំណេះ កុំអួតថាចេះ កុំដោយពុតពាល
កុំសមកុំសេព កុំស្រើបកុំស្រាល កុំអរកុំអាល
ត្រេកទៅដោយវា។

៤៥. ថាបើនឹងចង់ សេពដោយចំណង់ អំពើពាលា
អាចារ្យលោកចង ជាពាក្យឧបមា ឱយអ្នកមួយណា
ដុតដែកឱយក្តៅ។

បើកាន់ដែកបាន នោះទើបឱយហ៊ាន សេពសមចូលទៅ
អំពើទាំងបី ដូចដែកច្រាលឆ្អៅ លុះកាន់មិនក្តៅ
នោះទើបសេពបាន។

អំពើគុណគាប់ កូនចៅអើយស្តាប់ អាពុកទូន្មាន
រៀនគុណទាំងប្រាំ សឹងនាំរូបបាន រួមរក្សាប្រាណ
ពិតពុំឃ្លាតឃ្លា។

កាលណាសឹកមាន ថ្កើងឯទាហាន ពន្លឹកមហិមា
កាលបើមានអាថ៌ នូវសារបញ្ហា ដោះស្រាយប្រស្នា
ថ្កើងឯប្រាជ្ញប្រាយ។

មួយសោតកាលបើ រិះគិតនឹងធ្វើ កិច្ចការសម្ងាយ
ថ្កើងឯអ្នកជាង ជំនាងសុសសាយ កិច្ចការទំនាយ
ថ្កើងឯហោរា។

៥០. កាលកើតព្យាធិ រោគរោមឥន្ទ្រីយ ថ្កើងឯពេទ្យា
រីអ្នកទាំងប្រាំ សឹងនាំអាត្មា ឱយគាប់ដោយនា
ចំណេះទីទៃ។

មួយសោតជាសង្ឃ នោះឱយផ្គត់ផ្គង់ តាមព្រះវិន័យ
ជាស្រីសោតផ្គត់ មារយាទប្រពៃ ជាមនុស្សសព្វថ្ងៃ
ឱយរៀរបាបបង់។

ចូរចេះដាក់ខ្លួន គួរគិតក្តីសួន រក្សាផ្គត់ផ្គង់
ស្គាល់ទៅស្គាល់នៅ ប្រាជ្ញខ្មៅគថ្លង់ ស្គាល់រៀចស្គាល់ត្រង់
ស្គាល់ឱយគ្រប់ក្រៃ។

លោកថាឱយត្រាប់ នូវសត្វកុកសាប់ អំពើប្រពៃ
កុំត្រាប់កុកស កោកាវសព្វថ្ងៃ ហើយរទំអាស្រ័យ
ពុំប្លែកប្លែងប្រាណ។

លោកថាដែកផង ហៅរឹងកន្លង គេដុតដំបាន
រូសកោសជាការ តាមចិត្តប្រមាណ ពុំដែលនឹងមាន
ប្រកែកឡើងណា។

៥៥. ដំរីក្នុងព្រៃ សាហាវហ៊ានក្រៃ មមីសោះសា
គេទាក់មកបាន ផ្សះផ្សាំជិះជា ពុំដែលនឹងថា
ប្រកែកមិននៅ។

ត្រង់ពាលប្រទូស្ត ប្រទះរឹងរូស ពុំលុះប្រដៅ
រឹងលើសពីដែក នឹងដំរីនៅ ដោយនាកម្លៅ
កម្លាំងមោហា។

លោកថាក្អែកពិត យកម្តេចមណីរ័តន៍ តែវទៅបូជា
ម្រឹកជាតិវិស័យ ពាក់ម្តេចជជា ធម្មជាតិជាស្វា
ស្លៀកម្តេចសំពត់។

យកម្តេចព្រះធមត ជ្រៅជ្រះមានអាថ៌ ប្រពៃវិសុទ្ធ
ប្រដៅពាលា ប៉ោទ្បែស្មុគទ្រុឌ យកម្តេចឯមកុដ
បំពាក់ពានរ។

លោកថាផ្កាផង ពិដោរពិតហោង បុស្បាបវរ
ក្លិនក្លែបត្រឡប់ សាយសព្វទិសករ ហើយរោយកេសរ
បាត់បុស្បគន្ធា។

៦០. តែអ្នកមួយទៀង ពាក្យពេចន៍ឥតល្អៀង ចម្រើនមេត្តា

| | | | |
|---|---|---|---|
| | នោះកូវក្រអូប | ក្រៃលែងក្លិនផ្កា | ទូទៅនានា |
| | | ដោរដល់សួគ៌ស្ថាន។ | |
| | រីអរសោចឹលាមក | ហៅស្អុយអាក្រក់ | ពេកពន់ប្រមាណ |
| | មោះស្អុយនោះស្មើយ | ល្ហែល្ហើយគ្រាន់ក្បាន្ត | ល្មមទប់ទល់បាន |
| | | ពុំទាន់ជាអ្វី។ | |
| | តែអ្នកមួយកូវ | រអែររអូវ | ចិត្តបាបមូទូ |
| | កុហកភរភូត | បញ្ឆោតស្រដី | នាំពាក្យអប្រិយ |
| | | បំបែកមិត្តគេ។ | |
| | នោះកូវអាក្រក់ | ស្អុយក្រៃលែងលាមក | ពុំមានល្ហើយល្ហែ |
| | ដល់បរលោកសោត | ទៅនៅនិរយេ | នរកឯងឯ |
| | | ទល់ទុក្ខវេទនា។ | |
| | កុំពារកុំពាន | កុំយល់គេមាន | ច្រណែនឫស្យា |
| | ចូររៀរពាក្យស្លែង | ថ្លែងទៅពុំជា | រៀរពាក្យមុសា |
| | | បានបុណ្យក្រាស់ក្រៃ។ | |
| ៦៥. | កូនចៅអញអើយ | ចាំទុកជាត្រើយ | គ្រប់ខ្លួនទីទៃ |
| | ដើរដោយគន្លង | ផ្លូវផងវិស័យ | កុំពារពានព្រៃ |
| | | ជាន់ជាប់បន្លា។ | |
| | ក្រកិច្ចក្រកល | ក្រដឹងក្រយល់ | ក្រកិច្ចធានា[១] |
| | ក្រវៃឆ្នៃទាស់ | ឆ្លើយឆ្លាស់លោកា | ក្រជាមាតា |
| | | បិតាស្ងួនគ្រង។ | |
| | ក្រពាក្យពិរោះ | ក្រចិត្តអាចស្មោះ | ដឹងទុក្ខសត្វផង |
| | ក្រអត់ក្រខិន | ស្រឡាញ់ស្ងួនគ្រង | ក្រពាក្យឥតឆ្លង |
| | | ល្មមនឹងចិត្តគេ។ | |
| | ក្រមានពាក្យស័ត្យ | ក្រចិត្តអាចកាត់ | ស្រឡះពីស្នេហ៍ |
| | ក្រធ្ងន់គំនិត | ក្រគិតគុណគេ | ក្របានជាមេ- |
| | | បាគេទាំងឡាយ។ | |
| | ក្តីច្បាប់នេះក្រ | នរណាអាចយក៍ | ទុកខ្លួនសម្ចាយ |
| | ដ៏លោកនេះគាប់ | នៅបានពណ្ណរាយ | ដល់បរលោកនាយ |
| | | សោយសុខស្រេចស្រាប់។ | |

*(១) ច្បាប់ខ្លះថា ក្រចិត្តសទ្ធា ។*

៧០. ឱពុកចាស់ហើយ អស់កូនចៅអើយ នាំគ្នាស្តែងស្តាប់
ពាក្យពិតទូន្មាន ប្រធានគ្រាន់គ្រប់ ស្មើទ្រព្យសម្រាប់
ទុកឱយគ្រប់គ្នា។

ចូរចាំកុំភ្លេច ទូន្មាននេះស្រេច ស្មើខ្លួនហើយណា
ចាំចងឱយខ្ជាប់ ជាច្បាប់អាត្មា សូរេចអក្ខរា
សុភាសិតហោង។

# ច្បាប់ពាក្យចាស់

## បទព្រហ្មគីតិ

១.	ពាក្យចាស់ពាក្យពីព្រេង	ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់	រមិលយល់ប៉ុនទាំងភ្នំ។
ចូលព្រៃសត្វសាហាវ	រកអំពាវ[១] គ្នាមកជុំ
ដល់បានស្តុរទឹកឃ្មុំ	ពួនក្នុងផ្ទះឆីម្នាក់ឯង។
បានហើយចង់បានទៀត	ឆ្លៀតហើយឆៀតពុំគីតឈ្វេង
មើលយល់តែម្នាក់ឯង	មិនយល់គេឯទៀតផង។
នឹងស៊ីចង់ពិសា	ខ្ជិលទំពារឱយម៉ដ្ឋហ្មង
យល់នាមថាជាមង	យល់ឯផងថាជាក្អួយ។
៥.	យល់តាថាជីដូន	យល់ឯកូនថាជាក្អួយ
យល់ពីរថាជាមួយ	យល់ឯព្រួយថាជាសុខ។
យល់ទោសថាជាគុណ	យល់បុណ្យថានរក
យល់ល្អថាអាក្រក់	យល់លាមកថាជាផ្កា។
ស្លៀកស្បង់មិនកោរសក់	ឆ្លះកញ្ចក់ធ្មេចនេត្រា
យល់សេះថាជាលា	យល់គជាថាកណ្តុរ។
នេះពាក្យលោកពីព្រេង	អ្នកណាឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកកុំថាថ្នល់	ក្រែងកំហល់កំហុសមាន។
អ្នកប្រាជ្ញកាន់ពាក្យទៀង	កុំលំអៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន	ពាក្យអ្នកចាស់លោកដៀលថា។
១០.	ពាក្យនេះពីព្រេងព្រឹទ្ធ	គួរឱយគិតពិចារណា
កុំអួតអង្គអាត្មា	ថាចំពោះចំណាំមាន។
ដេកយប់កុំដេកយូរ	ខ្លាចក្តីទូជំនដល់ប្រាណ
បើស៊ីកុំតាមឃ្លាន	គិតប្រមាណគ្រប់គ្នីគ្នា។
លើកដាក់តាមកម្លាំង	កុំកើចខ្លាំងឈឺដល់ស្មា
ប្រើគេប្រើឱយត្រា	កុំសុំាស៊ិនរនថៅរៅ។

*(១) ច្បាប់ខ្លះថា រកបំព្រាវ បានន័យថា អំពាវនាវ ។*

ទោះគិតកុំរួសរាន់ គិតឱយគ្រាន់ទើបដើរទៅ
កុំឱយមានអាស្រូវ កើតជំនៀលដល់អាត្មា។
កុំយកឆ្អិនជាឆៅ កិច្ចក្នុងក្រៅមានតម្រា
កុំអាងឯងប្រាជ្ញា ចោលច្បាប់ក្បួនលោកព្រេងនាយ។
១៥. ស្រដីឱយស្រួចស្រេច គិតសេចគ្រេចកុំគិតងាយ
រំពឹងឱយវែងឆ្ងាយ យល់លង្វែកពាក្យលោកថា។
ពាក្យព្រេងលោកស្រដី ថាកុំបីចិញ្ចឹមខ្លាច
ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱយបាន។
កាន់កពស់ឱយខ្ជាប់ ខ្លាចក្រឡាប់ខាំងប្រាណ
អូសទូកកុំឱយល្អាន ទឹកថ្លាសោតកុំឱយល្អក់។
ស្លឹកឈើឥតកម្រើក បើកក្រើកត្បិតខ្យល់បក់
ទឹកថ្លាល្អឹកបើល្អក់ ត្បិតរលកខ្លាំងសោះសា។
យល់តូចកុំខិតខំ គួរសន្សំយកជាគ្នា
បានច្រើនកុំខំពារ សន្សឹមក្សិណតិចៗទៅ។
២៧. អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សខ្លៅ ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាផ្ការ[១] ។
រក្សាទៅមុខរឹង ឥតកំដឹងអស់អម្បាល
ចំណោ ចីរកាន់កាល ដូចរបងស្រាស់បន្លា។
កុំឆ្អែកពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានៗផ្ទៃផ្សា ឱយឆីវ៉ាបានឆ្អែតផង។
កុំមានចិត្តលលើ ពឹងក្រពើឱយចម្លង
កុំកាច់ឧសរបង វាំងចំណារឯអាត្មា។
២៥. មានទូកហើយមានថ្នោល មានបង្គោលមានយុថ្កា
ទាំងពួរទាំងច្រវា ក្រជីងចាប់ដោយនូវគ្រប់។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាគំនិត។
ពាក្យព្រេងគិតគួរចាំ ជាបណ្តាំប្រដៅចិត្ត

*(១) អ្នករុងរក្សាផ្ការ បានន័យថា អ្នកមានរក្សាអ្នកខ្សត់។*

ពាក្យព្រេងពាក្យព្រេងព្រឹទ្ធ មុខគួរគិតៗឱយគ្រាន់។
ពាក្យនេះជាសណ្ដាប់ ទុកជាច្បាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់ កំណត់នៅឥតឃ្លាតឃ្លា។
៣០. សូររេចនូវនិទាន ពាក្យទូន្មានដោយប្រការ
អម្បាលនេះឯងណា ចាំទុកកាយគ្រប់គ្រាន់ហោង។

# ច្បាប់ហែមហាជន

## បទព្រហ្មគីតិ

១. ហែមហាជនសប្បុរស ទោះស្រីប្រុសកបកិរិយា
គួរគិតយកប្រាជ្ញា ចងចាំជាប់ជាគន្លង។
មានច្បាប់ពីបុរាណ លោកទូន្មានតែងទុកឱ្យ(១)
ជនជាតិនៅឯក្រោយ ចងជាច្បាប់ទុកគ្រប់ប្រាណ។
ធម្មតាអ្នកចិត្តល្អ ពុំដែលក្រខ្សត់ប៉ុន្មាន
ទេព្ដាជាប្រធាន តែងចម្រើនសុខឥតសៅ។
បើធ្វើចិត្តអាក្រក់ ដើរស្ទួចឆក់លោកសៅដៅ
ទ្រព្យនោះណាបាត់ទៅ ដូចអគ្គីឆេះរោលរាល។
៥. ទេព្ដានឹងផ្ដន្ទា ឱ្យវេទនានៅកណ្ដាល
នរកទុក្ខអម្បាល លំបាកណាស់ណាអ្នកអើយ
សម្បត្តិក្នុងលោកិយ បរលោកក្ដីពុំត្រាឡើយ
ទុក្ខច្រើនពេកណាស់ហើយ តែនឹងរងកម្មវេរា។
បើចង់ឱ្យបានសុខ ឱ្យវិតក្កក្នុងចិន្តា
ខិតខំពិចារណា នឹងចរចាមានមេត្រី។
បើចង់បានជាធំ នោះឱ្យខំរៀនសេចក្ដី
ឱ្យច្បាស់តាមបាលី កេរ្ដិ៍គម្ពីរច្បាប់ធម៌ថា។
កុំអាងតែសក្ដិបុណ្យ ចិត្តលោភលន់លើមាត្រា
រីបុណ្យនោះអសារ ទ្រព្យធនណាអន្តរាយ។
១០. ចេះចាំក្នុងសេចក្ដី មានមេត្រីពាក្យបរិយាយ
មេត្តាអ្នកទាំងឡាយ អ្នកនោះនឹងជួយឱ្យពរ។
កុសលនោះទ្រទ្រង់ ជួយឱ្យគង់សក្ដិយសល្អ
នោះនឹងចូលអាករ ទ្រព្យធនមកពីជិតឆ្ងាយ។
បើកាន់កាប់ដោយធម៌ សក្ដិយសល្អឃើញសប្បាយ
ទ្រព្យធនផងទាំងឡាយ ទុកឱ្យកូនចៅឆីបាន។
គួរគន់គិតរំពឹង រិះជញ្ជឹងមើលប្រមាណ

កុសលព្រេងនោះមាន នឹងខំថ្វីពេកអម្បាយ។
ច្បាប់ធម៌ពីបុរាណ មាននិទានជាបរិយាយ
គម្ពីរចោទចែងចាយ ទូន្មានមកទុកឱយស្តាប់។
១៥. កុំខំហួសវាសនា កុំចរចាចោលឯច្បាប់
កុំប្រឹងចោលសណ្តាប់ កុំបន្លប់ចោលឯខ្នាត។
ធ្វើអ្វីគួរឱយគិត មើលពិនិត្យដោយបទបាឋ
គប្បីឱយសង្វាត កុំឱយខាតប្រយោជន៍ខ្លួន។
ទៅមុខប្រយ័ត្នក្រោយ កុំឱយឆ្គោយគិតឱយមួន
ការអ្វីមើលឱយថ្នួន ឱយត្រូវជួននឹងរាជការ។
កុំអាងថាខ្លួនចេះ អួតចំណេះមានប្រាជ្ញា
ឱយដឹងពិចារណា ព្រឹទ្ធាចារ្យនូវតូចធម។
រីក្នុងជាតិនេះនៃ ទោះប្រុសស្រីឱយគួរសម
ទើបបានធ្វើជាធំ និយាយលើគេនោះបាន។
២០. ដូចអង្គព្រះអាទិត្យ ដ៏មានឫទ្ធិជាប្រធាន
ពន្លឺភ្លឺសព្វស្ថាន នោះពុំបានចន្លោះឡើយ។
គិតឃើញគួររំពឹង កុំស្មៀមឈឹងឈប់ព្រងើយ
កុំស្ងៀមធ្វើកន្តើយ ខ្លួនធំហើយត្រូវត្រួតត្រា។
បើស្ងៀំពុំរិះគិត នឹងងងឹតដូចយប់ណា
ធ្លាយធ្លុះខុសខូចការ រីទោសាជិតដល់ខ្លួន។
ហេតុតែពុំពិនិត្យ ដោយសុចរិតតាមច្បាប់ក្បួន
ធ្លុះធ្លាយឱយខូចខ្លួន នេះនៃជួនដូចព្រឹក្សា។
ដើមឈើដុះក្នុងព្រៃ តូចធំក្តីច្រើនត្រៀបត្រា
ឱយជ្រៃនៅដោយសារ គិតខុសការខ្លួនអប្រិយ។
២៥. ជ្រៃតតអសុរោះ ដូចមនុស្សអន្យតិរ្ថិយ
តែងតែមានឱយភ័យ អាប់អន់អស់អង្គរូបា។
បើស្តីឱយពិនិត្យ ពាក្យណាពិតសឹមចរចា
កុំចាត់ដោយមុសា កុំពាលោដោយក្បួនច្បាប់។
រក្សាកេរមារយាទ កុំឱយឃ្លាតនៃសណ្តាប់
មានក្នុងគម្ពីរស្រាប់ គួរខំរៀនរក្សាខ្លួន។
រក្សាអស់ទ្រព្យធន យសសក្តិបុណ្យឱយមាំមួន
ដោយតេជតេជៈខ្លួន កេរ្តិ៍គម្ពីរទូន្មានទុក។

បើចង់ធ្វើមេបា ឱយឧស្សាហ៍នៅភូមិស្រុក
ចង់បានប្រាណស្រណុក ច្បាប់ចងទុកឱយរៀនគិត។
៣០. បើបានងារសក្តិយស ចិត្តឱយស្មោះនឹងមហាក្សត្រ
បើចង់គង់សម្បត្តិ ច្បាប់លោកថាកុំសូវចាយ។
បើចង់ធ្វើជាហោរ ឱយរៀនគួរលេខទំនាយ
ចង់សងគុណទាំងឡាយ បើនិយាយឱយបរមត្ថ។
បើចង់ឱយបរិសុទ្ធ ឱយលំអុតកេរ្តិ៍មារយាទ
បើចង់រក្សាញាតិ កុំឱយឃ្លាតប្រតិបត្តិ។
បើចង់ឱយបានសុខ ចៀសចាកទុក្ខឱយកំណត់
បើស្តីៗតាមបទ បើឃើញពុតកុំក្រេវក្រោធ។
សន្តាននៅក្នុងស្រុក អំពល់ទុក្ខកុំពិរោធ
គង់តែគេនឹងកោត ខ្លាចអំណាចអំណត់នោះ។
៣៥. បើចង់ឱយអប្រិយ បង្កើតក្តីអាក្រក់ឈ្មោះ
បើចង់ឱយត្រូវខ្នោះ នោះឱយគិតធ្វើជាចោរ។
សេចក្តីនេះមានច្រើន រាប់រយពាន់ក្នុងនគរ
និទានច្បាប់ទុកមក គ្រាន់តែមើលដឹងសេចក្តី។
ឱយគិតពិចារណា ដោយប្រាជ្ញាញាណវាងវៃ
ត្រិះរិះអធ្យាស្រ័យ គួរឱយគិតរក្សាកាយ។
រីលោកមានសក្តិយស បុណ្យខ្ពង់ខ្ពស់ធំទូលាយ
អ្នកតូចកុំមើលងាយ កុំផ្ទឹមកាយនឹងលោកឡើយ។
បើស្តីឱយមានក្រែង កុំជល់ជែងពាក្យលោកឡើយ
តតបថែមរឿយៗ មានទោសហើយខ្លួនអាស្រូវ។
៤០. ដូចអ្នកចេះពុះឧស ពុំដែលខុសសុទ្ធតែត្រូវ
ឧសសាញដូចម្តេចកូវ ត្រូវដដែលសឹងបែកបាន។
ហេតុនេះគួរប្រយ័ត្ន តាមព្រះក្រិត្យធម៌ទូន្មាន
កុំបីធ្វើបំពាន រក្សាប្រាណកុំបីធ្លោយ។
បើខឹងដូចម្តេចក្តី ប្រុងស្មារតីកុំឱយធ្លោយ
ខឹងនោះនឹងខុសក្រោយ ខឹងនោះឱយមានទោសា។
ទោសឱយបង់ស័ក្តិបុណ្យ បង់ទ្រព្យធនបុត្រភរិយា
មានកាលក្ស័យជន្មា ដល់អាត្មាសោតសឹងមាន។
បីដូចសត្វមមាច កាន់ចិត្តកាចទ្រូស្តសាមាន្យ

ហ៊ានហើរដល់ពុះពាន ព្រះអគ្គីឆេះឆាប់ក្រៃ។
៤៥. ហេតុនេះគួររិះគិត គួរចូលចិត្តកុំសង្ស័យ
គួរប្រឹងប្រុងស្មារតី តាមវិន័យច្បាប់ធម៌ថា។
ទោះផ្តាំព្រះមហាក្សត្រ ទាំងព្រាហ្មណ៍ព្រឹទ្ធនូវយោធា
ទោះផ្តាំព្រះមាតា ព្រះបិតាជាប្រធាន។
ឱយដឹងកលកិច្ចការ មើលអធ្យាស្រ័យប្រមាណ
បើលោកព្រះទ័យក្សាន្ត មានសេចក្តីសុំចរចារ។
កលមួយលោកនិយាយ អ្នកជិតឆ្ងាយពីរាជការ
ស្តីលលេងក្តីណា កុំចរចាកាន់លោកឡើយ។
ទោះបីលោកសប្បាយ ឈប់និយាយនោះស្រេចហើយ
តាមហេតុនោះអ្នកអើយ កុំចរចាការអ្វីៗ។
៥០. មួយលោកនឹងស្តីផង ចូរចាប់ចងចាំសេចក្តី
កុំបីភ្លេចឡើយនៃ ពាក្យបណ្តាំគ្រប់ប្រការ។
មួយបើគ្រូបាធ្យាយ ឪពុកម្តាយនូវយោធា
ព្រះមហាក្សត្រក្តីណា លោកមានការក្រជាងាយ។
លោកប្រើឱយទៅមើល សព្វសារពើការទាំងឡាយ
ទោះការនៅជិតឆ្ងាយ គួរពិនិត្យមើលឱយជាក់។
ឱយដឹងការវែងខ្លី តូចធំក្តីទោះមាសប្រាក់
ពិនិត្យមើលឱយជាក់ ក្នុងបញ្ជីជាចំណាំ។
ទោះបីឥតដំណឹង ការពុំដឹងភ្លេចពុំចាំ
ទោះនឹងធ្វើជាធំ ស្តីលើគេសោតពុំបាន។
៥៥. បើដឹងការកលកិច្ចច ចាំកុំភ្លេចក្នុងវិញ្ញាណ
ទើបធ្វើជាធំបាន ហេតុដោយមានមារយាទល្អ។
បើលោកមានក្រេវក្រោធ ស្តីពិរោធខឹងរឹករវ
ជេរពោលបន្ទោលមក៍ តាមដំណើរដែលខ្លួនធ្វើ។
កុំប្រឹងតបតឆ្លង ឆ្លើយសាសងកេរដំណើរ
ពាក្យពេចន៍សព្វសារពើ ប្រឹងប្រកែកជជែកឈ្លោះ។
ប្រៀបដូចជាភ្លើងឆេះ ដំណើរនេះចំចំពោះ
កុំខឹងប្រកែកឈ្លោះ នឹងភ្លើងនោះពុំឈ្នះឡើយ។
មួយដូចដំណើរខ្លួន អ្នកធំគួនពុំគ្រាស្បើយ
ដូចភ្លើងឆេះឯងហើយ គួរចូលចិត្តគិតចងចាំ។

៦០. គួរតែយកទឹកនៅ    លត់ភ្លើងក្តៅតាមចំណាំ
សោះលោកខឹងមួនមាំ    យកអំណត់ទើបលត់បាន។
អត់ចាំលោកបាត់ក្រោធ    ខឹងពិរោធលុះស្រាកស្រាន្ត
កុំថែមដោយដើមដាន    ដំណើរនោះជាឯក្រោយ។
លោកនឹងកោតថាចេះ    មានចំណេះមិនថ្លស់ធ្លោយ
លោកគិតអាណិតក្រោយ    ឃើញដឹងដោយសេចក្តីត្រង់។
លោកថាខ្លួនចេះអត់    មានអំណត់មិនល្ងើល្ងង់
នោះលោកនឹងតម្រង់    ឱយកេរ្តិ៍គង់កើតសុខា។
ទោះបីលោកអាណិត    ខំរិះគិតពិចារណា
រិះរេរកប្រាជ្ញា    រក្សាខ្លួនដោយក្រឹត្យក្រម។
៦៥. យកលោកជាទីពឹង    លើពំនឹងលោកជាធំ
គួរគិតឱយគួរសម    ទោះដេកដើរអង្គុយក្តី។
ឱយមានទីប្រតិបត្តិ    គួរប្រយ័ត្នប្រុងស្មារតី
ទោះទ្រព្យលោកថោកថ្លៃ    គន់រំពៃមើលរក្សា។
ខ្លួនពឹងលើលោកហើយ    កុំព្រងើយប្រហែសការ
ប្រយ័ត្នប្រុងប្រាជ្ញា    តាមសណ្តាប់ច្បាប់ប្រដៅ។
ប្រៀបដូចដើមឈើធំ    វល្លិដុះរុំព័ទ្ធពីក្រៅ
វល្លិសូមសំណាក់នៅ    ដើមឈើនោះដុះខ្ពស់ផង។
វល្លិខ្ពស់ព្រោះគុណឈើ    វល្លិព័ទ្ធលើនោះឯងហោង
វល្លិវារព័ទ្ធទាក់ទង    មានផ្លែផ្កាច្រើនក្រាស់ក្រែ។
៧០. ឈើដូចលោកមានបុណ្យ    វល្លិដុះព័ទ្ធពាក់ប្រស្រ័យ
ដូចអ្នកតូចនោះនៃ    គួរគិតកុំភ្លេចគុណឡើយ។
បើអ្នកណាដឹងគុណ    កុសលបុណ្យចម្រើនឱយ
បើភ្លេចគុណគេហើយ    បាបផ្តន្ទាឃើញថ្មីៗ។
បរលោកមើលមិនយល់    ឃើញដឹងកលកេរ្តិ៍លោកិយ
ដឹងគុណពុំភ្លេចក្តី    ដូចប្រុសស្រីដឹងស្រាប់ហើយ។
ហេតុនោះគួររេគិត    រិះពិនិត្យកុំព្រងើយ
កុំធ្វេសប្រហែសឡើយ    គុណនោះស្មើយានជំនិះ។
ឈ្នួញទឹកពិតពឹងទូក    រីឈ្នួញគោកពឹងរទេះ
សំណាងពឹងចំណេះ    ប្រាជ្ញប្រាយចេះដឹងគម្ពីរ។

៧៥. ព្រះសង្ឃពឹងវិន័យ សត្វកពត្រៃពឹងធរណី
សេនាពឹងឫទ្ធី ឯអ្នកជីពិតពឹងវត្ត។
រីមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់
កិរិយាពឹងសំពត់ រីបរិសុទ្ធពិតពឹងសីល។
សត្វត្មាតពិតពឹងរុយ សាច់សត្វស្អុយពឹងអំបិល
មង្គលការពឹងពពិល រក្សាសីលពិតពឹងទាន។
ទានមានគុណប្រសើរ ទោះនឹងធ្វើបុណ្យសឹងបាន
ជូនឧទ្ទិសសព្វស្ថាន ផលបុណ្យបានដូចប្រាថ្នា។
រីទាននោះមានច្រើន រាប់រយម៉ឺនក្នុងសីមា
ក្រមានអ្នកឯណា នឹងស្គាល់ទានឱយគ្រប់ឡើយ។
៨០. ទោះបីអ្នកឯណា មានវាសនាប្រាកដហើយ
ប្រតិបត្តិទានជាត្រើយ ទានទ្រទ្រង់ទាំងភពត្រៃ។
ថាបើបានប្រតិបត្តិ ទានប្រាកដហើយប្រពៃ
បីដូចស្ពានកែវថ្លៃ កែវនៅក្នុងដួងផ្កាល្វា។
ទានជួយឱយបានសុខ រួចនរកបានសុខា
សុខនៅលោកិយណា សុខដល់សួគ៌និព្វានហោង។
ពំនឹងពំនាក់នៅ ពឹងឱយត្រូវតាមគន្លង
ពឹងខុសនឹងសៅហ្មង នឹងខូចខាតខ្លួនអន្តរាយ។
ជ្រូកស្រុកពិតពឹងមនុស្ស ទុកចិត្តស្មោះថារសាយ
យូរទៅកើតដល់កាយ រងទុក្ខដល់ប្រាសព្រាត់គ្នា។
៨៥. មួយដូចគោក្របី សេះដំរីនួវមានទា
នៅនែនឹងមនុស្សា យូរប្រែជាសត្រូវផង។
មានកាលលក់បង្រាស ឱយព្រាត់ប្រាសពីមេពង
ជូនក្ស័យជីវិតផង ហេតុបំណងខុសថ្នាំងថ្នាក់។
កង្កែបគីង្គក់ហ៊ីង អរឃើញភ្លៀងស្រក់ស្រាក់
នាំគ្នាស្រែកឰជាក់ លោតលេងសាយកាលភ្លៀងនៅ។
លង់លុះដល់ភ្លៀងរាំង ដីរឹងគាំងស្ងួតទាំងស្មៅ
កង្កែបហ៊ីងលាក់ខ្លួន ជ្រកពឹងពួនក្នុងធរណី
គេតាមទាន់ចាប់ឆី លុះជីវិតក្សីណក្ស័យហោង។
៩០. ក្ស័យចោលកូនតូចៗ ខុសខាតខូចបង់ទាំងពង
ព្រាត់ព្រាយប្រាសចោលរូង ត្បិតខំស្រែកសម្រែកខ្លាំង។

| | |
|---|---|
| ហេតុនោះគួររិះគិត | ប្រុងគំនិតកុំភ័ន្តភាំង |
| គួរយកព្រះធម៌តាំង | ទូន្មានចិត្តតាមនិទាន។ |
| បើកាន់ចិត្តអាក្រក់ | ដូចឈើពុកស្ថិតសព្វស្ថាន |
| ពុកពីបណ្តូលប្រាណ | សឹងបាក់បែកហែកដើម។ |
| ជ្រុះស្លឹកជ្រុះផ្លែផ្កា | រំលងវេទនាឃើញសម្បើម |
| ហេតុនោះគួរឱយខ្លើម | ចិត្តអាក្រក់កុំទុកប្រាណ។ |
| ទុកយូរបន្តិចទៅ | ជួនក្រែងត្រូវតាមនិទាន |
| នឹងកើតក្តីរំខាន | កុំឱយប្រាណរោយរេចអស់។ |
| ៩៥. កុំកាន់ចិត្តឯឫស្យា | កុំចរចាចោលសប្បុរស |
| ឥតទោសកុំថាខុស | អ្នកចិត្តស្មោះកុំបញ្ឆោត។ |
| ផ្គរលាន់ឮគគ្រេង | កុំអួតភ្លៀងថាធ្លាក់មក |
| ក្រែងខ្យល់ផាត់បក់បោក | ប្រានពពកមេឃស្រឡះ។ |
| គិតការគួររំពឹង | មើលសំឡឹងឱយជាក់ច្បាស់ |
| គិតការកុំចោលចាស់ | ជួនក្រែងទាស់នឹងខុសក្រោយ។ |
| បើជនជាតិឯណា | មានវាសនាបុណ្យលោកជួយ |
| កាន់ច្បាប់ខ្ជាប់មិនធ្លោយ | កុសលឱយបានសុខា។ |
| ឱយបានសុខទាំងបី | សុខលោកិយសុខសួគ៌ា |
| សុខដល់និព្វានណា | ច្បាប់ធម៌ថាសុខស្រេចហោង។ |

# ច្បាប់បណ្តាំបិតា

## បទកាកគតិ

១. នេះបទកាកគា- តិទើបចងជា ច្បាប់ច្បាស់ទូន្មាន
តាមដោយគន្លង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោកនិទាន
ប្រដៅបុត្រភ្ងា។

ហៃកូនពន្លក ស្ងួនអើយមាសយក បណ្តាំបិតា
ឪពុកនោះចាស់ ឥតអ្វីអោយបា ស្ងួនអើយរក្សា
ពាក្យឪពុកនៅ។

ឱកូនកំសត់ រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ
រៀនឱនលំទោន កុំឱយហ្មងសៅ ដល់ខ្លួនកូនពៅ
កេរ្តិ៍ដល់ឪពុក។

ដឹងឆ្លើយត្បិតដង កូនសោតរវែងឆ្គង ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី ចេះរៀបដាក់ទុក ប្រះដេកឆាប់លក់
ត្បិតឥតបើគិត។

៥. ចំណោះទាំងឡាយ កិច្ចកលដោះស្រាយ ត្បិតតែគំនិត
ដឹងកិច្ចដឹងកល ដឹងឆ្ងាយដឹងជិត ដូចកលកាំបិត
កាប់ឆ្ការទំលាយ។

ល្មមទៅល្មមខាន ល្មមដើរបំពាន ពុំគិតក្រងាយ
ល្មមឈប់បង្អង់ ល្មមខាននៅអាយ ក្តីក្រកុំស្រាយ
ក្តីងាយកុំធ្វេស។

សូវដើរកុំដេក សូវចប់កុំគ្រេក សេចក្តីប្រហែស
សូវខានកុំពារ ចិត្តចង់ចចេស សូវចូលកុំចៀស
វាសរួចសឹមគួរ។

លឿនកុំបំបោល ពាក្យព្រេងកុំចោល ខឹងកុំមូទូ
ស្រាយចេញឱយឆាប់ កុំទុកឱយយូរ សេចក្តីមូទូ
មិនដឹងខុសត្រូវ។

ដេកកុំដំងើច គេក្រកុំសើច គេភ័យកុំព្យូហ៍

ទោះខឹងប៉ុន្មាន ធ្វើជាឱយគួរ តឹងគិតឱយធូរ
យូរគិតឱយឆាប់។

១០. សេចក្តីបម្រុង ពាក្យដើមពាក្យចុង ប្រកាន់ឱយខ្ជាប់
សូវនឿយឯខ្លួន កុំឱយបង់ទ្រព្យ សូវបង់ក្តីគាប់
កុំឱយខ្លួនស្លាប់។

សូវស្លាប់ទៅជា កុំបង់ធម្មា ឥរិយាសីលគាប់
ឱយគិតជញ្ជឹង រំពឹងឱយសព្វ ពាក្យស្វែងកុំស្អប់
ពាក្យគាប់ឱយយក។

ចង់គង់ឱយទុក ចង់បានក្តីសុខ ឱយស្វែងដើររក
ឃើញច្បាស់ធម៌អាថ៌ ឱយយកខ្លួនជ្រក ក្តីសោកមម៉ោក
ឱយចៀសចេញឆ្ងាយ។

កូនអើយលោកិយ នេះឱយរៀនក្តី រៀនច្បាប់ទាំងឡាយ
រៀនទាំងសម្តី កុំបីវាយមាយ ក្តីក្រក្តីងាយ
ក្តីគួរក្តីសម។

ឱកូនពុំងា ធម្មតាអ្នកជា ឱយរៀនថៃទាំ
រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ
លក់ចេញទិញចូល។

១៥. មួយសោតឯច្បាប់ បើបាមានទ្រព្យ មនុស្សផងមកមូល
ពឹងពាក់ប្រាណណា បាយកប្រមូល សន្សំផ្សំចូល
យកមកជាមួយ។

កូនអើយឯម្លប់ មនុស្សផងចូលឈប់ សម្រាន្តអាត្មា
ព្រោះឈើមានម្លប់ ត្រសុំសាខា ម្តេចឡើយប្រែជា
ក្តៅជ្រកពុំបាន។

មនុស្សផងរំលង រកម្លប់ទៀតហោង ចូលចតសម្រាន្ត
ម្លប់នេះត្រជាក់ ត្រសាក់ក្សេមក្សាន្ត មនុស្សផងចូលថ្កាន
មិនមានហៅអាក់។

ឧបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់
មច្ឆាមច្ឆា ចេញចូលពឹងពាក់ ព្រោះទឹកត្រជាក់
មិនមានហ្មងសៅ។

ពុំគិតឡើយហោង ឯទឹកនោះផង ម្តេចប្រែជាក្តៅ
មច្ឆាទាំងឡាយ ព្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ

ពុំនាក់អាត្មា។

២០. កូនអើយបើច្នោះ អសោចិ៍កេរ្តិ៍នោះ ត្រូវត្រង់ខ្លួនបា
ព្រៀងលានទាំងឡាយ គេនឹងនិន្ទា ដំនៀលដៀលថា
បាឯងពុំចេះ។

អាប់ឥតប្រាជ្ញា អាប់ទាំងឥរិយា យោបល់ចំណេះ
អាប់ទាំងមារយាទ អាប់ទាំងតម្រិះ ត្បិតបាឯងនេះ
ពុំចេះរក្សា។

គណនាដូចទឹក កូនអើយបើល្មឹក ពុំមានមច្ឆា
មួយគ្រាន់ពន្លៀក នៅក្នុងគង្គា ពុំរាប់ហៅជា
ប្រសើរឡើយហោង។

មួយសោតអ្នកណា គេមកប្រាប់ថា បទបាធ្វើឆ្គង
បាគិតជញ្ជឹង រំពឹងដើមទង កុំបាកែងកោង
ក្អេងក្អាងពុំស្តាប់។

ទូកហួសកំពង់ រាចៃវបង្អង់ ថយមកចូលចាប់
ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់
ពុំបានឡើយណា។

២៥. អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់បោយហួសស្មា
ពុំមើលប្រមាណ នឹងប្រាណអាត្មា ហាហួសចង្កា
ថាហួសសេចក្តី។

រីឯកង្កែប មុខដូចគេពេប ហាឡើងស្រដី
អួតឯងកម្លាំង ជល់នឹងដំរី ទោះទាំងរាជសីហ៍
ក៏អញពុំខ្លាច។

មួយសោតចចក ដកកក្ងក អួតឯងអំណាច
នឹងជ្រែកប្រឹថពី ទៅខាំនាគរាជ ដណ្តើមយករាជ្យ
ភូមិភពនាគា។

រីសត្វអណ្តើក វារឡើងរវើក មកអួតអាត្មា
ថាអញនឹងលោត រំលងបព្វតា ហេតុក្តីមោហា
ពុំដឹងខុសគាប់។

រីឯគីង្គក់ លោតឡើងពីភក់ មើលទៅគួរស្អប់
អួតខ្លួនថាល្អ ដូចមាសទឹកដប់ រាងអញចំប្រប់
ដូចរាជសីហា។

៣០. ហាឡើងមិនធ្យាន ស្ដីមិនប្រមាណ នឹងប្រាណអាត្មា
សូវឱនកុំងើប សូវស្មៀមកុំថា សូវវាយកុំយារ
សូវកាប់កុំជេះ។

ឱកូនពន្លក ច្បាប់នេះបាយក ស្ទួនកុំប្រហែស
ច្បាប់នេះប្រសើរ ហៅមហាវិសេស កូនអើយកុំធ្វេស
នឹងច្បាប់នេះណា។

មួយសោតឯល្បែង សប្បាយចង់លេង នឹងមានភ័យា
នឹងកើតទុក្ខក្រោយ នឹងបង់ទ្រព្យា នឹងកើតនិន្ទា
បង់មារយាទគាប់។

សប្បាយធ្វើស្រែ ចម្ការជួយប្រែ នោះមានគេរាប់
សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់
សប្បាយយឺនយូរ។

មួយសោតឯស្រី ចេះលើកយសប្ដី ចេះគិតចេះគូរ
ចេះរៀបចេះចំ ចេះសមចេះគួរ អ្នកផងនឹងសួរ
រកឈ្មោះពុំខាន។

៣៥. នាងនេះឈ្មោះអ្វី មុខមាត់ប្រិមប្រិយ សមជាអ្នកមាន
ម្លោះហើយនឹងកើត ទ្រព្យផងពុំខាន ព្រោះពាក្យសន្ដាន
ព្រេងលានគេទាយ។

រីឯពាក្យមនុស្ស ពុំដែលនឹងខុស ហួសពីទំនាយ
ពុំដែលនឹងល្មៀង មិនជិតមិនឆ្ងាយ អ្នកផងទាំងឡាយ
គួរគិតកុំឆ្ងល់។

ពាក្យព្រេងលោកថា លោកមានឧបមា ឱយគិតឱយយល់
ពាក្យលោកទំនឹម មិនមានឱយសល់ កូនអើយកុំឆ្ងល់
នឹងពាក្យនេះណា។

កុំអួតកុំអាង ដើរកុំមើលរាង មើលអង្គអាត្មា
កុំដើរផ្ទះគេ ហួសពេលវេលា កូនទៅធានា
ទ្រព្យគេទាំងឡាយ។

កុំដេកផ្កាប់មុខ កុំដើរពានថ្លុក ជាឯងសប្បាយ
មានទោសនឹងគេ កុំឱយនិយាយ ដើមគេនឹងក្លាយ
កើតទោសទៀតធំ។

៤០. ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ

ចាស់កោងកាន់ច្រត់ អួតអាងប្រគំ ក្ងួរអួតផ្ទុំ
ប៉ីពកយកខ្យល់។
ខ្ទាក់ផ្លុះកញ្ជាក់ ដកកក្ងក់ ហាក់ឯងមើលយល់
ខ្វិនអួតនឹងផ្លោះ រំលងលើគល់ គំពែករកកល
ចង់បានប្រេងលាប។
ក្មេងចង់រាំ ក្រោកឡើងទន្ទាំ កែងកោងអាបឡាប
ថ្លង់ចង់ស្តាប់ច្រៀង ផ្ទៀងផ្ទងទន់ទាប ដៃតូចខ្លួនទាប
ចង់ឈោងចាប់ផ្កាយ។
កូនអើយចូរស្តាប់ ពាក្យនេះមហាគាប់ គ្រប់តួទាំងឡាយ
បានគិតរំពឹង ជញ្ជឹងឱយឆ្ងាយ កុំធ្វើរាយមាយ
នឹងច្បាប់នេះណា។
មួយសោតគេប្រាប់ ថាបាពុំគាប់ ទោសដល់អាត្ម
កុំបាភិតភាំង ស្លុតស្លាំងកាយា ប្រាណប្រុងឥរិយា
ស្មារតីឱយនឹង។

៤៥. រិះរកគំនិត ភ្ញុំយោបល់គិត ទង់ទាញសន្ទឹង
ប្រាជ្ញាមួយកាត់ ចាត់ឡើងឱយដឹង ចំណេះមួយរឹង
ធ្វើហាក់មិនភ្លឹក។
កូនអើយលោកថា ពាក្យលោកឧបមា ដូចគុជសារសឹក
កាំភ្លើងដៃដុំ ពុំដែលនឹងភ្លឹក ជញ្ជួចគគឹក
គគុកបោលចូល។
ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្តានត្រកូល
ឱយគិតឱយដឹង រំពឹងឱយមូល ប្រាជ្ញាឱយចូល
ចងចាំទុកនៅ។
កុំអួតកុំអាង កុំភូតបំព្រាង កុំឱយចៃចូវ
កុំកាច់កុំកិន រអែរអូវ កុំនាំពាក្យទៅ
ប្រាប់ឱយកើតទោស។
កុំវេះកុំវៀន កុំបៀតកុំបៀន កុំស្តីតោសម៉ោស
គ្នាបានជាខុស ឱយមានសន្តោស កុំហាឱយហួស
ជ្រួសពាក្យទៅមុខ។

៥០. ចូលសឹកកុំញោច ជំពាក់កុំបោច ខ្វិលកុំចងពន្ធ
ជាគ្រូអាត្មា កុំឱយលោកអន់ សេចក្តីទម្ងន់

| | | | |
|---|---|---|---|
| | | សន្សឹមកុំបោល។ | |
| | កុំអួតកម្លាំង | កុំអាងខ្លួនខ្លាំង | រកនឹងស្រមោល |
| | កុំអាងជាធំ | កុំងាយពាក្យពោល | ពាក្យព្រេងកុំចោល |
| | | កុំថ្កោលទោសសង្ឃ។ | |
| | កុំចោលផ្លូវវៀច | កុំអាងអំណាច | ដើរកាត់តម្រង់ |
| | ក្រែងបង់ឥរិយា | សក្កាពុំគង់ | លោកហៅថាល្ងង់ |
| | | អាប់ឥតប្រាជ្ញា។ | |
| | កូនអើយចូរស្តាប់ | ពាក្យមួយមហាគាប់ | មានមិត្តស្នេហា |
| | ឱយមើលមារយាទ | មើលសព្វឥរិយា | ឱយដឹងថាជា |
| | | ជាកាចវៀចត្រង់។ | |
| | ឱយសមឱយសួន | ឱយល្អមនឹងខ្លួន | ឱយធួននឹងអង្គ |
| | សឹមយកជាមិត្ត | បិតថេរដ៏លង់ | ទៅមកតម្រង់ |
| | | ចេញចូលស៊ីចុក។ | |
| ៥៥. | មិត្តមួយសោតណា | ទៅមកកាន់គ្នា | បង្កើតឱយសុខ |
| | មិត្តមួយឱយទោស | បង្កើតជាទុក្ខ | មិត្តមួយឱយផុក |
| | | ឱយបង់ទ្រព្យា។ | |
| | មិត្តមួយបង្ហិន | ទៅមកខ្ពាន់ៗ | ជក់ថ្នាំស៊ីស្លា |
| | ចុះឡើងឥតអាក់ | នឹងហិនអាត្មា | កូនអើយលោកថា |
| | | អសារបង់ទ្រព្យ។ | |
| | ឱកូនពិសី | កូនប្រុសកូនស្រី | ស្ងួនអើយបាស្តាប់ |
| | ទំនឹមទំនង | គន្លងផ្លូវច្បាប់ | ទុកជាសណ្តាប់ |
| | | នៃនរជនជាតិ។ | |
| | មួយសោតលោកថា | ឬកក្នុងអាត្មា | មានបីពុំឃ្លាត |
| | មួយស៊ីមួយដេក | មួយដើរជាខ្នាត | ស៊ីឥតមារយាទ |
| | | ពុំត្រូវសណ្តាប់។ | |
| | ដេីឥតបើគិត | ដើរឥតគំនិត | ហៅខុសនឹងច្បាប់ |
| | ដេកដល់ថ្ងៃរះ | ហៅឥតគំនាប់ | ចង្រៃអភ័ព្វ |
| | | នឹងអាប់អាត្មា។ | |
| ៦០. | នឹងស្វែងរកទ្រព្យ | ចង្រៃអភ័ព្វ | មិនឱយជំនា |
| | ឱយកើតតែទុក្ខ | ឱយបង់ទ្រព្យា | នឹងរកភរិយា |
| | | ហាក់ដូចគេណាយ។ | |

| | | | |
|---|---|---|---|
| | ព្រោះក្ដីអភ័ព្វ | ចង្រៃនូវអព- | មង្គលទាំងឡាយ |
| | ចូលក្នុងអាត្មា | មិនមានទៅឆ្ងាយ | ជ្រាបជ្រៅក្នុងកាយ |
| | | ក្នុអង្គអាត្មា។ | |
| | ទោះប្រុសទោះស្រី | បើមានប្ញកបី | ដូចច្បាប់លោកថា |
| | ប្ញកដេកប្ញកដើរ | ប្ញកស៊ីអាហារ | ជាអ្នករក្សា |
| | | តវិយាមារយាទ។ | |
| | ខ្លាចមេខ្លាចបា | ទោះបីធ្វើការ | មិនមានឱយឃ្លាត |
| | ទោះបីនឹងសើច | នឹងលេងមានខ្នាត | ជាអ្នកសង្វាត |
| | | ខ្មីឃ្នាតធ្វើការ។ | |
| | អ្នកផងទាំងឡាយ | ទោះជិតទោះឆ្ងាយ | គេយល់តវិយា |
| | គេយល់ចំណេះ | ជាអ្នករាបសា | គេចង់ចងជា |
| | | ពន្ធយកជាញាតិ។ | |
| ៦៥. | មានឧ្យត់ពុំគិត | យកតែគំនិត | យកតែមារយាទ |
| | ឱយចេះរៀបចំ | ទុកដាក់ជាខ្នាត | ឧស្សាហ៍សង្វាត |
| | | រក្សាទ្រព្យា។ | |
| | វីម្ដាយឱពុក | នឹងបានលើកមុខ | ដោយកូនពុំងា |
| | អស់ទាំងបងប្អូន | ជីដូនជីតា | ម្ដាយមីងនូវមា |
| | | សឹងស្រួលចូលចិត្ត។ | |
| | ត្បិតកូនសុភាព | ជាអ្នករាបទាប | ត្រូវនឹងគំនិត |
| | គ្រប់អស់បងប្អូន | ទោះឆ្ងាយទោះជិត | សឹងបានដូចចិត្ត |
| | | ដូចដួងចិន្ដា។ | |
| ៨៨. | កូនអើយចូរស្ដាប់ | ចូរចាំឱយខ្ជាប់ | ទុកក្នុងអាត្មា |
| | ទំនឹមទំនង | គន្លងឧបមា | បទចងប្រៃជា |
| | | បទព្រហ្មគីតិ។ | |

១. កូនអើយសួនតែមួយ ទុកជាត្រួយត្រូលគំនិត
កូនអើយមាសតាំងចិត្ត តាំងចរិតគិតកុំឆ្វល់។
ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសគិតឱយដល់
ពាក្យលោកតែងខ្វាយខ្វល់ ជាបឋមចប់ម្ល៉េះហោង។

# ច្បាប់កូនចៅល្បើក

## បទកាកគតិ

១. នេះបទកាកគតិ[១] ទើបចងជាបទ ជាច្បាប់ទូន្មាន
តាមដោយគន្លង ព្រេងព្រឹទ្ធបុរាណ អ្នកប្រាជ្ញនិទាន
ប្រដៅបុត្រភ្លា។

ហៃកូនពន្លក ស្ងួនអើយមាសយក បណ្ដាំបិតា
ឪពុកនេះចាស់ ឥតអ្វីឱយបា ស្ងួនអើយរក្សា
ពាក្យឪពុកនៅ។

ឱកូនកំសត់ រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ
រៀនឱនលំទោន កុំឱយហ្មងសៅ ដល់ខ្លួនកូនពៅ
កេរ្តិ៍ដល់ឪពុក។

ដឹងឆ្លើយត្បិតផង កូនសើចរវែងឆ្គង ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី ចេះរៀបដាក់ទុក ប្រះដេកឆាប់លក់
ត្បិតឥតបើគិត។

៥. ចំណោះទាំងឡាយ កិច្ចកលដោះស្រាយ ត្បិតតែគំនិត
ដឹងកិច្ចដឹងកល ដឹងឆ្ងាយដឹងជិត ដូចកលកាំបិត
កាប់ឆ្ការទំលាយ។

ល្មមទៅល្មមខាន ល្មមដើរបំពាន ពុំគិតក្រងាយ
ល្មមគិតបង្អង់ ល្មមខាននៅអាយ ក្ដីក្រកុំស្រាយ
ក្ដីជាកុំធ្វេស។

សូវដើរកុំដេក សូវចប់កុំគ្រេក សេចក្ដីប្រហែស
សូវខានកុំពារ ចចើងចចេស សូវចូលកុំចៀស
វាសរួចសឹមគួរ។

លឿនកុំបំបោល ពាក្យព្រេងកុំចោល ខឹងកុំអ៊ូទ្រូ
ស្រាយចេញឱយឆាប់ កុំឱយទុកយូរ សេចក្ដីមូទូ
មិនគិតខុសត្រូវ។

(១) *ត្រូវអានសម្រួលតាមជើងកាព្យថា ៖ នេះបទកាកគតិ ។*

ដេកកុំដំដើច គេក្រកុំសើច គេភ័យកុំព្យួហ៍
ទោះខឹងប៉ុន្មាន ធ្វើជាឱយគួរ តឹងគិតឱយធូរ
យូរគិតឱយឆាប់។

១០. សេចក្ដីបម្រុង ពាក្យដើមពាក្យចុង ប្រកាន់ឱយខ្ជាប់
សូវនឿយខ្លួនឯង កុំឱយបង់ទ្រព្យ
សូវបង់ក្ដីគាប់
កុំឱយខ្លួនស្លាប់។

សូវស្លាប់ទៅជា កុំបង់ធម្មា តរិយាសីលគាប់
ឱយដឹងជញ្ជឹង រំពឹងឱយសព្វ ពាក្យស្លែងកុំស្អប់
ពាក្យគាប់ឱយយក។

ចង់គង់ឱយទុក ចង់បានក្ដីសុខ ឱយស្វែងដើររក
ឃើញច្បាប់ធម៌ផង ឱយយកខ្លួនជ្រក ក្ដីសោកមម៉ោក
ឱយចៀសចេញឆ្ងាយ។

កូនអើយលោកិយ នេះឱយរៀនក្ដី រៀនច្បាប់ទាំងឡាយ
រៀនទាំងសម្ដិ កុំបីរាយមាយ ក្ដីក្រក្ដីងាយ
ក្ដីគួរក្ដីសម។

ឱកូនពុំងា ធម្មតាអ្នកជា ឱយរៀនថៃទាំ
រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ
លក់ចេញទិញចូល។

១៥. មួយសោតឯច្បាប់ បើបាមានទ្រព្យ
មនុស្សផងមកចូល
ពឹងពាក់ប្រាណណា បាយកប្រមូល សន្សំផ្សំចូល
យកមកជាគ្នា។

កូនអើយឯម្លប់ មនុស្សផងចូលឈប់ សម្រាន្តអាត្មា
ព្រៃឈើជាម្លប់ ត្រសុំសាខា ម្ដេចឡើយប្រែជា
ក្ដៅជ្រកពុំបាន។

មនុស្សផងរំលង រកម្លប់ទៀតហោង ចូលចតសម្រាន្ត
ម្លប់នោះត្រជាក់ ត្រសាក់ក្បែមក្សាន្ត មនុស្សផងចូលថ្កាន
មិនមានហៅអាក់។

ឧបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់
មច្ឆោមច្ឆា ចេញចូលពឹងពាក់ ព្រោះទឹកត្រជាក់

មិនមានហ្មងសៅ។
ពុំគិតឡើយហោង ឯទឹកនោះផង ម្ដេចប្រែជាក្ដៅ
មច្ឆាទាំងឡាយ ព្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ
ពំនាក់អាត្មា។

២០. កូនអើយថាបើ បាឯងអាចធ្វើ ក្ដីក្ដាត់មហិមា
ព្រៀងលានទាំងឡាយ គេនឹងនិន្ទា ដំនៀលដៀលថា
បាឯងពុំចេះ។

អាប់ឥតប្រាជ្ញា អាប់ទាំងឥរិយា យោបល់ចំណេះ
អាប់ទាំងមារយាទ អាប់ទាំងតម្រិះ ត្បិតបាឯងនេះ
ពុំចេះរក្សា។

គណនាដូចទឹក កូនអើយបើល្ងឹក ពុំមានមច្ឆា
មួយគ្រាន់ពន្លៀត នៅក្នុងគង្គា ពុំរាប់ហៅជា
ប្រសើរឡើយហោង។

មួយសោតអ្នកណា គេមកប្រាប់ថា ត្បិតបាធ្វើឆ្គង
បាគិតជញ្ជឹង រំពឹងដើមទង កុំបាតោតតូង
ក្មេងក្មាងពុំគាប់។

ទូកហួសកំពង់ វាចៃវបង្អង់ ថយមកចូលចាប់
ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់
ពុំបានឡើយណា។

២៥. អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់បោយហួសស្មា
ពុំមើលប្រមាណ នឹងប្រាណធម្មតា ហាហួសចង្កា
ថាហួសសេចក្ដី។

រីឯកង្កែប មុខដូចគេពេប ហាឡើងស្រដី
អួតឯងកម្លាំង ជល់នឹងដំរី ទោះទាំងរាជសីហ៍
ក៏អញមិនខ្លាច។

មួយសោតចចក ដកកកភ្ញក់ អួតឯងអំណាច
នឹងជ្រែកប្រឹថពី ទៅខាំនាគរាជ ដណ្ដើមយករាជ្យ
ភូមិភពនាគា។

រីឯអណ្ដើក វារឡើងរើក មកអួតអាត្មា
ថាអញនឹងលោត រំលងបព្វតា ហេតុអ្វីមាហោ
ពុំដឹងខុសគាប់។

| | | | |
|---|---|---|---|
| | រីឯគីង្គក់ | លោតឡើងពីភក់ | មើលទៅគួរស្អប់ |
| | អួតខ្លួនថាល្អ | ដូចមាសទឹកដប់ | រាងអញចំប្រប់ |
| | | ដូចរាជសីហា។ | |
| ៣០. | ហាឡើងមិនធ្យាន | ស៊ីមិនប្រមាណ | នឹងអង្គអាត្មា |
| | សូវឱនកុំងើប | សូវស្មៀមកុំថា | សូវវាយកុំយារ |
| | | សូវកាប់កុំជេះ។ | |
| | ឱកូនពន្លក | ច្បាប់នេះបាយក | ស្ងួនពុំប្រហែស |
| | ច្បាប់នេះប្រសើរ | ហៅមហាវិសេស | កូនអើយកុំធ្វេស |
| | | នឹងច្បាប់នេះណា។ | |
| | មួយសោតឯល្បែង | សប្បាយចង់លេង | នេះឯងលោកថា |
| | នឹងកើតទុក្ខក្រោយ | នឹងអស់ទ្រព្យា | នឹងកើតនិន្ទា |
| | | បង់មារយាទគាប់។ | |
| | សប្បាយធ្វើស្រែ | ចំការជួញប្រែ | នោះមានគេរាប់ |
| | សប្បាយបានស៊ី | សប្បាយបានទ្រព្យ | សប្បាយនោះគាប់ |
| | | សប្បាយយឺនយូរ។ | |
| | មួយសោតឯស្រី | ចេះលើកយសប្តី | ចេះគិតចេះគួរ |
| | ចេះរៀបចេះចំ | ចេះសមចេះគួរ | អ្នកផងនឹងសួរ |
| | | រកឈ្មោះពុំខាន។ | |
| ៣៥. | នាងនេះឈ្មោះអ្វី | មុខមាត់ប្រិមប្រិយ | សមជាអ្នកមាន |
| | ម្លោះហើយនឹងកើត | ទ្រព្យផងពុំខាន | ព្រោះពាក្យសន្តាន |
| | | ព្រៀងលានគេទាយ។ | |
| | រីឯពាក្យមនុស្ស | ពុំដែលនឹងខុស | ហួសនឹងទំនាយ |
| | ពុំដែលនឹងផ្អៀង | មិនជិតមិនឆ្ងាយ | អ្នកផងទាំងឡាយ |
| | | គួរគិតកុំឆ្ងល់។ | |
| | ពាក្យព្រេងលោកថា | លោកនឹងឧបមា | ឱយគិតឱយយល់ |
| | ពាក្យលោកទំនឹម | មិនមានឱយសល់ | កូនអើយកុំឆ្ងល់ |
| | | នឹងពាក្យនេះណា។ | |
| | កុំអួតកុំអាង | ដើរកុំមើលរាង | មើលអង្គអាត្មា |
| | កុំដើរផ្ទះគេ | ហួសពេលវេលា | កុំទៅធានា |
| | | ទ្រព្យគេទាំងឡាយ។ | |
| | កុំដេកផ្កាប់មុខ | កុំដើរពានថ្លុក | ថាឯងសប្បាយ |

មានទោសនឹងគេ កុំឱយនិយាយ ដើមគេនឹងក្លាយ<br>
កើតជាទោសធំ។

៤០. ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ<br>
ចាស់កោងកាន់ច្រត់ អួតអាងប្រគំ ក្លូរអួតផ្លុំ<br>
ប៉ីពកយកខ្យល់។

ខ្វាល់ឆ្លុះកញ្ចាក់ ដកកក្ងក់ ហាក់ឯងមើលយល់<br>
ខ្ញិនអួតនឹងផ្លោះ រំលងលើគល់ តំពែករកកល<br>
ចង់បានប្រេងលាប។

ក្មេងចង់រាំ ក្រោកឡើងទន្ទាំ គេងកោងអាបឡាប<br>
ថ្លង់ចង់ស្តាប់ច្រៀង ផ្អៀងផ្អងទន់ទាប ដៃតូចខ្លួនទាប<br>
ចង់ឈោងចាប់ផ្កាយ។

កូនអើយចូរស្តាប់ ពាក្យនេះមហាគាប់ គ្រប់តួទាំងឡាយ<br>
បាគិតរំពឹង ជញ្ជឹងឱយឆ្ងាយ កុំធ្វើវាយមាយ<br>
នឹងច្បាប់នេះណា។

មួយសោតគេប្រាប់ ថាបាពុំគាប់ ទោសដល់អាត្មា<br>
កុំបាភិតភាំង ស្លុតស្លាំងកាយា ប្រាណប្រុងឥរិយា<br>
ស្មារតីឱយនឹង។

៤៥. រិះរកគំនិត ជុំយោបល់គិត ទង់ទាញសន្ទឹង<br>
ប្រាជ្ញាមួយកាត់ ចាត់ឡើងឱយដឹង ចំណេះមួយនឹង<br>
ធ្វើហាក់មិនភ្លឹក។

កូនអើយលោកថា ពាក្យលោកឧបមា ដូចគជសារសឹក<br>
កាំភ្លើងដៃជុំ ពុំដែលនឹងភ្លឹក ដេញដាលគគឹក<br>
គគុកបោលចូល។

ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្តានត្រកូល<br>
ឱយគិតជញ្ជឹង រំពឹងឱយមូល ប្រាជ្ញាឱយចូល<br>
ចងចាំទុកនៅ។

កុំអួតកុំអាង កុំភូតបំព្រាង កុំឱយចៃចូវ<br>
កុំកាច់កុំកិន រអែររអូវ កុំនាំពាក្យទៅ<br>
ប្រាប់ឱយកើតទោស។

កុំវៀសកុំវៀន កុំបៀតកុំបៀន កុំស្តីឱយមោះ<br>
គ្នាបានជាខុស ឱយមានសន្តោស កុំហាឱយហួស

ជ្រួសពាក្យទៅមុន។

៥០. ចូលសឹកកុំញោច ជំពាក់កុំបោច ខ្ជិលកុំចងពន្ធ
ជាគ្រូអាត្មា កុំឱយលោកអន់ សេចក្ដីទម្ងន់
សន្សឹមកុំបោល។

កុំអួតកម្លាំង កុំអាងខ្លួនខ្លាំង រត់នឹងស្រមោល
កុំអាងជាធំ កុំងាយពាក្យពោល ពាក្យព្រេងកុំចោល
កុំថ្កោលទោសសង្ឃ។

កុំចោលផ្លូវវៀច កុំអាងអំណាច ដើរកាត់តម្រង់
ក្រែងបង់តរិយា សក្ដាពុំគង់ លោកហៅថាល្ងង់
អាប់ឥតប្រាជ្ញា។

កូនអើយចូរស្ដាប់ ពាក្យមួយមហាគាប់ មានមិត្រស្នេហា
ឱយមើលមារយាទ មើលសព្វតរិយា ឱយដឹងជាក់ជា
ជាកាចវៀចត្រង់។

ឱយសមឱយសួន ឱយល្មមនឹងខ្លួន ឱយធួននឹងអង្គ
សឹមយកជាមិត្ត ស្និតស្នេរដ៏លង់ ទៅមកតម្រង់
ចេញចូលស៊ីចុក។

៥៥. មិត្រមួយសោតណា ទៅមកកាន់គ្នា បង្កើតឱយសុខ
មិត្រមួយឱយទោស បង្កើតជាទុក្ខ មិត្រមួយឱយធុក
ឱយបង់ទ្រព្យា។

មិត្រមួយបង្អិន ទៅមកខ្នាន់ៗ ជក់ថ្នាំស៊ីស្លា
ចុះឡើងមិនអាក់ នឹងហិនអាត្មា កូនអើយលោកថា
អាសារបង់ទ្រព្យ។

ឱកូនពិសី កូនប្រុសកូនស្រី ស្ងួនអើយបាស្ដាប់
ទំនឹមទំនង គន្លងផ្លូវច្បាប់ ទុកជាសណ្ដាប់
នៃនរជនជាតិ។

មួយសោតលោកថា ឫកក្នុងអាត្មា មានបីពុំឃ្លាត
មួយស៊ីមួយដេក មួយដើរឥតខ្នាត ស៊ីឥតមារយាទ
ពុំត្រូវសណ្ដាប់។

ដើរឥតបើគិត ដើរឥតគំនិត ហៅខុសនឹងច្បាប់
ដេកដល់ថ្ងៃរះ ហៅឥតគំនាប់ ចង្រៃអភ័ព្វ
នឹងអាប់អាត្មា។

៦០. នឹងស្វែងរកទ្រព្យ ចង្រៃអភ័ព្វ មិនឱយជំនា
ឱយកើតតែទុក្ខ ឱយបង់ទ្រព្យា កម្ទិលសោះសា
ហាក់ដូចគេណាយ។

ព្រោះក្ដីអភ័ព្វ ចង្រៃនូវអព- មង្គលទាំងឡាយ
ចូលក្នុងអាត្មា មិនមានទៅឆ្ងាយ ជ្រាបជាប់ក្នុងកាយ
ក្នុងអង្គអាត្មា។

ទោះប្រុសទោះស្រី បើមានឫកបី ដូចច្បាប់លោកថា
ឫកដើរឫកដេក ឫកស៊ីអាហារ ជាអ្នករក្សា
ឥរិយាមារយាទ។

ខ្លាចមេខ្លាចបា ទោះបីធ្វើការ មិនមានឱយឃ្លាត
នាបីនឹងសើច នឹងលេងមានខ្នាត ជាអ្នកសង្វាត
ខ្មីឃ្មាតធ្វើការ។

អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយល់ឥរិយា
គេយល់ចំណេះ ជាអ្នករាបសា គេនឹងចងជា
ពន្ធយកជាញាតិ។

៦៥. មានខ្សត់ពុំគិត យកតែគំនិត ឥរិយាមារយាទ
ឱយចេះរៀបចំ ទុកដាក់ជាខ្នាត ឧស្សាហ៍សង្វាត
រក្សាទ្រព្យា។

រីម្ដាយឪពុក នឹងបានលើកមុខ ដោយកូនពុំងា
អស់ទាំងបងប្អូន ជីដូនជីតា ម្ដាយមីងនូវមា
សឹងស្រួលចូលចិត្ត។

ត្បិតកូនសុភាព ជាអ្នករាបទាប ត្រូវនឹងគំនិត
គ្រប់អស់បងប្អូន ទោះឆ្ងាយទៅជិត សឹងបានដូចចិត្ត
ដូចដួងចិន្ដា។

៦៨. កូនអើយចូរស្ដាប់ ចង់ចាំឱយខ្ជាប់ ទុកក្នុងអាត្មា
ទំនឹកទំនង គន្លងឧបមា ទើបចងប្រែជា
ជាបទព្រហ្មគីតិ។

❋ ✿ ❋

# បទព្រហ្មគីតិ

១.　ឱកូនស្ងួនតែមួយ　　　ទុកជាត្រួយត្រួលគំនិត
កូនអើយមាសតាំងចិត្ត　　　តាំងចរិតគិតឱយឆ្ងល់។
ពាក្យចាស់ពាក្យពីព្រេង　　　ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់　　　រមិលយល់ប៉ុនទាំងភ្នំ។
ចូលព្រៃសត្វសាហាវ　　　រកអំពាវគ្នាមកជុំ
ដល់បានស្ករទឹកឃ្មុំ　　　ពួកក្នុងផ្ទះស៊ីម្នាក់ឯង។
បានហើយចង់បានទៀត　　　ខំឆ្លៀតបៀតមិនគិតក្រែង
មើលយល់តែខ្លួនឯង　　　មិនយល់គេឯទៀតផង។
៥.　នឹងស៊ីចង់ពិសា　　　ខ្ជិលទំបាឱយហ្មត់ហ្មង
យល់នាមថាជាមង　　　យល់ឯជងថាជាភ្លួយ។
យល់តាថាជាដូន　　　យល់ឯកូនថាជាក្មួយ
យល់ពីរថាជាមួយ　　　យល់ឯព្រួយថាជាសុខ។
យល់ទោសថាជាគុណ　　　យល់ឯបុណ្យថានរក
យល់ល្អថាអាក្រក់　　　យល់លាមកថាជាផ្កា។
ស្លៀកស្បង់មិនកោរសក់　　　ឆ្លុះកញ្ចក់ធ្មេចនេត្រា
យល់សេះថាជាលា　　　យល់គជាថាកណ្ដុរ។
នេះពាក្យលោកពីព្រេង　　　អ្នកណាឈ្វេងប្រាជ្ញាយល់
ឃើញថ្លុកកុំថាថ្នល់　　　ក្រែងកំហល់កំហុសមាន។
១០.　អ្នកប្រាជ្ញកាន់ពាក្យទៀង　　　កុំឱយល្មៀងពាក្យបុរាណ
កុំដើរផ្លូវបំពាន　　　ពាក្យអ្នកចាស់លោកដៀលថា។
ពាក្យនេះពីព្រេងព្រឹទ្ធ　　　គួរឱយគិតពិចារណា
កុំអួតអាងអាត្មា　　　ថាចំណេះចំណាំមាន។
ដេកយប់កុំដេកថ្ងូរ　　　ខ្លាចក្ដីទូជំនដល់ប្រាណ
បើស៊ីកុំតាមឃ្លាន　　　មើលប្រមាណអស់គ្នីគ្នា។
លើកដាក់តាមកម្លាំង　　　កុំភើចខ្លាំងឈឺដល់ស្មា
ប្រើគេប្រើឱយជា　　　កុំសសន់រាន់សៅដៅ។
ទោះដើរកុំរួសរាន់　　　គិតឱយគ្រាន់សឹមដើរទៅ

កុំឱយអាប់អាស្រូវ កើតដំណៀលដល់អាត្មា។
១៥. កុំយល់ឆ្អិនជាឆៅ កិច្ចក្នុងក្រៅមានតម្រា
កុំអាងតែប្រាជ្ញា ចោលក្បួនច្បាប់លោកព្រេងនាយ។
ស្រដីឱយស្រួលស្រេច គឺតសេចក្រេចកុំគិតងាយ
រំពឹងគិតឱយឆ្ងាយ យល់លង្វែកសព្វនានា។
ពាក្យព្រេងលោកស្រដី ថាកុំបីចិញ្ចឹមខ្លា
ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱយបាន។
កាន់ ក ពស់ឱយខ្ជាប់ ខ្លាចក្រឡាប់ខាំងប្រាណ
អូសទូកកុំឱយល្អាន ទឹកថ្លាសោតកុំឱយល្អក់។
ស្លឹកឈើឥតកម្រើក បើកក្រើកត្បិតខ្យល់បក់
ទឹកថ្លាល្អឹកបើល្អក់ ត្បិតរលកខ្លាំងសោះសា។
២០. យល់តូចកុំអាលខំ គួរសន្សំយកជាគ្នា
បានច្រើនកុំអាលពារ សន្សំតិចៗរៀងទៅ។
អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ
អ្នកឆ្អែករក្សាឃ្លាន នាអ្នករុងរក្សាឆ្មារ។
រក្សាទៅមករឹង ឥតកំដឹងអស់អម្បាល
ចំណោរចេរកាន់កាល ដូចរបងស្រាស់បន្លា។
កុំឆីឆ្អែតតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានក្នុងផ្ទៃផ្សា ឱយឆីរ៉ាបានឆ្អែតផង។
២៦. កុំមានចិត្តលលើ ពឹងក្រពើឱយចម្លង
កុំកាប់ឧសរបង វាំងចំណាររងអាត្មា។
មានទូកឱយមានថ្នោល មានបង្គោលមានយុថ្កា
ទាំងពួរទាំងច្រវា ជើងថៃវណ៌ាឱយសព្វគ្រប់។
ប្រយ័ត្នក្រែងព្យុះខ្យល់ បក់បោកដល់នឹងទល់ទប់
ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាក់ជាគំនិត។
ពាក្យព្រេងគិតគួរចាំ ដូចបណ្ដាំបណ្ដៅចិត្ត
ពាក្យព្រេងគួរឱយគិត គិតរំពឹងឱយគ្រប់គ្រាន់។
ពាក្យនេះជាសណ្ដាប់ ទុកជាច្បាប់ទៀងជាក់ស្បាន់
ពាក្យនេះជាកំណាន់ កំណត់នៅពុំឃ្លាតឃ្លា។

៣០. តែងតពាក្យទៅទៀត កុំបៀនបៀតអ្នកព្រឹទ្ធា
កុំសង់ផ្ទះបៀតផ្លា ស្រីសាធារណ៍ពុំគង់ទ្រព្យ។
ស្រីស្រាលខ្លៅប្រច័ណ្ឌ ស្ដីជញ្ជូនថាពុំគាប់
ពាក្យនេះឥតគេរាប់ ពាលរែងស្ដាប់ពាក្យមេបា។
ប្រទ្បែងរែងច្រើនឈ្លោះ ពាក្យទ្រគោះច្រើនគេថា
កំណាញ់កើតនិន្ទា នឹងសាធារណ៍ពុំគង់ទ្រព្យ។
កូនកាចរែងចាញ់ម្ដាយ ពាក្យពាយងាយគេរែងស្ដាប់
ខ្ចីទ្រព្យគេកញ្ចប់ រកគេទៀតគេថាគ្មាន។
អ្នកទាបរែងស្ដាប់ខ្ពស់ ត្បិតពឹងយសគេពុំបាន
អ្នកខ្សត់ស្ដាប់អ្នកមាន ត្បិតពុំបានឱយពឹងទ្រព្យ។
៣៥. អ្នកខ្លៅរែងស្ដាប់ចេះ ត្បិតតម្រិះគិតគំនាប់
អ្នកខុសរែងស្ដាប់គាប់ ត្បិតគេរាប់តែអ្នកត្រូវ។
ពាក្យនេះអស់ម្លេះហើយ កូនចៅអើយយកទុកទៅ
គ្រាន់បានប្រៀនប្រដៅ តកូនចៅផៅសន្ដាន។
ពាក្យនេះស្មើខ្លួនហើយ កូនចៅអើយចូរចាំប្រាណ
អស់អាថ៌ឱយវាទទាន ជាសូវេចម្លេះឯងហោង។

❁ ❉ ❁

# ច្បាប់វិធុរបណ្ឌិត

## បទព្រហ្មគីតិ

១. ព្រះខាន់ហើយឥតស្រោម នាផ្ទៃក្រោមឥតមន្ត្រី
ក្សត្រិយ៍ពុំចេះគម្ពីរ ស្រីឥតគម្លែងក្រឡា។
កើតមកជាបុត្រក្សត្រិយ៍ ពុំប្រយ័ត្នរៀនសាស្ត្រ
ពុំរៀនពិចារណា ពុំដឹងក្រងទុក្ខរាស្ត្រ។
ពុំតម្លើងពាក្យពិត បញ្ញវិធសីលវិនាស
យកគលាយកប្បាស កុំយកមាសលាយនឹងប្រាក់។
ប្រើត្រាប់ឯត្រាជូ កុំបង់ផ្លូវដោយតម្រាស់
កុំជិះរទេះចាស់ បាចសាចខ្សាច់កំបុតត្បូង។
៥. ជាក្សត្រីយ៍ពុំរៀនធម៌ ពុំដោះសាជម្ងឺទ្រូង
រាស្ត្រទាសនឹងចំកោង អាក់ចិត្តខឹងសត្វចោមរោម។
នឹងកើតក្តៅក្រហាយ ទុក្ខអន្តរាយភពផ្ទៃក្រោម
រាស្ត្រផងនឹងខឹងចោម ជ្រោមខ្វាត់ខ្វាយទីទៃណា។
រីមិត្រសង្សារស្នេហ៍ កុំបីប្រែកែពាក្យថា
ស្រាលញ៉នូវសត្យា កុំបីស្អប់ឱយសាមាន្យ។
អ្នកកាចសរពើក្តី សឹងអប្រិយរំជួលប្រាណ
កើតទោសអាត្មាមាន គំនូរខុសជាអសារ។
ទោះឆ្លងព្រះគង្គា សាត់អាត្មាកណ្តាលវាល
ពារសឹកដេញប្រហារ រត់ចេញទៅប្រទះខ្លា។
១០. ប្រទះទាំងទាកឈ្លើង សឹងជាប់ឡើងខាំអាត្មា
ចំរូងច្រូងបន្លា ជាប់ដោយជើងជាន់ជិតដី។
ខ្មោចរក្សាគ្រឹះស្ថាន ទោសនឹងមានភូមិលំនៅ
បិតខ្វែងប្រែក្តាត់ក្តៅ សឹងហ្មងសៅធ្វើទោសយើង។
ទាំងនាយពុំរក្សា បៀនបិណ្ឌាកុំឱយថ្កើង
អស់ញាតិពុំបន្ទើង សឹងរត់ចៀសចេញទៅឆ្ងាយ។
ពឹងថ្នោលៗសោតបាក់ ទូកពំនាក់ភ្លូកព្រាត់ព្រាយ

ពឹងបុណ្យបាបកំចាយ សាត់គឃ្លាយដោយខ្យល់នាំ។
កុំឱយចង្វាចឹក សូវចុះទឹកក្រពើខាំ
អភ័ព្វនៅសាំទាំ ជាទុក្ខសោកនៅស្លេកស្លក់។
១៥. នូវកើតឯហោចហីន ត្រមោចក្សីណរឹងអាក្រក់
អំពើដ៏លាមក នូវកើតទោសជាសាមាន្យ។
ដូចពាក្យនៃមនុស្សផង ស្រដីឆ្គងឥតប្រមាណ
ពោលពាក្យពារបំពាន ពុំរំពឹងឯក្រោយភ្នែក។
ពានរពុំដែលស្មុំត្រ ស្រីសាធស័ក្តិពុំដែលស្រែក
រីឯមៀមនិងក្អែក ពុំដែលរួមទ្រនំគ្នា។
ទោះអ្នកជាតិព្រេងព្រឹទ្ធ ចាំរិះរឹតបុរាណា
គួរចងចិត្តស្នេហា សរពើពិតកេរសព្វស្ថាន។
យកខាលដងសំណេ ដោយចិត្តឆគិតឱយបាន
រលាយឯខាលកាណេ សឹងពុំបានបង់ខាលសោត។
២០. ប្រទះបោះកាំបិត បង់សុចរិតនៃអ្នកឆោត
បង់ពីរប្រការសោត ត្រូវដំនៀលលោកនិន្ទា។
កុំកាន់ពាក្យអសត្យ ប្រុងប្រយ័ត្នអង្គអាត្មា
ដ៏លោកបរលោកា បរិបូណ៌បានសុខសួស្តីហោង។
កុំពោលពាក្យមុសា វាទវាចាឱយមានហ្មង
ចំពួកសត្រូវផង តែងយកទោសនៃអាត្មា។
កុំពោលពាក្យបំពាន តែងនឹងមានតំនៀលថា
ទុយ៌សពិតពុំជា នូវខ្មាសមុខឯងសព្វថ្ងៃ។
យកខ្មោចគេមកយំ មើលផ្សំថ្នាំព្យាធិ៍ហីនហៃ
ពុំនីរពុំប្រពៃ ពុំបានជាប្រយោជន៍អង្គ។
២៥. ធ្វើគុណកើតជាទោស យកឈើល្ងង់ប្រោសក្នុងអន្លង់
យកប៉ុយទៅគ្របភ្លើង គុណប្រឡងអម្បោះផ្កាយ។
អណ្តើកអម្ចាស់មាន ហ៊ានឈ្លានពានយកស្មោរងាយ
ក្រូចជូរពុំជូរក្លាយ ពុំប្រយ័ត្នគេយកបាន។
ហេតុចិត្តពុំគិតថ្មៃ អំពីព្រៃពន់ប្រមាណ
អ្នកថ្លោះយសពីប្រាណ ចិត្តពុំក្សាន្តពុំរសាយ។
អ្នកខ្ជិលចង់តែធី អ្នកអប្រិយគេមើលងាយ
រក្សាច្រើនផាផាយ ទ្រព្យខ្ទាត់ខ្ចាយរង្គោះឡើង។

| | | |
|---|---|---|
| | ដំរីសារចូលទៅ | ក្នុងអំពៅនោះរលើង |
| | ទាំងគុម្ពល្អិតដោយជើង | នៃដំរីសារចូលហោង។ |
| ៣០. | អំពៅអំពល់អស់ | រលើងឫសទាំងគុម្ពផង |
| | ទាំងស្រែចំការគ្រង | ឋានលំនៅឥតអាស្រ័យ។ |
| | អ្នកខ្លាចអួតអាងហ៊ាន | ស្រដីរានពួតជើងដៃ |
| | កំឡាំងមានស្មើថៃ | ទើបបើអួតអាងសាធារណ៍។ |
| | រីឯជាទាហាន | សៀមនៅឋានពុំចរចា |
| | សន្សឹមរកឆីស្លា | លុះសឹកដល់បន្លឺមាត់។ |
| | ដូចស្បែកខ្លាចទូរ | សឹងសាយគួរគង់ពុំបាត់ |
| | កាលស្លាប់គេលះលាត់ | លាយយល់ស្នាត់ដូចដែលហោង។ |
| | ដូចពុតពាលពុំជា | កុំផ្តន្ទាទោសទណ្ឌផង |
| | ចងតប់ដាល់វាយចង | ពុំចេះចោលពុតបាត់បង់។ |
| ៣៥. | ដូចខ្មៀនកន្ទុយឆ្កែ | ទោះនូវប្រែពត់ពុំត្រង់ |
| | យកប្រេងទួនរឹតទង់ | រោលភ្លើងពត់ពុំត្រង់បាន។ |
| | ដូចពុតពាលសក់ឡក់ | ចិត្តអាក្រក់ធ្វើលឹកលាន |
| | យល់ធម៌ដំបូន្មាន | ចិត្តពុំចូលពុំចង់ស្តាប់។ |
| | ទឹកហូរចេញចូលណា | ដោយច្បាប់ថាលោកប្រើត្រាប់ |
| | ជាញាតិសន្តានស្រាប់ | គួរបីត្រាប់អំពើពង្ស។ |
| | អ្នកតូចឥតមេត្រី | ចងជាក្តីមែនគ្នាចង់ |
| | ទ្រព្យធននាយពំគង់ | បទបំណងឯងឱយបាត់។ |
| | ទោះបីយល់គេខុស | កុំប្រទូស្តប្រទះមាត់ |
| | យល់ប្លែកប្រើប្រយ័ត្ន | គួរលែងសាធសេចក្តីធម៌។ |
| ៤០. | ទោះបីជាតិអ្នកចេះ | មានចំណេះអាងដឹងអាថ៌ |
| | ប្រើធ្ងន់ប្រើដោះសា | ដោយសណ្តាប់ព្រះធម៌ស្រាយ។ |
| | រីពាក្យពាលកម្លៅ | ពុំដឹងជ្រៅដោយបរិយាយ |
| | នាំពាក្យទៅនិយាយ | ដើរប្រាប់ប្រាយឱយអប្រិយ។ |
| | អម្ចាស់អ្នកប្រើទៅ | វិលវល់នៅពុំខ្លាចក្តី |
| | ស្វែងទ្រព្យសរពើអ្វី | អង់អាលឆីទ្រព្យសាធារណ៍។ |
| | ប្រើទៅជារាជទូត | ចិត្តពុំស្លូតធ្វើក្រៅសារ |
| | ចេះចាំនូវអស់អាថ៌ | ជារាជសារទូរាគមន៍។ |
| | ជារាជបុរោហិត | រាជបណ្ឌិតគ្រូហោរធម |

ពុំមានប្រព្រឹត្តក្រម	លោកក្រៃលែងអ្នកសាមាន្យ។
៤៥. ទោះគេស្រឡាញ់ហោង	ប្រើចេះស្នងស្រឡាញ់ថ្កាន
បណ្តាលហឫទ័យក្សាន្ត	សមស្នេហាមិត្រមេត្រី។
ទោះចេះក្តីកិច្ចកល	ប្រើចេះយល់អាថ៌នោះមិញ
អប្រិយប្រើចៀសចេញ	ទូរទីឆ្ងាយឱយបាត់ដាន។
ពុំគួរយកខ្លួនគប់	គួរតែស្អប់ហេតុសាមាន្យ
កុំសេពអាស្រូវប្រាណ	ពាក្យដំនៀលត្រូវឯភ្នែក[១]
កុំយកពងមាន់ធ្វើ	ឰដ៏លើសំបុកក្អែក
អ្នកដំកុំធ្វើដែក	អ្នកប្រមឹកកុំធ្វើស្រា។
កុំបីយកសំរិទ្ធ	ធ្វើអ្នកស្មិតនោះពុំជា
រីឯអ្នកចំការ	កុំយកគ្រាប់ត្រសក់ធ្វើ។
៥០. ទោះស្រូវភោជ្ជសាលី	ទុកកុដុម្ពីក៏នោះឃាត់ប្រើ
កុំមានចិត្តសើរើ	យកមកធ្វើនៅជលស័យ។
បញ្ញើប្អូនប្រការ	ពិចារណាឱយអស់ក្តី
កុំមានពាក្យអប្រិយ	ខ្លាចចំណោរដំនៀលថា។
កាលក្អែកចេញឆីលុះ	រាត្រីនោះមៀមកោក្កា
មានសឹករកអាសា	ទៀបអាត្មាកុំឃ្លាតឆ្ងាយ។
ទឹកឡើងស្រមោចលង់	លុះចំណង់ត្រីសប្បាយ
ស្រមោចក៏អន្តរាយ	លុះចំណោរចំណាប់ល្អ។
លុះទឹករីងស្ងួតទៅ	ត្រីផងនៅអាត្មាមរណ៍
អនេកអនន្តរ	លុះចំណោរស្រមោចស្នង។
៥៥. នេះមានពៀរវេរា	ពីបុរាបុរាណហោង
សព្វឋានកុំកន្លង	ហេតុចំណងពីព្រឹទ្ធព្រេង។
បានឆុកបទវាទី	បានជាក្តីបទចិត្តឯង
ហេតុចិត្តវៀចវង្វេង	បង់ទ្រព្យឯងបទចិត្តស្រាល។
រីអ្នកខ្ជេញខ្ជិលខ្សោយ	កុំបីឱយកាន់នូវការ
ពាលាអន្ធពាល	កុំឱយធម៌ឥតចិត្តចង់។
ទោះបានសត្វបក្សី	ប្រក្រតីតិចស្លាប់បង់
រីក្តីដឹងសព្វអង្គ	ប្រើគិតផ្សងគំនិតច្បាប់។

*(១)ឯភ្នែក : ឯនាយ ខាងមុខ ។*

ប្រើគ្រាប់ឯតាំងយូ ក្រងគ្រូពុំគួរគ្រាប់
កុំយល់មួយកណ្ដាប់ ជាមួយនឹងកំបង់ដៃ។
៦០. កុំយល់សសោកា កុំបីថាជាខ្មៅក្រៃ
បន្តិចនេះប្រពៃ គួរគ្រាប់កុំបីភ្លេចឡើយ។
ទោះបីដំរីបាត់ លោកប្រើស្កាត់វាជាត្រើយ
តាមនឹងដំរីហើយ កុំបីដើរនឹងជើងលា។
ទោះទូកដាច់សាត់សោះ យកទូកស្មោះទៅតាមគ្នា
នេះពាក្យព្រេងលោកថា ទុកជាច្បាប់តម្រាប់គេរ។
រីអ្នកមានប្រាជ្ញា សង្សារាយល់ពុំថេរ
ទុក្ខសោកភ័យចំណេរ ប្រើផ្ដាច់ផ្ដិលនិវាសស្ថាន។
ស្រុកមាសសឹកកុំបី ទៅជួញខ្វីរកធនធាន
រីខ្លួនកំព្រាប្រាណ ក្ររក្សានូវមាសប្រាក់។
៦៥. ចោរក្មួយចាំប្លែប្លន់ ឥតតំបន់ណានឹងលាក់
ខ្លួនឯងឥតបើដាក់ សារពើទ្រព្យបាត់អស់ឯង។
តំបន់ទីជ្រៅ កុំងូតនៅម្នាក់ឯងលេង
ទឹកហូររំពងត្រែង កុំបីអាលចុះទូកឆ្លង។
ក្រពើក្រពាពាំង សាហាវចាំសព្វព្រែកផង
ចាំចាប់ដោយបំណង បីដូចខ្យល់នឹងភ្លើងព្រៃ។
ដំរីគជសារធំ ឧទារជុំជាញជល់នៃ
ច្រើនរត់ចៀសចេញវៃ កុំយកខ្លួនទៅទប់ទល់។
កម្លាំងតិចពិតអង្គ ឯងថាអ្នកឯណាយល់
ទើបបានខ្លួនទុព៌ល លុះនៅដួលអាត្មាមរណ៍។
ព្រះធម៌នេះជាច្បាប់ ប្រសើរគាប់ឱយអស់នរ
អ្នកផងចាំបានបរិ- បូណ៌ដល់ត្រីពិធសួគ៌ហោង។

# ច្បាប់ត្រីនេតិ

## បទកាកគតិ

| | | | |
|---|---|---|---|
| ១. | បពិត្រមហារាជ | ទ្រើសទ្រង់អំណាច | អញ្ជើញស្តេចស្តាប់ |
| | ទំនឹកទំនង | នេះហោងជាច្បាប់ | ទុកជាសណ្តាប់ |
| | | នៃនរជនជាតិ។ | |
| | នរអ្នកណា | នឹងចូលទៅជា | វររាជអមាត្យ |
| | សេនាមន្ត្រី | កវីជាអាទ៏ | រៀនច្បាប់ជាខ្នាត |
| | | តែងទុករៀងទៅ។ | |
| | បម្រើព្រះបាទ | ព្រះបរមនាថ | អធិរាជចមចៅ |
| | ឱយសមឱយល្មម | នឹងក្សត្រានៅ | ឱយឡើងគាល់ហៅ |
| | | អ្នកជាអម្ចាស់។ | |
| | មួយនោះព្រះអង្គ | ក្សត្រាទ្រើសទ្រង់ | គ្រងផ្ទៃក្រោមក្រាស់ |
| | គួរមានមនោរម្យ | សុខសមសោមនស្ស | រៀនឱយច្បាស់លាស់ |
| | | ត្រង់ច្បាប់នេះណា។ | |
| ៥. | អស់មុខមន្ត្រី | ដោយព្រះបាលី | **នាសតិរាជា** |
| | បើមុខមន្ត្រី | ពុំពិចារណា | នឹងក្សិណក្សត្រា |
| | | ពុំលែងឡើយហោង។ | |
| | ត្បិតមុខមន្ត្រី | សេនាបតី | ពុំដោយគន្លង |
| | លោភោចង់បាន | បំពានរាស្ត្រផង | រាស្ត្ររឹងក្តៅហោង |
| | | អង្គឥតអាស្រ័យ។ | |
| | រាស្ត្រដូចមច្ឆា | មន្ត្រីសេនា | ដូចអង្គានៃ |
| | បើប្រែជាក្តៅ | ក្រៃក្រៅវិស័យ | រាស្ត្ររឹងកើតភ័យ |
| | | អង្គឥតពំនាក់។ | |
| | មន្ត្រីយោធា | បីដូចព្យគ្ឃា | និងពស់ពញ្លក់ |
| | រីអស់រាស្ត្រផង | ចរចូលពឹងពាក់ | ក្សិណប្រែជាយក្ខ |
| | | យង់ឥតករុណា។ | |
| | មួយ **កុបុត្តិ** | **នាសតិធនំ** | បទបន្ថែថា |

បើមានកូនកាច កំណាចហើយណា សិងវិនាសប្រា-
កដគឺសន្តាន។

១០. មួយ **កុត្ទុមំ** **នាសតិធនំ** វិនាសធនធាន
នៅភូមិអាក្រក់ នោះនឹងកើតមាន ព្យាធិបៀតប្រាណ
ពិតពុំប្រពៃ។

មួយ **កុគេហំ** **នាសតិជីវំ** បន្លែនេះនៃ
នៅផ្ទះអាក្រក់ នឹងកើតហឹនហៃ ប្រាជ្ញាញាណញេយ្យ
អាប់ឥតមង្គល។

កើតកេរ្តិ៍អាប់យស ដោយនូវពាក្យមនុស្ស គេដើរមកយល់
ហើយគេដឹងថា ផ្ទះអាក្រក់សល់ កើតអពមង្គល
ដោយពាក្យគេថា។

ឯសុមន្ត្រី ដោយអាថ៌បាលី **ទុឡ្ហិរាជា**
បើមុខមន្ត្រី មែនមានប្រាជ្ញា ដឹងអស់អធ្យា-
ស្រ័យគ្រប់ប្រការ។

តម្រង់មហាក្សត្រ សោយរាជសម្បត្តិ ក្សេមក្សាន្តភពការ
អស់រាស្ត្រមណ្ឌល សកលបរិពារ សឹងអស់រង្គាល
ដល់តិចឡើយហោង។

១៥. **ឯសុបុត្តំ** **ទុឡ្ហិកុលំ** ថាបើកូនផង
មែនមានគំនិត ល្អឥតឯហ្មង សឹងចំរើនបង
ប្អូនសាច់សន្តាន។

**ឯសុត្ទុមំ** **ទុឡ្ហិធនំ** ថាទោះភូមិស្ថាន
ល្អហើយនោះនឹង ចំរើនធនធាន សារពើនឹងបាន
ដូចចិត្តប្រាថ្នា។

**ឯសុគេហំ** **ទុឡ្ហិជីវំ** ថានៅគ្រឹហា
ល្អហើយនោះនឹង ចំរើនប្រាជ្ញា សារពើប្រាថ្នា
ពិតពុំកម្រ។

ទោះអ្នកផងដើរ គេសឹងសរសើរ ថាផ្ទះនោះល្អ
ចំរើនសួស្តី ចំរើនមាត់ម- នុស្សផងគេសរ-
សើរផ្ទះនោះនៃ។

ច្បាប់នេះត្រកាល សូមព្រះភូបាល បរមក្សត្រិយ៍ថ្លៃ

ទ្រង់ព្រះតំរិះ ត្រិះដោយញាណញេយ្យ ទុកក្នុងហឫទ័យ
ជាច្បាប់ទៅហោង។

២០. បពិត្រព្រះបាទ ព្រះបរមនាថ លើសលោកកន្លង
ជាតិជាតសូរ កំពូលរាស្ត្រផង ព្រះអង្គជាច្បង
ឯងឥតផ្ទឹមដល់។

យកព្រះប្រាជ្ញា យកព្រះញាណថ្លា ថ្លែងព្រះយោបល់
ត្រេកត្រិះកម្រាប អ្នកបាបកំហល់ ឱយនីរព្យសន៍សល់
បានដូចប្រាជ្ញា។

ទុក្ខរាស្ត្រទាំងឡាយ ក្នុងក្រៅបន្ទាយ សព្វព្រះមាត្រា
ព្រះឱស្ឋបណ្តាំ ទុកលើសិរសា ទម្ងន់អាជ្ញា
លើរាជមន្ត្រី។

បពិត្រមហារាជ ទ្រើសទ្រង់អំណាច ចេស្តារឹទ្ធិ
អញ្ជើញស្តេចស្តាប់ ជាច្បាប់គម្ពីរ សព្វព្រះវេណី
ថ្កល់ថ្កើងចំពោះ។

បីៗអសារ បីៗឥតការ បីៗសូន្យសោះ
ម្តេចហៅអសារ ឥតការដូច្នោះ ម្តេចហៅសូន្យសោះ
ទេទៅឥតត្រើយ។

២៥. នាហៅអសារ មានទ្រព្យឥតការ ពុំធ្វើបុណ្យឡើយ
ពុំសងគុណគេ អ្នកឯទៀតឡើយ ញាតិឯងជាត្រើយ
ពិតពុំស្រោចស្រង់។

នាហៅឥតការ ចាំសីលាចារ មោះឥតពាក្យត្រង់
ចិត្តចង់បានបុណ្យ ពុំប្រណិប័តន៍សង្ឃ ចង់យសបានអង្គ
ពិតពុំឧស្សាហ៍។

នាហៅសូន្យសោះ ឮធម៌ពិរោះ ពុំស្តាប់ធម្មា
យល់ក្រឹត្យក្រមច្បាប់ ពុំស្តាប់ក្រឹត្យជា ដឹងព្រះធម្មា
ពុំធ្វើបរិសុទ្ធ។

បីផ្គង់ស្នេហា បីផ្គង់ភរិយា បីៗផ្គង់បុត្រ
ម្តេចហៅស្នេហា ភរិយាបរិសុទ្ធ ម្តេចហៅផ្គង់បុត្រ
អស់ន័យនេះផង។

នាផ្គង់ស្នេហា រសគាប់ពិសា កុំភ្លេចឡើយហោង
សំណោះសំណួរ សាកសួរស្នេហ៍ស្នង ឧត្បាតនេះហោង

ពុំបង់ឡើយនៃ។

៣០. នាផ្តង់ភរិយា រណ្ដាប់គ្រឹហា ខ្ជាប់ខ្ជួនប្រពៃ
ទោះទ្រព្យរបស់ អម្រស់ទុកដៃ រក្សាសំចៃ
ពុំធ្លោយឡើយណ៎ា។

នាហៅផ្តង់បុត្រ ប្រពៃបរិសុទ្ធ ឱយរៀនសាស្ត្រ
សិល្បសារពើគាប់ ជាច្បាប់អាត្មា អរឱយភរិយា
ដូចដោយចិត្តថ្វាត់។

បីៗហីនល័ក្ខណ៍ បីៗហីនស័ក្តិ ហីនសួស្តីថ្វាត់
ម្តេចហៅហីនល័ក្ខណ៍ ហីនស័ក្តបង់បាត់ ហីនសូន្យទៀតទាត់
ន័យនេះសោតហោង។

នាហីនលក្ខណា សរសើរអាត្មា ឯងចេះកន្លង
ពោលឥតគេស្តាប់ សូរស័ព្ទសាសង ចូលស្ថានអ្នកផង
ឥតគេស្រដី។

នាហៅហីនល័ក្ខណ៍ ស័ព្ទគងព្មជាក់ ឥតស័ព្ទភេរី
មានមហាក្សត្រា ឥតមានក្សត្រី មានរាជធានី
ហើយគ្មានបន្ទាយ។

៣៥. នាហីនសួស្តី ល័ក្ខណ៍ផ្ទះអប្រិយ ភូមិសោតរំសាយ
ស័ក្តិសឹងពុំជា យាត្រាទៀបឆ្ងាយ និមិត្តស្អុនកាយ
អង្គឱយអប្រិយ។

បីៗបាត់ស្និទ្ធ បីៗបាត់មិត្ត បីបាត់ពន្លឺ
ម្តេចហៅបាត់ស្និទ្ធ បាត់មិត្តមេត្រី ពន្លឺរស្មី
បាត់បង់នោះណ៎ា។

នាហៅបាត់ស្និទ្ធ ពោលពាក្យខុសចិត្ត ខ្សឹបខ្សៀវជេរថា
ធ្វើមុខអាក្រក់ កុហកជាសា ហេតុនោះលោកថា
បាត់ស្និទ្ធពុំមាន។

វិន័យបាត់មិត្ត ពោលពាក្យពុំគិត សត្យាសងសាន
នាស្ថានលំនៅ ពុំទៅមកថ្កាន ខ្ចីទ្រព្យបង្ខាន
មុខពុំឱយយល់។

នាបាត់ពន្លឺ ភ្នែកពិតពុំភ្លឺ ពុំយល់បរិបូណ៌
ឥតសាច់ឥតញាតិ ស្តាប់ស័ព្ទស្តាប់សូរ ពិតពុំបរិបូណ៌
វិញ្ញាណឯងអាច។

| | | | |
|---|---|---|---|
| ៤០. | បីបាត់ខុនណាង | បីៗបាត់ជាង | បីៗបាត់ប្រាជ្ញ |
| | ម្ដេចបាត់ខុនណាង | បាត់ជាងឯងអាច | ម្ដេចហៅបាត់ប្រាជ្ញ |
| | | ទាំងបីនេះណ៎ា។ | |
| | នាហៅបាត់ខុន | ណាងនេះជាមុន | ស្រីមានលក្ខណា |
| | ពុំស្ដាប់អម្ចាស់ | យប់ថ្ងៃឡើយណ៎ា | ខ្លួនចាស់ព្រឹទ្ធា |
| | | ស្រដីឡេះឡោះ។ | |
| | រីបាត់ជាងជាតិ | ធ្វើការឥតខ្នាត | ពុំស្រេចការនោះ |
| | វាតែងឱយស្អាត | នឹងខ្នាតសូន្យសោះ | ពុំត្រូវចំពោះ |
| | | នឹងក្បួនច្បាប់ឡើយ។ | |
| | នាបាត់ប្រាជ្ញប្រុះ | កាលជំនុំនោះ | ស្ងៀមស្ងាត់ព្រងើយ |
| | ពាក្យពុំស្រដី | តិរិយឥតត្រើយ | ពុំសេពគប់ឡើយ |
| | | មារយាទអប្រិយ។ | |
| | បីៗបានរស | បីៗសប្បុរស | បីៗពន្លឺ |
| | ម្ដេចហៅមានរស | សប្បុរសមេត្រី | ពន្លឺរស្មី |
| | | ចាយចែងចរចា។ | |
| ៤៥. | ទោះមានរសកាល | សេពសោយអាហារ | មានរសពិសា |
| | អ្នកមានសប្បុរស | កបរសវាចា | មែនមានភរិយា |
| | | មារយាទប្រពៃ។ | |
| | រីសប្បុរិសា | ប្រកបលក្ខណា | មានធមឥសោតនៃ |
| | ស្រដីនូវអាថ៌ | ជាធម៌ឈ្លាសវៃ | គាល់អម្ចាស់ថ្លៃ |
| | | មានពិចារណា។ | |
| | រីពន្លឺនោះ | កាលហូបបាយឆ្ពោះ | ទៀងទើបភោក្តា |
| | ពោលពាក្យនូវអ្នក | មានព្រះប្រាជ្ញា | ប្រកបភរិយា |
| | | ប្រណិប័តន៍សព្វកាល។ | |
| | បីៗហានហោច | បីៗត្រមោច | បីៗសាធារណ៍ |
| | ម្ដេចហៅហិនហោច | ត្រមោចឥតការ | ម្ដេចហៅសាធារណ៍ |
| | | ស្រេចស្រាយចេញហោង។ | |
| | នាហៅហិហោច | អសារអសោចិ៍ | ខ្លួនខ្លៅធ្វើឆ្គង |
| | គប់នូវអ្នកផឹក | ប្រមឹកស្រាផង | ប្រពន្ធសោតហោង |
| | | ស្រដីមាយា។ | |
| ៥០. | នាហៅត្រមោច | ត្រមោលកណ្ដោច | កណ្ដោងកំព្រា |

ឯងមានរបៀប ឥតប្រៀបអ្នកណា ឥតបុត្រស្ងួនភ្ងា
ត្រមោចសោតសល់។

នាហៅសាធារណ៍ មានព្រៀងឥតការ បំបែកកិច្ចកល
ប្រពន្ធឫស្យា អាត្មាទុព៌ល រឹងព្រួតបំណុល
លើខ្លួនទៀតកូវ។

បីៗសាមាន្យ បីបន្តរធាន បីៗអាស្រូវ
ម្តេចហៅសាមាន្យ អន្តរធានកូវ ម្តេចហៅអាស្រូវ
ពាក្យនេះលោកថា។

នាហៅសាមាន្យ សង់ផ្ទះនាស្ពាន ទៀបផ្សារពុំជា
គប់នូវអ្នកពាល សាធារណ៍មោហា ប្រពន្ធនោះណា
ច្រើនបំណុលនៅ។

រីអន្តរធាន សង់ផ្ទះនាស្ពាន នោះនៅជិតផ្លូវ
ខ្លួនរែងអប្រិយ មានក្តីអាស្រូវ ប្រពន្ធនោះកូវ
ប្រមឹកស្រាផង។

៥៥. នាហៅអាស្រូវ សង់ផ្ទះជិតផ្លូវ ធ្លានោះសោតហោង
ម៉ែក្មេកពុំជា មាត់រឹងកន្លង ប្រពន្ធនោះហោង
គេលែងទៀតខ្ទី។

បីៗបរលោក បីៗពុំចោក បីៗលោកិយ
ម្តេកហៅបរលោក ពុំចោកនោះក្តី ម្តេចហៅលោកិយ
គួរដឹងសោះសា។

នាហៅបរលោក រកគ្រូនាលោក ដ៏មានប្រាជ្ញា
ខ្លួនសោតពុំខ្ជិល ចាំសីលភាវនា ចិត្តថ្លាសទ្ធា
ពុំដែលដាច់ឡើយ

នោះហៅពុំចោក រក្សាប្រាណលោក ដំណឹងខ្លួនហើយ
អង្គុយខ្ពង់ខ្ពស់ ថ្កើងយសជាត្រើយ ភរិយាគាប់ហើយ
ត្រកូលថ្លៃផង។

នាហៅលោកិយ ពុំយល់ឯងក្តី មាសច្បាប់សោតហោង
ពាក្យពោលសត្យា ចរចាឥតហ្មង ពាក្យពីរោះផង
សាន្តសមសាទរ។

៦០. បីៗប្រាសលោក បីៗចយចោក ប្រាសលោកុត្តរ
ម្តេចហៅប្រាសលោក ចយចោកពុំប- វិបូណ៌លោកុត្តរ

ឱយពិចារណា។
នាហៅប្រាសលោក   ស្រដីថយថោក   ពាក្យនោះពុំជា
ខ្លួនឯងតំអឹង   ពាក្យរឹងមហិមា   យល់ចាស់ព្រឹទ្ធា
ពិតពុំប្រណិប័តន៍។
ថោកប្រាណពេកណ៎ា   ទុរយសអសារ   អង្គុយថយក្អាត់
អាហារថយផ្ទង់   បម្រុងពីមាត់   នេះហោងលោកកាត់
ហៅថយថោកហោង។
រីប្រាសលោកកូវ   គួរនោះពុំត្រូវ   ដោយធម៌ទំនង
យល់សង្ឃឥតចិត្ត   ប្រណិប័តន៍សង្ឃផង   សីលទាននោះហោង
ពុំស្គាល់ឡើយណ៎ា។
មានតែបំបាត់   ជីវិតសព្វសត្វ   ឥតមានមេត្តា
ហៅប្រាណលោកកូវ   គួរនៅឯណា   មានពន្ធបីប្រា-
ការអកុសល។

៦៥. ព្រះអង្គមហាក្សត្រិយ៍   សោរាជសម្បត្តិ   គ្រងរាជមណ្ឌល
រើសរកសេនា   ឱយជាសុខពល   ហើយនឹងតំកល់
ស្នងព្រះនេត្រន័យន៍។
ក្រឡាពាសធំ   ជាមេកងជុំ   ការសង្គ្រាមជ័យ
ស្រាល់រកអ្នកណា   ចេះអធ្យាស្រ័យ   មានប្រាជ្ញាវៃ
ស្គាល់គ្រប់រាជការ។
ស្គាល់ទោសស្គាល់គុណ   ស្គាល់ក្រោយស្គាល់មុន   ដើមចុងកណ្ដាល
ស្គាល់បាបស្គាល់បុណ្យ   ស្គាល់ធ្ងន់ស្គាល់ស្រាល   ស្គាល់ប្រាជ្ញស្គាល់ពាល
ស្គាល់ខ្លាចស្គាល់ហ៊ាន។
ស្គាល់តិចស្គាល់ច្រើន   សង្វាតក្រវើន   ស្គាល់អត់ស្គាលឃ្លាន
ស្គាល់វៀចស្គាល់ត្រង់   ស្គាល់ភូតស្គាល់មែន   ស្គាល់ដីស្គាល់ដែន
ស្គាល់ព្រៃស្គាល់ត្រាញ់។
ស្គាល់គាប់ស្គាល់ខុស   ស្គាល់ស្លាប់ស្គាល់រស់   ស្គាល់ឈ្នះស្គាល់ចាញ់
ស្គាល់បាញ់ស្គាល់បោះ   ស្គាល់ដោះស្គាល់ដេញ   ស្គាល់ចូលស្គាល់ចេញ
ស្គាល់បាត់ស្គាល់មាន។

៧០. ស្គាល់តឹងស្គាល់ធូរ   ស្គាល់ឆាប់ស្គាល់យូរ   ស្គាល់ហូលស្គាល់ខៀន
ស្គាល់ដើរស្គាល់ដេក   ស្គាល់ស្រេចស្គាល់ឃ្លាន   ស្គាល់ចង់ស្គាល់បាន
ស្គាល់មានស្គាល់ខ្សត់។

បើមានកង្វល់ កលិយុគមកដល់ គេប្រាប់ប្រាកដ
បាកុំឆោតឆ្វល់ វិលវល់រន្ធត់ កុំផ្សូរយូររត់
តំអក់តំអឹង។

កុំច្រើនវង្វេង ងងោងងងេង មមីមមមឹង
កុំច្រើនប្រទូស្ត រឹងរូសរបឹង កុំខ្ជិលរំពឹង
តែងដេកនិទ្រា។

កុំលោភចង់បាន ទ្រព្យគេបំពាន ពន្លឹកសោះសា
កុំរៀនកំណាញ់ ស្វិតស្វាញឫស្យា ពុំស្គាល់កាចជា
ពាក្យពេចន៍ទ្រគោះ។

កុំលេងជាល្បែង រំពឹងយល់ឈ្វេង ពាក្យពុំពីរោះ
ស្រដីឱយដាច់ ឱយស្រេចឱយស្មោះ កុំធ្វើឡេះឡោះ
សសោះអន្ទង។

៧៥. កុំធ្វើហេងហាង កុំអួតកុំអាង ខុសក្ដីបំណង
កុំច្រើនក្រអែស ប្រហែសលេងលង ឱយរៀនត្រងរង
នូវក្ដីអំណត់។

អ្នកណាអាចស្គាល់ អាចដឹងអស់អាថ៌ ជាក់ជាងប្រាកដ
ធ្វើការសង្គ្រាម ព្យាយាមចំហុត ឮកេរ្តិ៍ប្រាកដ
ដូចព្រះរាមា។

ស្ដេចផ្ចាញ់អសុរ អស់ឥតសំណល់ ដល់មួយឡើយណា
បើបានសណ្ដាប់ ក្រមច្បាប់សាស្ត្រា ទុកអង្គអាត្មា
ទីទៃគ្រប់ប្រាណ។

វីច្បាប់នេះណា បើអ្នកឯណា យកទុកឱយបាន
ក្នុងអង្គអាត្មា ជាសណ្ដាប់ប្រាណ អ្នកនោះនឹងបាន
ជាអង្គអ្នកប្រាជ្ញ។

បើអ្នកឯណា បានមើលអក្ខរា ថាឱយស្រួលស្រេច
ជួយជួសសេចក្ដី អស់អាថ៌សេចគ្រេច ឱយទានបន្តិច
កុំសើចឡើងហោង។

៨០. ជួយកែឱយត្រូវ តម្រង់តម្រូវ ដោយនូវគន្លង
ជាច្បាប់បុរាណ ពិតពីព្រេងហោង ឱយត្រូវបំណង
ព្រេងព្រឹទ្ធបុរាណ។

សេចក្តីនេះណា និទានអស់អាថ៌ ចប់បរិបូណ៌បាន
នេះហោងជាច្បាប់ សណ្តាប់គ្រប់ប្រាណ ឱយឱវាទទាន
និដ្ឋិតំចប់ហោង។

# ច្បាប់រាជនេតិ ឬ ច្បាប់ព្រះរាជសម្ភារ[១]

## បទកាកគតិ

១. ហៃសាធុជនផង នេះគឺចំណង បទបាលីថា
គម្ពីររសធម៌ អាណាក្រិត្តិកា គួរគប្បីមហា-
ជនផងត្រងត្រាប់។

ធម៌នេះដំបូន្មាន រួមរក្សាប្រាណ ឱយបានក្ដីគាប់
ដ៏លោកបរលោក ហៅរសពុំស្លាប់ ធម៌នេះជាច្បាប់
ក្ដីគាប់បរិយាយ។

កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្តម៍ កុំទុកចិត្តអភិប្រាយ
ប្រើស្មំលែងខ្ពស់ រំពឹងឱយឆ្ងាយ ស្ដាប់ពាក្យបរិយាយ
បណ្ឌិតបេដី។

កុំរឿងដោយខ្យល់ កុំឱយពាក្យពល កុំខ្វល់ដោយស្រី
កុំកាន់ពិសយង់ គប់នឹងស្ត្រី សមណៈជនជី
កុំឱយក្ដីត្រូវ

៥. កុំនៅញ៉ាំងឈ្លោះ កុំស្ដាប់អសុរោះ កុំស្ដាប់អាស្រូវ
កុំដើរពានស្កុន កុំស្កាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី។

ផ្អែមពីរប្រការ ចំណីនៅដាល កុំអាលឱយធី
ផ្អែមមួយពាក្យពាល រែងរាលរកក្ដី ផ្អែមមួយពាក្យស្រី
ស្រដីមាយា។

ពាក្យគ្រូរែងរឹង ស្រារែងស្រវឹង ពុំដែលពិសា
ពាក្យពិតរែងស្លែង ពុំពីរោះថា បណ្ឌិតមេបា
រែងថាពុំគាប់។

ខ្លៅរែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រចណ្ឌ រែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់
រែងស្អប់ប្រដៅ។

(១) *"ច្បាប់ព្រះរាជសម្ភារ" ហៅតាមនាមលោកអ្នកតែង គឺព្រះស្រីធម្មរាជាព្រះរាជសម្ភារ។*

ចង់បុណ្យបានបាប ចចើងចង់លាភ រែងបាត់ធនទៅ
មានះបាត់មិត្ត ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ
រមែងបាត់អង្គ។

១០. ស្វែងគាប់បានយស ចង់ស្វែងរបស់ ប្រើចេះផ្គត់ផ្គង់
ចង់ធំកុំអួត ដើមមានពូជពង្ស ចង់ឱយខ្លួនត្រង់
ប្រើផ្គាប់អ្នកមុខ។

ខ្លែងហើរត្បិតខ្យល់ នាយថ្កើងត្បិតពល រក្សាឱយសុខ
ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក
ត្បិតភរិយាជា។

បាត់យសត្បិតខ្ជិល បាត់ញាណទានសីល ត្បិតសេពសុរា
ប្រមាថបាត់បុណ្យ ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា
បាត់ឥរិយាគាប់។

អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ
មេត្រីជាញាតិ រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់
ជាគន្ធពិដោរ។

ទឹកបាក់ទៅទាប បុណ្យបាត់ត្បិតបាប លាភបាត់ត្បិតឃោរ
ទឹកថ្លាត្បិតរលក ពុំយល់ស្រមោល ទោសកើតត្បិតពោល
ល្មមមាត់ឈ្លានពាន។

១៥. ខ្លៅរែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច រែងធ្វើជាហ៊ាន
ខ្សត់ខ្សោយស្មុគទ្រុឌ រែងធ្វើជាមាន អ្នកឥតសន្តាន
រែងមើលគេងាយ។

ទាហានច្រើនត្បិតសឹក ធ្វើស្រែត្បិតទឹក ត្រឹកពលត្បិតបាយ[១]
សិស្សប្រាជ្ញត្បិតគ្រូ ជេរពាលដំវាយ ពលជាត្បិតនាយ
ហ្វឹកហ្វឺនខះខំ។

រៀនក្តីគួរគិត ចាស់ឥតប្រព្រឹត្ត នៅប្រែច្រឡំ
អ្នកជាជាកាច តូចប្រែជាធំ ពង្សពូជឧត្តម
ច្រឡំជារាស្ត្រ។

ឃើញសេះជាលា ក្ងានជាទា ពពាយជាទាស
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស បង្គួយជាជាស

*(១) ត្រឹក ពាក្យបុរាណ ប្រែថា : ដឹកនាំ ត្រើនរំលឹក ។*

កប្បាសជាគ។
ហេតុនេះគួរគិត គួររិះរកហិត ដឹងរសគន្ធ
គិដោរអសុដោរ ពីសាសាទរ ហិតហើយសឹមប-
រំកោក្កាក្កិត។
២០. ល្ងឹកព្ទពាក្យពេចន៍ សាកសួររកសាច់ សន្ដានព្រេងព្រឹទ្ធ
រករិះកលអ្វី សុចរិតទុច្ចរិត ហើយហោងគួរគិត
ឱយដឹងខ្ពស់ទាប។
ដូចខ្វាក់បាំងស្បែក មួយដូចតំពែក ចង់សុំប្រេងលាប
ដូចថ្លង់ស្ដាប់ច្រៀង ទះដៃព្រាកៗ ដូចខ្វិនអាបឡាប
ចង់ចងក្បិនរត់។
ពុតញ្ញាយមានបី មួយដូចដំរី សាហាវឥតបទ
អាចផ្សះផ្សាំងបាន កង្វេរកាន់កត់ ដាលដេញគោតគត់
ប្រាំមួយហត្ថហោង។
មួយចង់ឈ្នានីស ចិត្តចង់ចចេស កុំដោយគន្លង
ពាក្យពោលអ្នកធំ ប្រទ្បាំសូរសង ពុំគិតក្ដីហ្មង
ចង់ចេរអន្តរាយ
មួយស្រីពេស្យា បំពេញព្រហ្មចា- រីរួសអភិប្រាយ
អំពើទាំងបី ហៅពិសពុតញ្ញាយ សាធុសម្វាយ
ចៀសកុំបីគ្រាប់។
២៥. ប្រាជ្ញពុំស្មើពុត បម្រើលំអុត ពុំស្មើក្ដីគាប់
មានគុណពុំស្មើ អ្នកមានបុណ្យភ័ព្វ ស្វែងរៀនរកច្បាប់
ពុំស្មើចិត្តជា។
ស័ក្តិពុំស្មើយស អ្នកមានរបស់ ពុំស្មើស័ក្កា
សូវបង់ធនធាន កុំខុសអាជ្ញា សូវមានរោគា
កុំឱយមើលងាយ។
សូវសុំកុំយក គ្នាស្មើកុំរក ដូចបាវនិងនាយ
ខុសគាប់សូវអត់ កុំឱយព្ទឆ្ងាយ ក្ដីសុខមទាំងឡាយ
កុំខ្វាយសូរស័ព្ទ។
ធម៌នេះដំបូន្មាន រួមរក្សាប្រាណ ឱយមានក្ដីគាប់
សូវបង់ធនធាន កុំឱយខ្លួនស្លាប់ សូវស្លាប់គួរគាប់
រសធម៌កុំបីបង់។

បណ្ដាំមេបា អំបូរលោកថា ទុកតាមកំពង់
សំពៅតាមខ្យល់ ចង្កូតតម្រង់ មេលឹមតែងត្រង់
ត្រីវិស័យជាមុខ។

៣០. ដូចចិត្តប្ដីជា ដូចមានភរិយា នៅផ្ទះស្រណុក
ដូចកូនទទួល យកពាក្យអាពុក ដូចខ្ញុំឱយមុខ
អម្ចាស់ប្រើហៅ។

បណ្ដាំមេបា អំបូរលោកថា ព្រេងព្រឹទ្ធប្រដៅ
ទើងឆីប្រើរក ទើបស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ
មិត្រមកជាមិត្រ។

ពាក្យខុសកុំស្ដាប់ ក្ដីខុសកុំត្រាប់ អ្នកកាចកុំផ្ចិត
ល្ងង់កុំស្រដី ខ្សត់កុំទុកចិត្ត ពាលោកុំផ្ចិត
ជាមិត្រមេត្រី។

ប្រើថ្លឹងឱយស្មើ ទោះបីនឹងប្រើ ប្រើអ្នកចេះក្ដី
កុំយកពាក្យស្លោក ផ្ទឹមនឹងគម្ពីរ កុំយកពាក្យជី
ផ្ទឹមនូវពាក្យពាល។

មើលភ្នែកជញ្ជីង ក្នុងចិត្តឱយដឹង ណាធ្ងន់ណាស្រាយ
កុំយកមណីរ័តន៍ មាសមានជាកាល ចិត្តកុំបណ្ដាល
នូវបង់សីលធម៌។

៣៥. ប្រើដឹងគុលហាប ប្រើដឹងខ្ពស់ទាប មានភ្នែកយល់ល្អ
ទោះដឹងទឹកមាស ពុំចេរនៅថ្ម ទោះដឹងដីស
ពុំចេរសំបុត្រ។

ធ្វើស្រែមើលស្មៅ សន្ដានមើលផៅ បំរើមើលពុត
ទោះដឹងពុតជា ពុំចេះពុតត្បុត ដឹងចិត្តបរិសុទ្ធ
ពុំចេរឥរិយា។

ទេបីមើលក្រឹត្យ ក្សត្រាមើលឫទ្ធិ៍ ទាហានមើលចេស្ដា
ជាងមើលអំពើ អំពីហត្ថា ទោះយកភរិយា
មើលនាលំនៅ។

អសារក្ដីបី បណ្ដាំមេជី ព្រេងព្រឹទ្ធប្រដៅ
អង្គរសសុទ្ធ ចម្អិនឱយឆៅ ពិសីហើយខ្លៅ
ប្រាជ្ញផុតមារយាទ។

អ្នកបួសឥតត្រឹតុយ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ
ភរិយាផុយផាយ ចាយវាយឥតខ្នាត ពពាលសុទ្ធសាធ
ប្រដៅក្រុបាន។

៤០. ផ្ទះភ្លើងមានបី អំពើពុតស្រី ខឹងឥតប្រមាណ
កូនកាចចចេស ពុំដោយដំបូន្មាន ខ្ញុំកាចកៀសប្រាណ
ពុំឱយម្ចាស់ប្រើ។

ហោរាប្រើគួរ ភមូប្រើមូល ស្នង់ទឹកប្រើស្មើ
បន្ទាត់ប្រើត្រង់ ពលផ្ទង់គប្បីប្រើ ពុំហើយគប្បីធ្វើ
កុំលេងគប្បីភ្វា។

ក្ដីកោតមានបី កោតមួយពួកស្រី ស្រដីមាយា
កោតមួយពាក្យពិស អាស្រ្វជេរថា កោតមួយពាក្យពា-
លោលោកទូជំន។

ពិសពស់នានា កុយខ្លាយទន្លា កាលគត់ស្ដាប់មន្ដ
ត្រង់ពិសពាក្យពាល រោលរាលពុំស្រន់ សម្បីអស់ជន្ម
ក្រមន្តបោសបាន។

ហេតុនោះគួរគិត គួររិះរកហិត ថ្នាំពិសឱយស្រាន្ត
ដ៏លោកនេះគួរ រកអ្នកទ្រង់ញាណ សេពសាងសីលទាន
ជាថ្នាំលោកិយ។

៤៥. រីថ្នាំបរលោក ចៀសចាកទុក្ខសោក ចង់បញ្ចិន្ទ្រិយ
គប្បីផឹកសត្តតិង្ស- ពោធិបក្ខិយ អាចនាំដល់ត្រៃ-
ពិធសម្បត្តិសារ។

ពិដោរផ្កាបី ពិដោរមេត្រី សួស្ដីសីលាចារ
ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល
ដល់សួគ៌ពុំស្បើយ។

ពិដោរផ្កាបី ក្រៃលែងក្លិនភ្ញី ឥតឯល្ហែល្ហើយ
ដោយខ្យល់ប្រាសខ្យល់ នៅត្រើយឆ្លងត្រើយ ពិដោរពុំស្បើយ
ហៅរសគន្ធា។

ពិសាផ្លែប្រាំ ពិសារសធម៌ ពិសាសត្យា
ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារសវា-
ចាចេញមធុរ។

| | | | |
|---|---|---|---|
| | ពិសាផ្លែប្រាំ | គិតជានាយនាំ | ឥន្ទ្រិយទៅចូល |
| | ត្រីពិធសម្បត្តិ | ទិព្វរ័តន៍អនុកូល | ចំណោរទៅចូល |
| | | មោក្ខមគ្គាល័យ។ | |
| ៥០. | ធម៌នេះជាច្បាប់ | ប្រសើរមហាគាប់ | ឧត្តមពេកក្រៃ |
| | ក្រអ្នកណាបាន | ប្រាជ្ញាឈ្លាសវៃ | អាចដឹងដោយន័យ |
| | | រសធម៌គាថា។ | |
| | គួរចេះគួរចាំ | គួរតាមបណ្ដាំ | ទូលទុកសិរសា |
| | ធម៌នេះស្មើក្សីរ | អម្រឹតធារា | សម្ដេចភគវា |
| | | សាធុប្រោសប្រាណ។ | |
| | អ្នកណាបានស្ដាប់ | អ្នកណាបានត្រាប់ | អ្នកណាបានធ្យាន |
| | រសធម៌នេះគាប់ | ជាច្បាប់ទូន្មាន | អ្នកនោះស្មើបាន |
| | | ដល់និព្វានហោង។ | |

# ចប់